نبي يوسف

عليه السلام

ប្រវត្តិណាពីយូសុះ

ដឹងស៊ីឡៃខ្មែរ

ឃ្លាំងចំណេះដឹងឥស្លាមកម្ពុជា

بِسۡمِ ٱللَّهِ ٱلرَّحۡمَٰنِ ٱلرَّحِيمِ

قال الله تعالى قوله تعالى : ولقد جاءكم يوسف من قبل بالبينات فما زلتم في شك مما جاءكم به حتى إذا هلك قلتم لن يبعث الله من بعده رسولا كذلك يضل الله من هو مسرف مرتاب . وقال رسول الله ﷺ":الكريم ابن الكريم ابن الكريم ابن الكريم يوسف بن يعقوب بن إسحاق بن إبراهيم." وبعد

السلام عليكم ورحمة الله وبركاته

បងប្អូនមុស្លីមីន និងមុស្លីម៉ាតជាទីគោរពស្រលាញ់..

យើងបានដឹងមកហើយថា នៅក្នុងគម្ពីរអាល់កូរអានរបស់អល់ឡោះជាម្ចាស់ដែលបញ្ចុះលើព្យាការីមូហាំម៉ាត់នៃយើង អល់ឡោះបានរៀបរាប់អំពីប្រវត្តិណាពីយូសុះ ដើម្បីជាដំណឹងជូនដល់មនុស្សលោកឲ្យធ្វើការស្វែងយល់ និងរិះគិតដំរិញការបាត់បង់ ការអត់ធ្មត់ និងការលំបាកឈឺចាប់របស់ណាពីយ៉ាកូប និងណាពីយូសុះ។

ដូច្នោះ នេះគឺជាកម្រងឯកសាររៀបរាប់អំពីប្រវត្តិណាពីយូសុះ ដែលក្រុមការងាររបស់យើងខ្ញុំ (**ឃ្លាំងចំនេះដឹងឥស្លាមកម្ពុជា**) បានខិតខំប្រឹងប្រែងស្រាវជ្រាវ ចងក្រងឡើងរហូតបានក្លាយជារូបរាង និងក្លាយជាអត្ថបទមួយដ៏តូចខ្លីជាភាសាខ្មែរ ក្នុងគោលបំណងដើម្បីចែករម្លែក ជាចំនេះដឹង ដើម្បីស្វែងយល់អំពីប្រវត្តិណាពីយូសុះដល់បងប្អូនមុស្លីមីន និងមុស្លីម៉ាត បានដឹង ដើម្បីពិចារណារិះគិត (إعتبار)។

សង្ឃឹមថា អត្ថបទប្រវត្តិយូសុះដ៏ខ្លីមួយនេះនឹងផ្តល់ប្រយោជន៍ដល់អ្នកទាំងអស់គ្នា ដើម្បីយកជាគំរូ នឹងប្តឹងប្តែងក្នុងការរស់នៅជាក់ជាពុំខាន។

نبی یوسف علیه السلام

ប្រវត្តិណាពីយូសុះ



ក្រុមគ្រួសារ

ណាពីយ៉ាកុប (يعقون عليه السلام)

ណាពីយ៉ាកូប គឺជាកូនរបស់ណាពីអ៊ីស្ហាក់ ពិន ណាពីអ៊ីព្រហ៊ីម ហើយម្តាយរបស់លោកឈ្មោះ រ៉ាហ្វកោះ ពិនទី ប៉ាទូអ៊ីល មកពីពូជប៉ានីអ៊ីស្រអែល ណាពីយ៉ាកូបបានរៀបការជាមួយនាងរ៉ាហែលដែលជានារីវ័យជំទង់ម្នាក់ មានរូបសម្ផស្សស្រស់ស្អាតជាច់គេ ហើយកជាភរិយាទីពីររបស់យ៉ាកូបផងដែ ឯចំនែកភរិយាទីមួយរបស់លោកឈ្មោះ ឡេយ៉ា (នាងឡេយ៉ាគឺជាបងស្រីបង្កើតរបស់នាងរ៉ាហែល) ហើយណាពីយ៉ាក់កូបនឹងនាងទាំងពីរនាក់វិញត្រូវជាជីដូនមួយនឹងគ្នាផងដែ។ ភរិយាទី៣របស់ណាពីយ៉ាកូបឈ្មោះ ហ្សុល

ហ្វះ នឹងទី៤ឈ្មោះ ពុលហះ (អ្នកទាំង២នាក់គឺជាកូនឈ្នួលកង្វាលពពែរបស់ឡៃយ៉ា និងរ៉ាហែល)។ ខាងក្រោមនេះ គឺជាឈ្មោះភរិយារបស់ណាពីយ៉ាកូប នឹងឈ្មោះកូនៗរបស់លោក៖

ភរិយាទី១. ឡៃយ៉ា

ណាពីយ៉ាកូបនឹងនាងឡៃយ៉ាមានកូនប្រុសស្រីចំនួន៦នាក់ គឺ៖

១.រ៉ាពីន ២.សាមូន ៣.ឡាវី ៤.យ៉ាហ៊ូហ្សា ៥.យ៉ាកាសៀរ ៦.ហ្សាពូលូន។

ភរិយាទី២. រ៉ាហែល

រីឯកូនៗណាពីយ៉ាកូបជាមួយនាងរ៉ាហែលវិញមានកូនប្រុសចំនួន២នាក់គត់ គឺ៖

១. ណាពីយូសុះ និង ២. ពុនយ៉ាមីន។

ភរិយាទី៣. ហ្សុលហ្វះ

កូនជាមួយនាងហ្សុលហ្វះមាន២នាក់គត់ គឺ៖

១.ចាអាត់ និង ២.អាសៀរ។

ភរិយាទី៤. ពលហះ

កូនជាមួយពុលហះ ក៏មានតែ២នាក់ដែ គឺ៖

១.ដាអាន និង ២.ណាហ្វ្រលី។

សរុប ណាពីយ៉ាកូបមានភរិយាចំនួន៤នាក់ និងកូនៗសរុបចំនួន ១២នាក់។ គ្រួសារណាពីយ៉ាកូបគេឲ្យឈ្មោះថា អាល់អើសពើត (មានន័យថាអម្បូរមកពីអម្បូរអ៊ីស្រអែល)។

ណាពីយូសុះ

(يوسف عليه السلام)

ប្រវត្តិណាពីយូសុះត្រូវបានអល់ឡោះបញ្ចុះលើណាពីមូហាំម៉ាត់ពេញមួយស៊ូរ៉ោះ ពោលមាន111អាយ៉ាត់។ នាពេលដែលមានពួកយ៉ាហ៊ូទី (គ្រឹះសាសនា) មួយក្រុមបានសួរនាំណាពីមូហាំម៉ាត់ឲ្យរៀបរាប់អំពីប្រវត្តិទាក់ទងទៅនឹងណាពីយ៉ាកូប នឹងណាពីយូសុះដូច្នោះអល់ឡោះបានហៀរ៉ាំមានប្រាប់ណាពីមូហាំម៉ាត់ដូចអល់ឡោះបានពោលក្នុងគម្ពីរអាល់កូរអាន ស៊ូរ៉ោះយូសុះ អាយ៉ាត់ទី03 ថា៖

نَحْنُ نَقُصُّ عَلَيْكَ أَحْسَنَ ٱلْقَصَصِ بِمَآ أَوْحَيْنَآ إِلَيْكَ
هَٰذَا ٱلْقُرْءَانَ وَإِن كُنتَ مِن قَبْلِهِۦ لَمِنَ ٱلْغَٰفِلِينَ ٣

មាននំយថា៖ "យើងនិទានប្រាប់ចំពោះអ្នក (មូហាំម៉ាត់) អំពីរឿងនិទានដ៏ល្អលើសគេនូវអ្វីដែលយើងបានបញ្ចុះឲ្យអ្នកជាគម្ពីអាល់កូរអាននេះ។ ហើយជាការពិត តាំងពីមុនមក អ្នកពិតជាអ្នកក្នុងចំណោមពួកអ្នកដែលមិនបានចាប់អារម្មណ៍ (ដឹង) រឿងនិទាននេះ" ។

ណាពីយូសុះគឺជាកូនទី១១ ហើយគឺបងប្រុសបង្កើតរបស់ពុនយ៉ាមីន ជាកូនពៅ (ទី១២) ក្នុងចំណោមបងប្អូនប្រុសស្រីទាំងអស់១២នាក់របស់ណាពីយ៉ាកូប ក្នុងចំណោមបងប្អូនទាំងអស់ ណាពីយូសុះនឹងប្អូនប្រុសបង្កើតគឺជាកូនដែលណាពីយ៉ាកូបស្រលាញ់នឹងអានិតអាសូជាងគេ ដោយសារពួកគេទាំងពីរនាក់ជាក្មេងកំព្រារម្តាយ តាំងពីនាងរ៉ាំហែលបានប្រសូតពុនយ៉ាមីនរួចមកម្លេះ ដែលពេលនោះ យូសុះទើបតែមានអាយុ១២

ឆ្នាំប៉ុណ្ណោះ។ នាងរ៉ាហែលបានស្លាប់បាត់បង់ជីវិតចោលណាពីយ៉ាកូប នឹងកូនប្រុសទាំង
ពីរនាក់របស់នាង យូសុះគឺជាកូនដែលស្អាតល្អឯកជាងបងប្អូនដ៏ទៃទៀត គឺជាក្មេង
ប្រុសម្នាក់ដែលមានរូបសម្រស់ស្រស់សង្ហា មានពណ៌សំបុលសរលោង រូបរាងធំខ្ពស់
ស្រទ្បះ ដំណើសំសួន នឹងមានអត្តចរឹកស្លូតបូត តៀងត្រង់ សក់ខ្មៅអង្គាដ គ្មានអ្នក
ប្រដូចទ្បើយ ហេតុដូច្នោះហើយ បានធ្វើឲ្យកូនៗណាពីយ៉ាកូបផ្សេងទៀតមានអារម្មណ៍
ថាច្រណែនឈ្នានីស មិនសប្បាយចិត្ត អាក់អនចិត្តជាមួយយូសុះ នឹងឪពុករបស់ពួក
ខ្លួនយ៉ាកូបដែលអានិតស្រលាញ់យូសុះនឹងពុនយ៉ាមុនខ្លាំងជាងពួកខ្លួននោះ ដោយ
ហេតុក្នុងចិត្តរបស់ពួកគេគិតថា ទង្វើរបស់យ៉ាកូបដែលជាឪពុកនោះ មិនយុត្តិធម៌
លម្អៀងម្ខាងយូសុះនឹងពុនយ៉ាមុន ធ្វើឲ្យពួកគេមិនអាចទទួលយកបាន រហូតបណ្តាល
ឲ្យពួកគេមានអារម្មណ៍ចងគំនំជាមួយណាពីយូសុះ នឹងរិះរកគ្រប់ល្បិចកល់ផ្សេងៗ
ដើម្បីបំបែកយូសុះពីយ៉ាកូប នឹងធ្វើបាបយូសុះ រឺកំចាត់យូសុះឲ្យរស់នៅឃ្លាត់ឆ្ងាយពី
ឪពុកជាទីស្រលាញ្ញ នឹងក្រុមគ្រួសារ។

គម្រោងសម្លាប់យូសុះ



នៅក្នុងយប់មួយកណ្តាលអាធ្រាត ដោយបង
ប្អូនយូសុះទាំង១០នាក់នោះ បានប្រមូលផ្តុំ
គ្នាដើម្បីពិភាគសារឆ្ងេចឆ្ងើមគំនិត រកល្បិច
កល់ផ្សេងៗប៉ុនប៉ងសម្លាប់ ធ្វើបាបយូសុះ។
ម្នាក់ក្នុងចំណោមបងប្អូនទាំង១០នាក់ផ្សេង
ទៀត បានហៅបបួលគ្នីគ្នាជួបជុំមួយ ដើម្បី
ញុះញុងបងប្អូនផ្សេងទៀតឲ្យរួមដៃសហ
ការណ៍ជាមួយខ្លួន ហើយរិះរកល្បិចកល់

សម្លាប់ណាពីយូសុះ ដោយនិយាយថា៖ *តើបងប្អូនទាំងអស់មានដឹងដែរឬទេថា.. ឪពុករបស់ពួកយើងមិនដែលចាត់ទុកពួកយើងជាកូននោះទេលើកលែងយូសុះ លោកបានស្រលាញ្ជាងដែលមើលទៅហាបីដូចលម្អៀងម្ខាង មិនស្មើភាពរវាងពួកយើងនឹងយូសុះ លោកមើលចែ អាណិតស្រលាញ្ជ នឹងធ្វើអ្វីៗគ្រប់យ៉ាងដើម្បីយូសុះ ចុះពួកយើងវិញ? ក្រែងពួកយើងទាំងអស់គ្នាក៏ជាកូនរបស់លោកផងដែ ចែមទាំងពួកយើងជាអ្នកជានិច្ចជាកាលជួយការងារផ្ទះ កង្វៀលពពែ និងចេះដឹងខុសត្រូវជាងយូសុះទ្ងាយ ចុះហេតុអ្វីបានជាឪពុកយើងលោកមិនដែលបើកភ្នែកមើលទង្វើល្អរបស់ពួកយើងបន្តិចសោះ មិនដែលក្ងាយខ្ងល់នឹងសុខទុក្ខរបស់ពួកយើងសោះអញ្ចឹង?*។ បន្ទាប់ពីលឺសំដីបែបនោះរួចម្នាក់ក្នុងចំណោមពួកគេទាំង១០នាក់ផ្សេងទៀតបាននិយាយតបតថា៖ *ភាពលំអៀងរបស់ឪពុកយើងពិតជាមិនស្មើភាពនឹងយុត្តិធម៌បន្តិចនោះទេ ហេតុអ្វីឪពុករបស់ពួកយើងបង្កើតដូចយូសុះដែ ប៉ុន្តែហេតុអ្វីលោកស្រលាញ្ជអានិតយូសុះលើសឲ្ងាយជាងពួកយើងបែបនេះ? ពួកយើងមានដើមកំនើតពីឪពុកតែមួយដូចគ្នា ទុះមានម្តាយទីទែផ្សេងគ្នា ផ្ទុយមកវិញគួរតែឪពុកយើងស្រលាញ្ជពួកយើងខ្លាំងជាងយូសុះនឹងពុនយ៉ាម៉ុនព្រោះម្តាយរបស់យើងទ្បែយ៉ាគឺជាប្រពន្ធដើម ហើយកជាម្តាយធំជាងគេដែ ឯចំនែកម្តាយយូសុះនឹងពុនយ៉ាម៉ុនវិញជាម្តាយចុងតែប៉ុណ្ណោះ ម៉្យាងវិញទៀតមេដែតែងតែធំជាងកូនដៃនឹងម្រាមដៃផ្សេងៗទៀត ដូច្នោះទង្វើឪពុករបស់យើងបានបញ្ជាក់យ៉ាងច្បាស់ថាលោកលម្អៀងម្ខាងយូសុះ មិនស្រលាញ្ជពួកយើងដូចដែលលោកស្រលាញ្ជយូសុះនោះទេ ពួកយើងជាបងប្អូននឹងគ្នាត្រូវតែរកវិធីណាមួយដើម្បីឲ្យឪពុករបស់យើងមកស្រលាញ្ជពួកយើងវិញ។* ជាបន្តបន្ទាប់បងប្អូនទាំង១០នាក់បានបន្តពិភាគសារជុំគ្នាដើម្បីរៃរកមធ្យោបាយ លួចកល់ផ្សេងៗដើមពង្រាត់យូសុះចេញពីឪពុក នឹងកែវភ្នែករបស់ពួកគេ ជាចុងក្រោយពួកគេបានឯកភាពគ្នាថា ត្រូវសម្លាប់យូសុះ ដូច្នោះក្នុងចំណោមពួកគេគឺ យ៉ាហុតហ្សា (ជាកូនទីបួននឹងជាកូនដែលមានគំនិតវែងធ្ងាយចេះដឹងជ្រៅជ្រះជាង

បងប្អូនផ្សេងទៀត) បាននិយាយថា៖ *ពួកយើងទាំងអស់គ្នាគឺជាកូនរបស់ណាពីយ៉ាកូប ដែលជាកូនរបស់ណាពីអ៊ីព្រហីម គឺជាខ្សែស្រឡាយដែលមានហាន:ខ្ពង់ខ្ពស់ ជាណាពី នឹងជាពូជអម្បូរដែលមនុស្សលោកគោរពស្រលាញ ដើតាមផ្លូវអល់ឡោះជាម្ចាស់ ជាពូជដែលមានគំនិតវែងឆ្ងាយមានការគិតត្រឹមត្រូវ នឹងមិនដែលធ្វើខុសឆ្គងនឹងសាសនារបស់អល់ឡោះបន្តិចណាឡើយ។ ដូច្នោះ.. ទង្វើសម្លាប់មនុស្សគឺជាការហាមឃាត់របស់អល់ឡោះ ហើយមនុស្សម្នាក់ៗដែលមានសតិគ្រប់គ្រាន់ក៏មិនអាចប្រព្រឹត្តណ៏នូវទង្វើបែបនោះបានដែ។ ដូច្នោះយើងមិនគួរគប្បីសំលាប់យូសុះនោះទេ ព្រោះយូសុះក៏ជាបងប្អូនមានឈាមជ័រខឹពុកតែមួយជាមួយពួកយើងផងដែ ទុះជាម្ចាយទីទែផ្សេងគ្នាក៏ដោយ ហើយកុំឲ្យយើងមានកំហុសខុស មានបាបកម្មធ្ងន់ធ្ងោនឹងអល់ឡោះ ទូសារនឹងឪពុករបស់យើង ខ្ញុំមានគំនិតមួយដ៏ល្អនឹងសុវត្តភាពបំផុតដែលពួកយើងទាំងអស់គ្នាអាចទទួលយកបាន គឺ យើងត្រូវរកអណ្តូងជ្រៅមួយដែលនៅជិតនឹងផ្លូវធ្វើដំណើរបស់មនុស្ស ចាប់យូសុះទំលាក់ក្នុងអណ្តូងនោះឲ្យរូបគេរស់ក្នុងអណ្តូងនោះ បើសិនជារូបគេមិនស្លាប់ មិនយូប៉ុន្មានក្រោយមកគង់មានមនុស្សម្នាដែលឆ្លងកាត់ទីកន្លែងនោះ ពួកគេនឹងជួបយូសុះ ហើយស្រង់យូសុះចេញពីក្នុងអណ្តូងនោះវិញ រួចពួកគេប្រាកដជានាំយូសុះទៅជាមួយ ដើម្បីរស់នៅជាមួយគេ រឺត្រូវលក់ធ្វើជាខ្ញុំបំរើរបស់គេ។ វិធីនេះពិតជាធ្វើឲ្យយូសុះនៅឃ្លាត់ឆ្ងាយពីឪពុករបស់ពួកយើង នឹងឆ្ងាយពីកែវភ្នែករបស់យើង ហើយកដូចបំណងប្រាថ្នារបស់ពួកយើងផងដែ។*

នៅយប់នោះផងដែ (មានអ្នកប្រវត្តិវិទូតស្លាមមួយចំនួនបាននិយាយថា ៣ថ្ងៃក្រោយមកបន្ទាប់ពីបងប្អូនយូសុះរៀបគម្រោងសម្លាប់យូសុះ) ខណៈយូសុះកំពុងដេកលង់លក់ក្នុងដំណេកយ៉ាងស្កប់ស្កល់នោះ យូសុះបានយល់សុបិនឃើញ មានលោកខែ និងព្រះអាទិត្យ នឹងមានផ្កាយចំនួន១១ដួង បានចុះពីលើមេឃ ហើយអោនស៊ូជូត (ក្រាប

ថ្វាយបង្គំ) ចំពោះយូសុះ។ ដូចប្រសាសន៍របស់អល់ឡោះមានពោលក្នុងគម្ពីរអាល់កូរអានក្នុងស៊ូរ៉ោះយូសុះ អាយ៉ាត់ 04 ថា៖

إِذْ قَالَ يُوسُفُ لِأَبِيهِ يَٰٓأَبَتِ إِنِّي رَأَيْتُ أَحَدَ عَشَرَ كَوْكَبًا
وَٱلشَّمْسَ وَٱلْقَمَرَ رَأَيْتُهُمْ لِي سَٰجِدِينَ ٤

មានន័យថា៖ នៅពេលដែលយូសុះបាននិយាយទៅកាន់បិតារបស់គេថា ឳបិតារបស់ខ្ញុំ! ពិតណាស់ ខ្ញុំបានឃើញ (ក្នុងសុបិន) មានផ្កាយចំនួន១១ដួង ព្រមទាំងព្រះអាទិត្យ និងចន្ទ្រា (ផ្កាយ) ខ្ញុំបានឃើញពួកវាស៊ូជូត (ក្រាប) មកចំពោះខ្ញុំ។

នៅពេលព្រឹកព្រលឹមស្រាងៗ យូសុះបានប្រញាប់ប្រញាលទៅដាស់ឪពុក (ណាពីយ៉ាកូប) ពីដំណេក ហើយបានរៀបរាប់ប្រាប់ដល់ឪពុកថា៖ *"ឪពុកជាទីស្រលាញ់របស់កូន .. កូនបានយល់សុបិនក្នុងដំណេករបស់កូន ឃើញមានលោកខែ ព្រះអាទិត្យ និងផ្កាយចំនួន១១ដួងបានក្រាបស៊ូជូតដល់រូបកូន កូនមិនដឹងថាតើសុបិនរបស់កូននេះនឹងមានន័យយ៉ាងដូចម្តេចនោះទេ តើសុបិននេះជាសុបិនការពិតរឺកជាសុបិនក្លែងក្លាយ សូមលោកឪពុកមេត្តាកាត់សុបិនរបស់កូនផង"*។ បន្ទាប់ពីណាពីយ៉ាកូបលឺដូច្នោះ យ៉ាកូបបានរៀបរាប់ប្រាប់យូសុះវិញថា៖ *"ឪកូនជាទីស្រលាញ់របស់ឪពុក.. ជាការពិតណាស់សុបិនរបស់កូនគឺមកពីអល់ឡោះជាម្ចាស់ ហើយកជាសុបិនដ៏រីករាយ ដែលអ្នកផ្សេងគ្មានភ័ព្វសំណាងវាសនានឹងទទួលបានឡើយ សុបិនរបស់កូនគឺជាដំណឹងយ៉ាងច្បាស់ថា អល់ឡោះបានចាត់តាំងរូបកូនធ្វើជាណាពី (ព្យាការី) របស់ទ្រង់ ដើម្បីដឹកនាំមនុស្សលោកឆ្ពស់ទៅរកភាពត្រឹមត្រូវ នឹងដឹកនាំសន្តិភាពជូនកពផែនដីរបស់ទ្រង់ ចំនេះដឹងនឹងភាពថ្លៃថ្នូរបស់កូន អល់ឡោះនឹងប្រទានដល់កូន កូននឹងមានឋានៈដ៏ខ្ពង់ខ្ពស់ ដែលមនុស្សលោកគោរពស្រលាញ់។ ចូរកូនកុំនិទានរៀបរាប់រឿងរ៉ាវសុបិនរបស់កូនប្រាប់ដល់បងប្អូនរបស់កូនទាំង១១នាក់ជាដាច់ខាត កូនត្រូវរក្សារការសុបិនរបស់កូនជាអាថ៌កំបាំង នឹង*

សំងាត់បំផុត ពីព្រោះពួកគេទាំង១១នាក់ហាបីដូចជាច្រណែនឈ្នានីសចំពោះរូបកូន នឹងប្អូនកូនពុនយ៉ាម៉ីន ដោយពុកបានដឹងយ៉ាងច្បាស់ពីមុនមកថា រូបកូននឹងក្លាយជាអ្នកដឹកនាំមនុស្សលោកបន្ទាប់ពីពុក ក្លាយជាណាពីរបស់អល់ឡោះនាថ្ងៃណាមួយជាក់ជាពុំខាន។ ពុកខ្លាចក្រែងថ្ងៃណាមួយ ប្រសិនបើបងប្អូនរបស់កូនទាំង១១នាក់បានដឹងអំពីព្រឹត្តិការសុបិនរបស់កូននេះ ពួកគេនឹងធ្វើបាបកូន សម្លាប់កូន ពីព្រោះហ្សែតន (ព្រួយបីសាច) និងមនុស្សលោកគឺជាសត្រូវនឹងគ្នា ពួកគេនឹងមិនធ្វើឲ្យរូបកូនមានសេចក្តីសុខឡើយ។

ពេលលឺប្រសាសន៍របស់លោកឪពុកយ៉ាងដូច្នោះ យូសុះបានសន្យាយល់ព្រមចំពោះលោកឪពុក ដោយមិននិទានរឿងរ៉ាវសុបិននោះប្រាប់នរណាម្នាក់ឡើយ ជាពិសេសបងប្អូនរបស់ខ្លួនទាំង១១នាក់ ហើយលាក់ទុកក្នុងចិត្តជាអាថ៌កំបាំងបំផុត។ ដូចអល់ឡោះបានមានបន្ទូលក្នុងគម្ពីអាល់កូរអាន ស៊ូរ៉ោះយូសុះ អាយ៉ាត់ទី 5-6 ថា៖

قَالَ يَٰبُنَيَّ لَا تَقۡصُصۡ رُءۡيَاكَ عَلَىٰٓ إِخۡوَتِكَ فَيَكِيدُواْ لَكَ كَيۡدًاۖ إِنَّ ٱلشَّيۡطَٰنَ لِلۡإِنسَٰنِ عَدُوّٞ مُّبِينٞ ٥ وَكَذَٰلِكَ يَجۡتَبِيكَ رَبُّكَ وَيُعَلِّمُكَ مِن تَأۡوِيلِ ٱلۡأَحَادِيثِ وَيُتِمُّ نِعۡمَتَهُۥ عَلَيۡكَ وَعَلَىٰٓ ءَالِ يَعۡقُوبَ كَمَآ أَتَمَّهَا عَلَىٰٓ أَبَوَيۡكَ مِن قَبۡلُ إِبۡرَٰهِيمَ وَإِسۡحَٰقَۚ إِنَّ رَبَّكَ عَلِيمٌ حَكِيمٞ ٦

មាននัយថា៖ លោកថា (យ៉ាកូប) ឱបុត្រារបស់យើង! ចូរកូនកុំនិទានសុបិននេះប្រាប់ទៅបងប្អូនរបស់កូន ពុំនោះទេ ពួកគេនឹងមានល្បិចកលធ្វើបាបកូន បង្កើតនូវល្បិចកលឈ្នានីស ។ ជាការពិតស្តែតនចំពោះពួកមនុស្សគឺជាសត្រូវជាមួយគ្នាពិតប្រាកដ ហេតុដូច្នេះហើយ ដែលម្ចាស់របស់កូននឹងជ្រើសរើសរូបកូន ហើយទ្រង់នឹងបង្រៀនកូនអំពីការកាត់សុបិនទាំងឡាយ ហើយលោកនឹងផ្តល់នូវឧបការគុណរបស់ទ្រង់ទៅលើកូន និងទៅលើក្រុមគ្រួសាររបស់យ៉ាក់កូប ដូចដែ លោកបានផ្តល់ឧបការគុណទៅលើបិតាទាំងពីរ

របស់កូនកាលពីមុន (អ៊ីព្រហ៊ីម និងអ៊ីស្ហាក) ជាការពិតម្ចាស់របស់កូន គឺជាអ្នកដែលដឹងជ្រៅបំផុត ថែមទាំងមហាគតិបណ្ឌិត។

មិនយូប៉ុន្មានក្រោយមក នាព្រឹកព្រលឹមស្រាងៗ បងប្អូនយូសុះទាំង១០នាក់បានភ្ញាក់ពីដំណេករៀងៗខ្លួន រៀបចំខ្លួនប្រាណយ៉ាងស្អាត នឹងបានត្រៀមនំចំណី អាហារជាស្រាប់ ហើយប្រមូលផ្តុំគ្នាទាំង១០នាក់ ដើម្បីទៅជួបយ៉ាកូបដែលជាឪពុករបស់ពួកគេ ដើម្បីសំការអនុញ្ញាតពីឪពុក នាំយូសុះទៅដើលេងកំហែកាយនៅឯព្រៃខាងក្រោយផ្ទះ។ ម្នាក់ក្នុងចំណោមពួកគេបាននិយាយទៅកាន់ឪពុកថា៖ *ឪពុកជាទីស្រលាញ់.. យើងខ្ញុំទាំងអស់គ្នាដែលជាកូនរបស់ពុក សុំការអនុញ្ញាតពីលោកឪពុកដើម្បីធ្វើដំណើរចេញទៅលំហែកាយនៅឯព្រៃខាងក្រោយផ្ទះ ដោយសុំអនុញ្ញាតពីលោកពុកដើម្បីនាំយូសុះទៅជាមួយផងដែ។* ពេលលឺដូច្នោះ ណាពីយ៉ាកូបបានឆ្លើយតបចំពោះកូនៗទាំង១០នាក់នោះវិញថា៖ *កូនៗជាទីស្រលាញ.. ពិតប្រាកដណាស់ យូសុះនៅតូច ដែលម្តាយគេទើបតែស្លាប់បាត់បង់ជីវិត ពុកមានការព្រួយបារម្ភណ៍ចំពោះសុវត្ថភាពយូសុះ ពុកភ្លាចមានករណីគ្រោះថ្នាក់ណាមួយកើតទ្បើងចំពោះយូសុះ ព្រោះនៅឯព្រៃខាងក្រោយផ្ទះនេះពោពេញដោយសត្វកាចសាហាវ អសេរពីស ជាពិសេសសត្វខ្លាចចក ពួកវាអាចបង្កគ្រោះថ្នាក់ដល់យូសុះគ្រប់ពេល។* ពេលនោះម្នាក់ក្នុងចំណោមពួកគេទាំង១០នាក់បានឆ្លើយតបសំដីរបស់ឪពុកវិញថា៖ *ពុកជាទីស្រលាញ់.. ពួកកូនៗទាំងអស់គ្នាសុទ្ធតែជាអ្នកមានកំលាំងខ្លាំងក្លា នឹងមានគំនិតគ្រប់គ្រាន់ ដើម្បីការពារសុវត្ថភាពជូនយូសុះ មិនឲ្យប្រការអាក្រក់ណាមួយកើតទ្បើងលើរូបរាងកាយរបស់យូសុះសូម្បីបន្តិចទ្បើយ។ យូសុះគឺជាដួងកែវភ្នែករបស់លោកឪពុក នឹងជាក្មេងកំព្រាម្តាយ ហើយកជាបងប្អូនរបស់ពួកយើងទាំងអស់គ្នាផងដែ ពួកយើងសុខចិត្តផ្តុំកាយផ្តុំឈាម ដើម្បីការពារសុវត្ថភាព*

ជូនយូសុះ រហូតយូសុះបានវិលត្រលប់មកកាន់ចំពោះមុខលោកពុកវិញនាពេលរសៀលមកដល់។

នៅពេលលឺដូច្នោះ យ៉ាកូបហាបីដូចទន់ចិត្ត ជឿជាក់ចំពោះការសន្យារបស់ពួកគេទាំង១០នាក់ ណាមួយដោយគិតថា យូសុះមិនដែលបានចេញទៅលំហែកាយផងដែនោះ ណាពីយ៉ាកូបបានសម្រេចចិត្តអនុញ្ញាតឲ្យយូសុះរួមដំណើជាមួយពួកគេទាំង១០នាក់ ដើម្បីចេញពីផ្ទះធ្វើដំណើឆ្ពស់ទៅកាន់ទីកន្លែងមួយឆ្ងាយពីផ្ទះក្នងគោលបំណងលំហែកាយ លេងសើចសប្បាយជាមួយបងប្អូនទាំង១០នាក់ផ្សេងទៀត ដោយណាពីយ៉ាកូបបាននិយាយទៅកាន់កូនៗទាំង១០នាក់នោះថា៖ *កូនៗជាទីស្រលាញ់.. ជាការពិតណាស់ ពុកអនុញ្ញាតឲ្យពួកកូនៗនាំយូសុះរួមដំណើជាមួយកូនៗ ដើម្បីចេញទៅលំហែកាយតាមការស្នើសុំ នឹងសន្យាថា នឹងថែរក្សាការពារយូសុះចាប់ពីពេលចេញពីផ្ទះរហូតយូសុះវិលត្រលប់មកផ្ទះវិញ ដោយសុវត្តភាពដូចការសន្យារបស់កូនៗ។*

យូសុះបានត្រៀមខ្លួនប្រាណ នឹងរៀបចំខោអាវតែតែរ៉ាន់ផ្សេងៗជាស្រាច់ ដើម្បីរួមដំណើជាមួយបងៗទាំង១០នាក់ផ្សេងទៀត លើកលែងពុនយ៉ាមុីន ដោយសារពុនយ៉ាមុីននៅតួច មិនអាចចូលរួមក្នងកម្មវិធីលំហែកាយរបស់បងៗបាន។ ពួកគេទាំង១១នាក់ប្រញ៉ាប់ប្រញ៉ាលចាកចេញពីផ្ទះ ឯចំនែកយូសុះ សើចសប្បាយឥតឈប់ឈរក្នងគ្រាកំពុងធ្វើដំណើតាមដងផ្លូវជាមួយក្រុមបងៗទាំង១០នាក់នោះ រហូតបានទៅដល់កន្លែងដែលពួកគេទាំង១០នាក់បានរៀបផែនការជាស្រាច់នោះ ដោយយូសុះមិនបានដឹង យល់អំពីល្បិចកល់ដ៏ពីសពុល សាហាវ របស់បងៗទាំង១០នាក់លើខ្លួននោះទេ យូសុះមិនបានគិតថា បងៗនឹងសម្លាប់ ធ្វើបាប រឺនឹងមានហេតុគ្រោះថ្នាក់អ្វីកើតឡើងចំពោះខ្លួនដែ ដោយសារភាពក្មេងខ្ចី ជឿទុកចិត្តលើបងៗទាំង១០នាក់ យូសុះគ្មានមន្ទិលសង្ស័យអ្វី

បន្តិចលើបងៗសោះទេ្បីយ។ មិនយូប៉ុន្មានក្រោយមក បន្ទាប់ពីពួកគេទាំង១០នាក់ទៅដល់ទីកន្លែងនោះ ពួកគេបានចាប់សម្រាតខោអាវយេសុះ ហើយចាប់លើកយេសុះទំលាក់ចូលក្នុងអណ្តូងជ្រៅហើយងងិតមួយដែលគ្មានទឹក តាមផែនការគ្រោងទុកកាលពីយប់មុនមក។ យេសុះមិនបានស្រែក មិនសួរនាំ មិនយំ ហើយក៏មិនបម្រាស់ខ្លួនសម្បីបន្តិចទេ្បីយ ព្រោះគិតថា អ្វីដែលបងៗកំពុងធ្វើនោះជាការលេងសើចសប្បាយតែប៉ុណ្ណោះ។

នៅពេលយេសុះបានធ្លាក់ដល់បាតអណ្តូងដែលគ្មានទឹក នឹងងងិតរកមើលអ្វីមិនឃើញនោះហើយ យេសុះបានស្រែកហៅសុំឲ្យបងៗជួយស្រង់ខ្លួនចេញពីអណ្តូងនោះវិញ តែទុះជាយេសុះខំស្រែក អង្វរករយ៉ាងណាក៏ដោយ ក៏គ្មានបងណាម្នាក់ជួយស្រង់យេសុះចេញពីអណ្តូងនោះដែ នៅពេលនោះទើបយេសុះដឹងខ្លួនថា នោះគឺជាគម្រោងរបស់ពួកគេទាំង១០នាក់ប៊ុនប៉ងសម្លាប់មកលើខ្លួន តែអ្វីៗបានហួសពេលទៅហើយ យេសុះបានត្រឹមតែសំងំក្នុងអណ្តូងដ៏ងងិតនោះ ហើយស្រែកឲ្យបងៗជួយបន្ត ប៉ុន្តែជាអកុសល្យពួកបងៗចិត្តខ្មៅទាំង១០នាក់នោះ បន្ទាប់ពីចាប់ទំលាក់យេសុះរួច ក៏ប្រញាប់ប្រញាលចាកចេញពីទីកន្លែងនោះ ឆ្ពស់ទៅកាន់រូងពពែរបស់ពួកគេវិញ ហើយបានសម្លាប់សត្វពពែមួយក្បាល ហែកខោអាវយេសុះនឹងបានយកឈាមពពែនោះលៀបលើខោអាវយេសុះ រួចពាំនាំខោអាវដែលប្រឡាក់ឈាមពពែនោះមកទួលពិតដល់ឪពុករបស់ពួកខ្លួន។ នាពេលរសៀលល្ងាចបន្តិច បន្ទាប់ពីសម្លាប់ពពែយកឈាមលៀបលើខោអាវយេសុះតាមផែនការណ៍ដែលគ្រោងទុករួចពួកគេទាំង១០នាក់បានចាកចេញពីទីកន្លែងនោះ ដោយធ្វើដំណើឆ្ពស់វិលត្រលប់ទៅផ្ទះវិញ នៅពេលដល់ផ្ទះ ពួកគេបានធ្វើជាយំសោកសម្រក់ទឹកភ្នែក ធ្វើទឹកមុខប្រាកបដោយទុក្ខព្រួយក្រៀមក្រំបំផុត ហើយក៏បានទូលប្រាប់ឪពុកថា៖ *ឪលោកឪពុកជាទីស្រលាញ.. អ្វីៗគ្រប់យ៉ាងដែលលោកពុកមានការព្រួយបារម្ភណ៍ចំពោះសុវត្តភាពយេសុះនោះ ពេលនេះវាបានក្លាយទៅជាការពិតទៅហើយ នៅពេល*

ដែលពួកយើងទាំង១០នាក់បានទៅដល់ទីកន្លែងមួយ ពួកយើងបានរត់ដេញប្រលែងចាប់គ្នាលេងយ៉ាងសប្បាយ ដោយទុកយូសុះចោលនៅទីកន្លែងនោះក្រោមដើមឈើមួយដើមជាមួយនឹងខោអាវ តវ៉ាន់ អូបអាហារ ដែលពួកយើងដាក់ទុក ពួកយើងមិនប្រុងប្រយ័ត្ន ភ្លេចខ្លួនដោយសារវល់រត់លេងសប្បាយ ស្រាប់តែមានចចកមួយក្បាលបានចាប់ខាំ ហែកសាច់យូសុះជាចំនែកៗ ហើយស៊ីធ្វើជាអាហារ ពួកយើងពិតជាមិនអាចជួយយូសុះបាន ហើយទាំងនេះគឺជាខោអាវយូសុះដែលប្រឡាក់ជោគដោយឈាមយូសុះ រហែកដោយសារចង្កូមរបស់ឆ្កែចចក។ លោកពុក.. កូនៗដឹងច្បាស់ថា លោកពុកពិតជាមិនជឿចំពោះដំណឹងដែលកូនៗបានរៀបរាប់ប្រាប់នេះទេ ប៉ុន្តែអ្វីៗទាំងអស់ដែលកូនៗនិយាយរៀបរាប់នេះគឺជាការពិត ហើយនេះគឺជាខោអាវរបស់យូសុះដែលប្រឡាក់ជោគដោយឈាមយូសុះ គឺជាភស្តុតាងយ៉ាងច្បាស់ដែលបញ្ជាក់ថា យូសុះត្រូវបានឆ្កែចចកស៊ីធ្វើជាអាហារ។ នៅពេលណាពីយ៉ាកូបបានលឺសំដីពួកគេទាំង១០នាក់ហើយ ណាពីយ៉ាកូបស្រក់ទឹកភ្នែក សោស្តាយ នឹងស្រណោះចំពោះយូសុះ នឹងចំពោះការសម្រេចចិត្តរបស់ខ្លួន ដែលអនុញ្ញាតឲ្យយូសុះរួមដំណើជាមួយពួកគេទាំង១០នាក់នោះ ប៉ុន្តែដោយការសពើរ (អត់ធ្មត់) នឹងចាត់ទុកថា អ្វីៗគឺជាការកំណត់របស់អល់ឡោះដែលមនុស្សម្នាក់ៗមិនអាចប្រកែកនឹងជៀសបាន ណាពីយ៉ាកកូបបានឆ្លើយទៅកាន់ពួកគេទាំង១០នាក់នោះវិញថា៖ *ជាការពិតណាស់ ពួកអ្នកបានប្រព្រឹត្តិនូវអ្វីៗតាមចិត្តរបស់ពួកអ្នកដោយមិនបានពិចារណាគិតវែងឆ្ងាយ អនុវត្តន៍តាមការអូសទាញរបស់ហ្សៃតន យើងដឹងច្បាស់អំពីចិត្តនឹងអកប្បកិរិយារបស់ពួកអ្នក យើងនិងអនុគ្រោះដល់ពួកអ្នកបើសិនជាពួកអ្នកមិនបានធ្វើពិតមែនៗ* ដូចអល់ឡោះបានមានបន្ទូលក្នុងគម្ពីរអាល់កូរអានថា៖

قَالُوا۟ يَـٰٓأَبَانَآ إِنَّا ذَهَبْنَا نَسْتَبِقُ وَتَرَكْنَا يُوسُفَ عِندَ مَتَـٰعِنَا فَأَكَلَهُ ٱلذِّئْبُ ۖ وَمَآ أَنتَ
بِمُؤْمِنٍ لَّنَا وَلَوْ كُنَّا صَـٰدِقِينَ ﴿١٧﴾ وَجَآءُو عَلَىٰ قَمِيصِهِۦ بِدَمٍ كَذِبٍ ۚ قَالَ بَلْ سَوَّلَتْ لَكُمْ
أَنفُسُكُمْ أَمْرًا ۖ فَصَبْرٌ جَمِيلٌ ۖ وَٱللَّهُ ٱلْمُسْتَعَانُ عَلَىٰ مَا تَصِفُونَ ﴿١٨﴾

មាននំយថា៖ ពួកគេ (កូនៗយ៉ាកូបទាំង១០នាក់) ថា ឱបិតារបស់ពួកយើង ពួកយើង បានធ្វើដំណើរទាំងរត់លេងជាមួយគ្នា ហើយពួកយើងបានទុកយូសុះនៅទីកន្លែងមួយជិត ឥវ៉ាន់របស់ពួកយើង ក្រោយមកសត្វចចកក៏បានស៊ីវា។ ហើយពួកយើងជឿថា បិតាមិន ជឿនូវអ្វីដែលពួកយើងរៀបរាប់ប្រាប់ទេ ទោះបីជាពួកយើងគឺជាអ្នកដែលទៀងត្រង់ក៏ដោយ។ (18) ហើយពួកគេក៏បាននាំមកជាមួយអាវរបស់យូសុះ ដែលប្រឡាក់ដោយឈាមប្រឌិត។ យ៉ាកូបនិយាយថា ទេ! ការពិត គឺពួកអ្នកបានរៀបចំផែនការឲ្យពួកអ្នកនូវគម្រោងការមួយ។ ហេតុដូច្នេះ ការអត់ធ្មត់គឺជាការល្អបំផុត ។ ហើយអល់ឡោះគឺជាអ្នកដែលត្រូវគេសុំជំនួយនូវអ្វីដែលពួកអ្នកកំពុងតែរៀបរាប់។

យូសុះនៅក្នុងអណ្តូង

រយៈពេល៣ថ្ងៃក្រោយមក ដែលយូសុះរស់នៅក្នុងអណ្តូងដ៏ងងឹតនោះ យូសុះបានលឺសូ

សម្លេងចម្លែកមួយចេញពីខាងលើអណ្តូង ដោយសម្លេងនោះ ខ្លះលឺដូចជាសម្លេងសត្វពាហនៈបន្តិច ជាសម្លេងមនុស្សនិយាយគ្នាបន្តិច នឹងមានសម្លេងដូចជាខ្យល់បក់បន្តិច យូសុះមានអារម្មណ៍ភ័យក្លាចកាន់តែខ្លាំងឡើងៗ ដោយសារយូសុះ

ធ្លាប់បាននិទានប្រាប់ពីឪពុកថា នៅទីកន្លែងដែលយូសុះទៅលេងនោះមានខ្លា ឆ្កែចចក
នឹងសត្វពីសគ្រប់ប្រភេទ ហើយសត្វទាំងនោះអាចសម្លាប់ធ្វើបាបយូសុះបានគ្រប់ពេល
ដោយសារយូសុះនៅតូច គ្មានលទ្ធភាពដើម្បីតតាំងជាមួយសត្វសាហាវទាំងអស់នោះ។
អ្វីដែលជាការពិតនោះ សម្លេងទាំងនោះគឺជាសម្លេងជើងសត្វអូដ្ឋ នឹងសម្លេងនិយាយ
ពិភាគសារគ្នារបស់ក្រុមអ្នកធ្វើដំណើរប្រកបមុខរបរជំនួយអេហ្សិបមួយក្រុម ដែលឈប់
សម្រាក់នៅត្រង់កន្លែងនោះ ដើម្បីស្វែងរកទឹកផឹកសំរាប់ពួកគេនឹងសត្វដំណើរបស់ពួក
គេផងដែ។ ពេលនោះ ថៅកែ (រឺមេក្រុម) ម្នាក់ក្នុងចំណោមពួកជំនួយអេហ្សិបទាំងអស់
នោះ បានបញ្ជាឲ្យកូនឈ្នួលរបស់ខ្លួនទម្លាក់យោងចូលក្នុងអណ្តូងនោះដើម្បីដងទឹក
ប៉ុន្តែពួកគេមិនដឹងថាក្នុងអណ្តូងនោះរឹងគ្មានទឹកនោះទេ ព្រោះក្នុងអណ្តូងនោះងងឹត
ហើយជ្រៅដែលមើលអ្វីមិនឃើញ។ ពេលនោះយូសុះបានសម្លឹងមើលខាងលើ ក៏ប្រទះ
ឃើញមានយោងដងទឹកមួយចុះក្រោម ហើយគិតថា នោះគឺជាជំនួយពីបងប្អូនរបស់គេ
រឺជាឪពុករបស់ខ្លួនមកជួយស្រង់ចេញអណ្តូងវិញ យូសុះបានស្ទុះចាប់យោងនោះ
ហើយអង្គុយពីលើ ពេលនោះអ្នកជំនួញរូបនោះបានទាញយោងនោះឡើងលើវិញព្រោះ
នឹកគិតថាវាគឺជាទឹក ប៉ុន្តែពេលដល់លើ ធ្វើឲ្យពួកគេម្នាក់ៗធ្វើភ្នែកធំៗ នាំគ្នាភ្ញាក់ព្រឺត
ដោយនឹកស្មានមិនដល់ថា អ្វីដែលពួកគេដងឡើងលើនោះ គឺជាក្មេងប្រុសម្នាក់ដែល
មានមុខមាត់ស្អាតល្អ សែ្បកសថ្លា ផ្នែកមូលក្រឡង សក់រួញអង្គាជិ សមស្មួនជាក្មេងជា
ទីស្រលាញ្ជគ្មានពីរលើលោកទៅវិញ។ ក្រោយមកពួកគេបានផ្តល់ចំណីអាហារបន្តិច
បន្តួចដល់យូសុះនឹងបានសួរនាំយូសុះអំពីប្រវត្តិឪពុកម្តាយ ទីកន្លែងរស់នៅ។ល។ ប៉ុន្តែ
យូសុះមិនអាចរៀបរាប់ប្រាប់បាន ដោយសារតាំងពីកើតមកយូសុះមិនដែលចាកចេញពី
ផ្ទះ ឃ្លាតពីលោកឪពុកម្តងណាទេ្បីយ ហើយកជាលើកទីមួយដែលយូសុះឃ្លាតឆ្ងាយពី
ក្រុមគ្រួសារ និងឪពុកជាទីស្រលាញ្ជនោះ យូសុះមិនដឹងថា តើផ្ទះរបស់ខ្លួននៅឯណា

ឈ្មោះភូមិអ្វីនោះទេ។ ឃើញដូច្នោះ ក្រុមអ្នកជំនួញអេហ្សីបទាំងអស់នោះ បានសម្រេចចិត្តនាំយូសុះទៅជាមួយឯប្រទេសអេហ្សីបតែម្តង។

នៅតាមដងផ្លូវឆ្ពស់ទៅកាន់ទីប្រជុំជនមួយ ពេលកំពុងធ្វើដំណើរពួកអ្នកជំនួយអេហ្សីបទាំងអស់នោះបានធ្វើដំណើរបណ្តើ និងបានពិភាគសារគ្នាបណ្តើ ដោយដងដែកអំពើរឿងរ៉ាវយូសុះ មានម្នាក់ក្នុងចំណោមពួកគេនិយាយថា៖ ខ្ញុំនឹងទទួលចញ្ចឹមកុមារម្នាក់នេះដូចជាកូន នឹងផ្តល់សេចក្តីសុខគ្រប់បែបយ៉ាងដល់គេ ព្រោះកុមារម្នាក់នេះមើលទៅពិតជាគួរឲ្យស្រលាញ់នឹងអាណិតអាស្សូបំផុត។ អ្នកខ្លះទៀតនិយាយថា៖ កុមារម្នាក់នេះគឺជាក្មេងដែលយើងរើសបានទាំងអស់គ្នា ដូច្នោះពួកយើងទាំងអស់គ្នានឹងចិញ្ចឹមគេឲ្យធំធាត់ពេញវ័យ ពេលនោះយើងប្រើប្រាស់រូបគេធ្វើជាអ្នកជំនួយជុសមុខឲ្យពួកយើង។ ឯចំនែកអ្នកផ្សេងទៀតនិយាយថា៖ យើងត្រូវលក់ក្មេងម្នាក់នេះនាពេលទៅដល់ទីប្រជុំខាងមុខ យើងនឹងចែកប្រាក់គ្នាឲ្យស្មើភាពតាមចំនួនតំលៃដែលយើងលក់បាន។ ជាចុងក្រោយពួកគេបានឯកភាពមូលមតិគ្នាថា នឹងលក់យូសុះឲ្យទៅបុគ្គលណាម្នាក់ដែលស្នាក់ចិត្តទិញយូសុះ ទុះជាក្នុងបំនងយកទៅចិញ្ចឹមរឺធ្វើជាខ្ញុំបំរើ រឺធ្វើជាទស្សករណ៍របស់អ្នកនោះកដោយ។

យូសុះត្រូវបានគេជាក់លក់



មិនយូប៉ុន្មានក្រោយមក ពួកអ្នកជំនួយទាំងអស់នោះបានទៅដល់ទីបរដ្ឋជំនួយក្នុងប្រទេសអេហ្សីប ពួកគេបានប្រកាស់ជាក់លក់យូសុះនៅទីប្រជុំជនមួយកន្លែងនោះ

ក្នុងតំលៃថ្លៃ ប៉ុន្តែគ្មាននរណាទិញយូសុះនោះទេ ចុងក្រោយមានបុរសម្នាក់ដែលជាអ្នក
មានទ្រពម្បត្តិស្តុកស្តុំ មានទួនាទីជានាយសន្តិសុខក្នុងប្រទេសអេហ្សីបទាំងមូលឈ្មោះ
ហ្វាត់ហីហ្វើរ បានទិញយូសុះពីពួកគេវិញក្នុងតំលៃត្រឹមតែប៉ុន្មានទៀរហាំ (ឈ្មោះប្រាក់
អារ៉ាប់) តែប៉ុណ្ណោះ។ ហ្វាត់ហីហ្វើរ លោកគឺជាបុគ្គល់ម្នាក់ដែលមានកេរ៍ឈ្មោះល្បី
ល្បាញ កត្តិយសខ្ពង់ខ្ពស់ នឹងជាអ្នកមានទាំងទ្រពសម្បត្តិនឹងអំណាចផងដែ លោក
មានភរិយាម្នាក់ឈ្មោះ យ៉ូញ៉ា (ស៊ូឡែខ)។ នាងស៊ូឡែខគឺជានារីវ័យក្មេងម្នាក់ដែល
មានរូបសម្រស់ស្រស់ស្អាតភ្លឺភ្លង់ជាច់គេជាងនារីផ្សេងៗនៅក្នុងតំបន់នោះ ស៊ូឡែខគឺជា
ភរិយាដែលលោកហ្វាត់ហីហ្វើរស្រលាញ់ខ្លាំងបំផុត លោកហ្វាត់ហីហ្វើរ មិនដែលធ្វើអ្វី
ទាស់ចិត្តភរិយាទ្បើយ លោកបានផ្តល់សេចក្តីសុខគ្រប់យ៉ាងជូនស៊ូឡែខ ទាំងការរស់
នៅ ទ្រពសម្បត្តិ នឹងកេរ៍ឈ្មោះ។

នាពេល ហ្វាត់ហីហ្វើរ បានទិញយូសុះពីអ្នកជំនួញនោះរួច លោកបាននាំយូសុះទៅផ្ទះ
របស់លោក ហើយប្រគល់យូសុះជូនភរិយារបស់លោក ស៊ូឡែខ ដោយលោកបាន
និយាយថា៖ *ឱប្រពន្ធជាទីស្រលាញ.. នេះគឺជាក្មេងប្រុសម្នាក់ដែលខ្ញុំបានទិញពីពួកអ្នក
ជំនួញមួយក្រុម ហើយខ្ញុំយកក្មេងប្រុសម្នាក់នេះប្រគល់ជូនអ្នក ដើម្បីជួយមើលការខុស
ក្នុងគ្រួសារ នឹងប្រើប្រាស់នៅពេលដែលយើងចង់ប្រើ។ សូមជួយរៀបចំបន្ទប់មួយដ៏សម
រម្យ នឹងប្រដាប់ប្រដារប្រើប្រាស់ផ្សេងៗសម្រាប់ក្មេងម្នាក់នេះផង។* នាងស៊ូឡែខ បាន
រៀបចំនឹងអនុវត្តន៍តាមសំដីប្តីរបស់ខ្លួន ដោយបានរៀបចំបន្ទប់មួយយ៉ាងស្អាត មានស
ម្លៀកបំពាក់ ខោអាវ ប្រដាប់ប្រដារប្រើប្រាស់ផ្សេងៗជូនយូសុះ។ ចាប់ពីពេលនោះមក
ទាំងហ្វាត់ហីហ្វើរ នឹង ស៊ូឡែខ មិនដែលចាត់ទុកយូសុះគឺជាខ្ញុំបំរើដាច់ថ្លៃនោះទេ
ពោល ចាត់ទុកជាសមាជិកម្នាក់ក្នុងក្រុមគ្រួសារ ក្នុងចំណោមពួកគេផងដែ។ យូសុះ
រីករាយនឹងរស់នៅជាមួយពួកគេ មិនដែលលំបាករឺទាស់ចិត្តកន្លែងណាឡើយ ពីមួយថ្ងៃ
ទៅមួយថ្ងៃ ដោយយូសុះមានអាយុកាន់តែច្រើន ចំនេះដឹងការស្វែងយល់កាន់តែច្រើន

ដោយសារភាពបិនប្រសប់របស់យូសុះ ភាពស្លូតបូតទៀងត្រង់របស់យូសុះ បានធ្វើឲ្យ ហ្វាត់ហីហ្វើរ នឹងនាងស៊ូឡែខកាន់តែស្រលាញ់ខ្លាំងឡើងៗ នឹងមានទំនុកចិត្ត ទាំងស្រុងចំពោះយូសុះ។

យូសុះធំធាត់ពេញវ័យ

មិនយូប៉ុន្មាន ពោល ប៉ុន្មានឆ្នាំបន្ទាប់ យូសុះកធំធាត់ពេញវ័យ ពេញកម្លោះ គ្រប់អាយុ (بالغ) សម្រស់យូសុះកាន់ស្រស់សង្ហាឡើងៗ ទន្ទឹមនឹងភាពទន់ភ្លន់ ចិត្តគំនិតចាស់ទំ នឹងស្រស់សង្ហាគ្មានបុរសណាប្រៀបប្រដូចនោះ នាងស៊ូឡែខ បានចាប់ផ្តើមមានចិត្ត ប្រតិព័ត្តិចំពោះយូសុះ លួចស្រលាញ្ញយូសុះ ពេញចិត្តពេញថ្លើម រហូតធ្វើអោយនាង ហ៊ានក្បត់នឹងប្តីរបស់ខ្លួនដែលជាអ្នកផ្តល់អ្វីៗគ្រប់យ៉ាង ទាំងទ្រពសម្បត្តិ សេចក្តីសុខ នឹងកេរ៍ឈ្មោះ ។ល។ ជូននាង។ ពីមួយថ្ងៃទៅមួយថ្ងៃ ក្នុងកែវភ្នែកទាំងគូររបស់នាងស៊ូ ឡែខចំពោះយូសុះ ហបីដូចស្រលាញ្ញនឹងពេញចិត្តពេញថ្លើមកាន់តែខ្លាំងឡើងៗ រហូត ធ្វើឲ្យនាងស៊ូឡែខទ្រាំមិនបាន សម្រេចចិត្តសារភាពស្នេហ៍ត្រង់ៗចំពោះមុខយូសុះ ដោយនាងបាននិយាយថា៖ *“ឪយូសុះ.. ជាការពិតណាស់ ខ្ញុំសុខចិត្តសារភាពចំពោះ អ្នកទាំងបំពានដែលជាស្ត្រីម្នាក់ដែលមានប្តីរួចហើយ ខ្ញុំពិតជាស្រលាញ់អ្នកនឹងពេញ ចិត្តរាល់ទង្វើ កាយវិការ នឹងអកប្បកិរិយារបស់អ្នក”*។ បន្ទាប់ពីយូសុះបានលឺនូវ សារភាពរបស់ស៊ូឡែខរួច យូសុះបានឆ្លើយប្រាប់នាងស៊ូឡែខវិញថា៖ *“ឪចៅហ្វាយស្រី របស់ខ្ញុំ.. រូបខ្ញុំគ្រាន់តែជាអ្នកបំរើម្នាក់ដើម្បីជួយរៀបចំ នឹងបំរើអ្នកទាំងអស់គ្នាក្នុងក្រុម គ្រួសារនេះ ខ្ញុំពិតជាមិនអាចទទួលយកតាមសំណូមពររបស់ចៅហ្វាយស្រីបានឡើយ ចៅហ្វាយស្រីមានប្តីម្នាក់ដែលល្អ ជាមេដឹកនាំមនុស្សទាំងឡាយ នឹងមានទ្រពសម្បត្តិ នឹងអ្វីគ្រប់យ៉ាងសំរាប់អ្នក ហើយក៏ជាអ្នកផ្តល់សេចក្តីសុខស្លាម៉ាត់ដល់រូបខ្ញុំផងដែ*

ដូច្នោះខ្ញុំពិតជាមិនអាចធ្វើនូវរឿងដ៏អាម៉ាស់ មិនគប្បីនឹងចៅហ្វាយប្រុសចៅហ្វាយស្រីបានឡើយ”។

ស៊ូឡែខចាប់យូសុះ



ជាការពិតណាស់ ក្នុងចិត្តរបស់នាងស៊ូឡែខ នៅតែមានចិត្តគំគួនប្រតិព័ត្តិស្រលាញ្រពេញចិត្តចំពោះយូសុះដដែល មិនតែប៉ុណ្ណោះពីមួយថ្ងៃទៅមួយថ្ងៃកាន់តែធ្វើឲ្យចិត្តរបស់នាងស៊ូឡែខមានចិត្តស្រលាញ្រចំពោះយូសុះមិនអាចកាត់ផ្តែងបាន។ ដោយហេតុតែស្រលាញ់ ពេញចិត្តពេញថ្លើមដកចិត្តពុំរួច មិនយូប៉ុន្មានក្រោយមក នាងស៊ូឡែខ បានរៀបផែនការណ៍មួយដើម្បីចាប់បង្ខំយូសុះ នឹងសារភាពត្រង់ៗចំពោះមុខយូសុះ បញ្ជាក់ពីក្តីស្រលាញ្រប់ស់នាងចំពោះយូសុះដែលមិនអាចហាមឃាត់ចិត្តបាននោះដាលើកទីពីរម្តងទៀត។ មានថ្ងៃមួយនាងស៊ូឡែខ បានហៅយូសុះចូលក្នុងបន្ទាប់របស់នាងដូចរាល់ដង នាពេលដែលនាងត្រូវការអ្វីម៉្យាងឲ្យយូសុះធ្វើ រីឯយនាង ពោល គឺនៅពេលដែលនាងត្រូវការប្រើយូសុះ។ នាថ្ងៃមួយ ពេលប្តីរបស់នាងចេញពីផ្ទះបាត់ ពេលនោះស៊ូឡែខបានហៅយូសុះឲ្យចូលក្នុងបន្ទាប់របស់នាង យូសុះបានលឺសម្លេងហៅរបស់ស៊ូឡែខ យូសុះក៏ប្រញ៉ាប់ប្រញាលចូលក្នុងបន្ទប់របស់ស៊ូឡែខ ដើម្បីសួរនាំ ប៉ុន្តែស៊ូឡែខវិញបានស្ទុះទៅបិទទ្វា បិទបង្ហួច ហើយចាក់សោគន្លឹះទ្វានោះមិនឲ្យយូសុះចេញក្រៅបាន ពេលនោះស៊ូឡែខបាននិយាយទៅកាន់យូសុះថា៖ *ឱយូសុះ.. តើអ្នកបានដឹងដែរឬទេថា*

ខ្ញុំពិតជាមិនអាចទ្រាំមើលសម្រស់របស់អ្នក កាយវិការ នឹងអកប្បកិរិយារបស់អ្នកបានទៀតទេ ខ្ញុំនឹងប្រគល់អ្វីៗគ្រប់យ៉ាងទាំងខ្លួនរបស់ខ្ញុំ ចិត្តរបស់ខ្ញុំ នឹងអ្វីដែលខ្ញុំមានជូនទៅអ្នក បើសិនជាអ្នកព្រមរួមរស់ជាមួយខ្ញុំ (រួមរ័ក្ខ)។ សូមអ្នកកុំបដិសេធចំពោះក្តីស្រីលាញ្ញ នឹងសារភាពរបស់ខ្ញុំចំពោះអ្នក សូមអ្នកព្រមចុះ ហើយខ្ញុំនឹងនៅ (ដេក) ជាមួយអ្នកក្នុងពេលនេះ។ នៅពេលលឺដូច្នោះ យូសុះបានស្ទុះទៅទ្វាហើយព្យាយាមបើកទ្វាដើម្បីរត់គេចខ្លួនពីស៊ូឡែខ បុន្តែមិនបានសម្រេចនោះទេ ដោយសារស៊ូឡែខបានចាក់សោទ្វាជាប់មិនអាចបើកបាន ពេលនោះយូសុះបាននិយាយឆ្លើយតបទៅកាន់ស៊ីឡែខវិញថា៖ *ម៉ែចៅហ្វាយស្រីជាទីគោរព.. ខ្ញុំពិតជាមិនអាចក្បត់នឹងខ្លួនឯង ចៅហ្វាយប្រុសជាពិសេសនឹងអល់ឡោះរបស់ខ្ញុំបានឡើយ ខ្ញុំមិនអាចធ្វើតាមមាគ៌ារបស់ហ្សែតន (ព្រោយបីសាច) បានឡើយ បើសិនជារូបខ្ញុំព្រមប្រព្រឹតណ៌តាមការស្នើសុំ លួងលោមរបស់អ្នក នោះពិតប្រាកដណាស់ខ្ញុំពិតជានៅក្នុងចំណោមពួកអ្នកដែលដើរលើផ្លូវខុសដ៏ធ្ងន់ធ្ងា។* ពេលនិយាយរួចហើយ យូសុះបានស្ទុះទៅទ្វាជាលើកទីពីរដើម្បីបើកទ្វារត់ ពេលនោះនាងស៊ូឡែខបានស្ទុះចាប់យូសុះបង្ខំឲ្យរួមរ័ក្ខជាមួយខ្លួនតាមតណ្ហាដែលខ្លួនមាន យូសុះខំប្រឹងរើបម្រាស់ ឯស៊ូឡែខវិញចាប់ទាញអាវយូសុះផ្នែកខាងក្រោយរហូតបណ្តាលឲ្យអាវរបស់យូសុះដែលកំពុងពាក់នោះ រហែកជាចំនែកៗ។

ការប្រតាយប្រតប់អ្នកទាំងពីរនៅជិតទ្វាក្នុងបន្ទប់នាងស៊ូឡែខរហូតលឺដល់ខាងក្រៅ គាប់ជួនពេលនោះប្តីរបស់ស៊ូឡែខ លោក ហ្វាត់ហីហ្វីរ បានមកដល់ល្មមក៏ឃើញអ្នកទាំងពី (យូសុះ នឹងស៊ីឡែខ) កំពុងប្រតាយប្រតបគ្នាចាប់ទាញគ្នា ពេលឃើញហេតុការដូច្នោះ លោក ហ្វាត់ហីហ្វីរ បានសួរថា៖ *តើមានរឿងអ្វីកើតឡើងចំពោះអ្នកទាំងពីរ?* ស៊ូឡែខប្រញាប់ឆ្លើយតបសំនួររបស់ប្តីវិញថា៖ *ជាការពិតណាស់ នេះហើយគឺជាខ្ញុំបំរើបស់អ្នក ដែលអ្នកតែងតែស្ងើចសសើថា យូសុះជាក្មេងដែលល្អ ទៀងត្រង់ ស្លូត*

បូត នឹងមានការពិចារណាត្រឹមត្រូវនោះ។ ស៊ូឡែខបានបន្ថែមថា៖ *មុននេះបន្តិចយូសុះបានលួចចូលក្នុងបន្ទាប់របស់ខ្ញុំខណៈពេលដែលខ្ញុំកំពុងគេងលង់លក់ គេបានព្យាយាមចាប់ខ្ញុំរំលោភប៉ុន្តែខ្ញុំបានរើបម្រាស់ រហូតបានក្លាយជាហេតុការណ៍មួយដូចដែលអ្នកបានឃើញក្នុងគ្រានេះអញ្ចឹង សូមអ្នកចាប់យូសុះហើយផ្តល់ទាទោសដល់រូបគេ ឲ្យសមនឹងទង្វើដែលគេធ្វើមកលើរូបខ្ញុំចុះ។* នៅពេលដែលស៊ូឡែខនិយាយចប់ លោក ហ្វាត់ហីហ្វើរ បានសួរនាំយូសុះអំពីរឿងរ៉ាវដែលកើតឡើងនោះ យូសុះបាននិយាយប្រាប់ចៅហ្វាយរបស់ខ្លួន ហ្វាត់ហីហ្វើរ ថា៖ *ពិតណាស់ចៅហ្វាយ.. ខ្ញុំមិនដែលប្រព្រឹត្តណ៍ទង្វើអាក្រក់ណាមួយដែលក្បត់នឹងចៅហ្វាយ ខ្លួនឯង រឺអល់ឡោះឡើយ ខ្ញុំតែងតែគោរពប្រណិបត្តិចំពោះចៅហ្វាយទាំងពីរ អ្នកទាំងពីរគឺជាមនុស្សដែលមានគុណបំណាច់ដ៏លើសលប់មកលើរូបខ្ញុំ គឺជាឪពុកគឺជាម្តាយដូចជាឪពុកម្តាយបង្កើតរបស់ខ្ញុំផងដែលើសពីនេះទៅទៀត ខ្ញុំពិតជាមិនអាចក្បត់រឺប្រព្រឹត្តិណ៍អំពើណាមួយដែលផ្ទុយពីមាគាវ៌របស់អល់ឡោះបានឡើយ អល់ឡោះទ្រង់មហាសេនដឹងរវាងអ្នកខុសនឹងអ្នកត្រូវ។* សម្តីរបស់យូសុះធ្វើឲ្យលោក ហ្វាត់ហីហ្វើរ ពិបាកក្នុងការបែងចែករវែកញែករកខុសត្រូវជួនពួកគេទាំងពីរ ព្រោះពីមុនមក លោកជឿទុកចិត្តទាំងស្រុងចំពោះយូសុះ ហើយយូសុះក៏មិនធ្លាប់ដែលធ្វើទង្វើណាមួយដែលបណ្តាលឲ្យចៅហ្វាយរបស់ខ្លួនថ្នាក់ថ្នាំងចិត្ត ស្អប់ រឺមិនគប្បីនោះដែ ហើយលោកក៏ដឹងយ៉ាងច្បាស់ផងដែថា វាមិនមែនជាកំហុសរបស់យូសុះនោះទេ គឺជាការទំលាក់កំហុសទាំងស្រុងទៅលើយូសុះ។ នៅគ្រានោះ ដោយហេតុមានការសុំជួយវិភាគរបស់លោក ហ្វាត់ហីហ្វើរ ដល់បុរសម្នាក់ (ត្រូវជាជីដូនមួយនឹងស៊ូឡែខ ហើយកជាអ្នកមានការវិភាគត្រឹមត្រូវផងដែ) ដែលជាអ្នកមើលការខុសត្រូវក្នុងផ្ទះរបស់លោក នឹងជាអ្នកទទួលចាត់ចែងរាល់ការងាររបស់លោកផងដែនោះ លោក ហ្វាត់ហីហ្វើរ បានសួរទៅកាន់បុរសនោះថា៖ *តើលោកយល់យ៉ាងណាដែចំពោះរឿងរ៉ាវដែលកើតឡឺងរវាងយូសុះនឹងស៊ូឡែខនេះ?* បុរសម្នាក់នោះបានឆ្លើយយ៉ាងខ្លីថា៖ *បើ*

សិនជាអាវរបស់យូសុះរហែកផ្នែកខាងមុខ នោះពិតប្រាកដណាស់ យូសុះជាអ្នកចាប់រំលោភស៊ូឡែខ តែបើសិនជាអាវរបស់យូសុះរហែកខាងក្រោយ គឺស៊ូឡែខជាអ្នកចាប់បង្ខំយូសុះរំលោភ។ ជាចុងក្រោយ ដោយហេតុតែស្រលាញ់ស៊ូឡែខខ្លាំងពេក ម៉្យាងវិញទៀតអានិតស្រលាញ់យូសុះដែលជាក្មេងល្អអាចទុកចិត្តបាននោះ លោក ហ្វាត់ហីហ្វីរ មិនបានដឹកឫសដឹកគល់សួរនាំរកខុសត្រូវបន្តទៀតនោះទេ ហើយសុំឲ្យបញ្ចប់រឿងរ៉ាវត្រឹមពេលនោះ ដោយសំណូមពរដល់អ្នកដែលដឹងលឺរឿងរ៉ាវហេតុការណ៍នោះ សំឲ្យកំនិយាយប្រាប់អ្នកផ្សេង ដែលជាហេតុធ្វើឲ្យអាប់អោនកិត្តិយសរបស់លោក ហើយខ្មាស់គេផងដែ។

ពិតណាស់ ហ្សែតននឹងមនុស្សគឺជាសត្រូវនឹងគ្នា មនុស្សម្នាក់ៗបើបានដឹងលឺអំពីរឿងរ៉ាវអាស្រូវរបស់គេហើយប្រាកដជានៅមិនសុខឡើយ យូនឹងធាប់រឿងអាស្រូវនោះគង់នឹងធ្លាយដល់គេឯង.. ដូច្នោះដែរឿងរ៉ាវអាស្រូវរបស់យូសុះ នឹងនាងស៊ីឡែខ ក៏បានជ្រាបលិចលឺដល់បណ្តាស្ត្រីដែលជាអ្នកមានមុខមាត់ ជាពិសេសភរិយារបស់មន្ត្រីផ្សេងៗទៀតក្នុងប្រទេសអេហ្ស៊ីប ដែលស្គាល់នាងស៊ូឡែខ។ ដំណឹងនោះបានធ្វើឲ្យស៊ូឡែខប្រឈមមុខនឹងក្តីអាម៉ាស់យ៉ាងខ្លាំងរកអ្វីថ្លែងពុំបាន ស៊ូឡែខបានសំងំលាក់ខ្លួនក្នុងផ្ទះមិនដែលចេញទៅណាមកណាឡើយ ឯចំនែកយូសុះវិញមិនបានដឹងអ្វីបន្តិចសោះ រស់នៅក្នុងផ្ទះហ្វាត់ហីហ្វីរ ខំប្រឹងធ្វើការទាំងថ្ងៃទាំងយប់តាមធម្មតា។ មានថ្ងៃមួយ ដោយពត៌មាននោះបានលិចលឺតៗគ្នាពីមាត់មនុស្សម្នាក់ទៅមនុស្សម្នាក់ លិចលឺសុះសាយហើយភាពអាម៉ាស់កាន់តែខ្លាំងឡើងៗ ហើយដើម្បីរក្សារកេរ៍ឈ្មោះរបស់ខ្លួន ស៊ូឡែខបានសំឲ្យប្តីរបស់ខ្លួនហ្វាត់ហីហ្វីរ ចាប់យូសុះដាក់ឃុំឃាំងហើយផ្តល់ទាទោសចំពោះយូសុះជាលើកទីពីរ ដើម្បីបញ្ជាក់ថា រឿងរ៉ាវអាស្រូវទាំងនោះគឺជាចេត្តនាយូសុះយ៉ាងច្បាស់ នឹងដើម្បីលាងកំហុស សាងកេរ៍ឈ្មោះរបស់ខ្លួនវិញ ប៉ុន្តែការស្នើសុំរបស់ស៊ូឡែខត្រូវបានប្តីរបស់នាងបដិសេធ ព្រោះប្តីរបស់នាងបានដឹងយ៉ាងច្បាស់ថា វាមិនមែនជា

កំហុសរបស់យូសុះនោះទេ ហើយលោកដែលជាមន្ត្រីម្នាក់ដែលតែងតែយុត្តិធម៌នោះក មិនអាចបំពានលើភាពយុត្តិធម៌បានដែ។

ជាច្រើនខែក្រោយមក ដោយស៊ូឡែខ ព្យាយាមរកវិធីល្បិចកល់ផ្សេងៗដើម្បីលាង កំហុសខ្លួនឯងពុំបានសម្រេច ជាចុងក្រោយនាងបានរៀបចំផែនការណ៍មួយ ដោយ ផែនការណ៍នោះនាងបានរៀបចំកម្មវិធីជួបជុំអស់បណ្តាស្ត្រីអ្នកមានមុខមាត់ទាំងឡាយ ព្រមជាមួយនឹងមានស្រស់ស្រូបពិសារអាហា នំចំណីចំនុក កេស្ងះ នឹងផ្លែឈើគ្រប់មុខ គ្រប់ពណ៌ផងដែដោយមានការអនុញ្ញាតពីប្តីរបស់ខ្លួន។ នៅថ្ងៃនោះ នាពេលដែលប ណ្តាស្ត្រីអ្នកមានមុខមាត់ក្នុងសង្គមទាំងអស់នោះបានទៅដល់ផ្ទះរបស់ស៊ូឡែខហើយ កម្មវិធីក៏ចាប់ផ្តើមទ្បើង ដោយនាងស៊ូឡែខបានទ្បើងនិយាយជម្រាបអញ្ជើញជាកិច្ច ស្វាគមន៍ដល់ភ្ញៀវបណ្តាស្ត្រីទាំងអស់នោះ។ ឯយូសុះវិញកំពុងនៅក្នុងផ្ទះដើម្បីត្រៀម លើកអាហានំចំណីចំណុក នឹងផ្លែឈើទាំងអស់នោះជូនបណ្តាស្ត្រីខាងលើពិសារតាម បង្គាប់បញ្ជារបស់ស៊ូឡែខ ពេលស៊ូឡែខទ្បើយនិយាយរៀបរាប់អំពីរឿងរ៉ាវអាស្រូវរបស់ នាង នឹងអញ្ជើញពិសារចប់សប់គ្រប់ហើយ ស៊ូឡែខបានអញ្ជើញអោយស្ត្រីទាំងអស់ នោះត្រៀមកូនកាំបិតដ៏មុតម្នាក់មួយដើម្បីចិតផ្លែឈើ។ ពេលចាប់ផ្តើម ស៊ូឡែខបាន ហៅយូសុះចេញមកខាងក្រៅ បង្ហាញមុខនៅចំពោះមុខបណ្តាស្ត្រីទាំងអស់នោះ ស៊ូឡែ ខបាននិយាយថា៖ *ម៉ីបណ្តាស្ត្រីទាំងអស់គ្នាដែលមានវត្តមាននៅទីនេះ នេះហើយគឺជា យូសុះអ្នកបំរើរបស់ខ្ញុំ ដែលបណ្តាលឲ្យមានការលិចលឺរឿងអាស្រូវដ៏សែនអាម៉ាស់របស់ ខ្ញុំដល់ត្រជៀកអ្នកទាំងអស់គ្នានោះ។* ពេលលឺដូច្នោះ ស្ត្រីៗទាំងអស់នោះម្នាក់ៗបាន សម្លឹងមើលទៅយូសុះដោយមិនប្រព្រិចភ្នែកបន្តិចឡើយ ភាពស្រស់សង្ហា សស្អាត ទន់ភ្លន់ សមសួនរបស់យូសុះបានធ្វើឲ្យអស់ស្ត្រីទាំងអស់នោះចិតផ្លែឈើមុតដៃខ្លួនឯង រហូតហ៊ូឈាមប្រឡាក់កាំបិតនឹងផ្លែឈើដោយមិនដឹងខ្លួន ពេលនោះស៊ូឡែខបាន និយាយទៅកាន់ស្ត្រីទាំងអស់នោះថា៖ *ចូរពួកអ្នកមើលដៃរបស់ពួកអ្នកវិញ ហេតុអ្វីកាំ*

បុិតដៃលសម្រាប់ចិត្តផ្លែឈើនោះបៃជាមុតដៃរបស់ពួកអ្នកទាំងអស់វិញ តើអារម្មណ៍របស់ពួកអ្នកអណ្តែតអណ្តូងដល់ណាហើយ? ដោយភ្នែកមិនបានមើលផ្លែឈើដោយសម្លឹងមើលយូសុះធ្វើឲ្យដៃរបស់ពួកគេមុតនឹងកូនកាំបិតដ៏មុតស្រួចនោះ ម្នាក់ៗបានលាន់មាត់ស្ងើចសសើយូសុះថា ជាកម្លោះដ៏ស្រស់សង្ហា គ្មានបុរសណាប្រដូចឡើយ។

ម្នាក់ក្នុងចំណោមស្ត្រីខាងលើបាននិយាយថា៖ *ហេតុដូច្នោះហើយទើបស៊ូឡែខមិនអាចគ្រប់គ្រងតណ្ហារបស់ខ្លួនបាន។* ហើយនិយាយទៅកាន់យូសុះថា៖ *ឱយូសុះ.. តើអ្នកឯងនៅចាំអ្វីទៀត ពួកយើងទាំងអស់គ្នាពិតជាស្រលាញ់នឹងពេញចិត្តចំពោះអ្នក មិនមែនត្រឹមតែស៊ូឡែខម្នាក់នោះទេ ប៉ុន្តែដោយសារពួកយើងអាយុច្រើន ឯចំនែកស៊ូឡែខនៅក្មេង ថែមទាំងមានរូបសម្រស់ស្អាតភ្លឺជាងពួកយើងឆ្ងាយ ដូច្នោះបូរអ្នកឯងកំគិតអ្វីដែលខាត់បង់ ហេតុអ្វីអ្នកមិនយល់ព្រមជាមួយស៊ូឡែខ នឹងរួមរស់ជាមួយនាងដូច្នោះ?* ហើយមានអ្នកខ្លះទៀតនិយាយថា៖ បើបានទៅលើដៃស៊ូឡែខពិតមែនស៊ូឡែខពិតជាស្ត្រីដែលមានសំណាងបំផុតក្នុងចំណោមបណ្តាស្ត្រីទាំងឡាយដែលមានវត្តមានក្នុងកម្មពិធីពិសារអាហាថ្ងៃនេះ។ ហើយមានអ្នកខ្លះទៀតនិយាយថា៖ បើយូសុះធ្លាក់ក្នុងការគ្រប់គ្រងរបស់ខ្ញុំវិញ ខ្ញុំនឹងមិនឲ្យយូសុះរបូតចេញពីដៃខ្ញុំឡើយ ហើយខ្ញុំនឹងប្រគល់អ្វីៗគ្រប់យ៉ាងដើម្បីយូសុះ..។ ជាចុងក្រោយមានម្នាក់ផ្សេងទៀតបាននិយាយថា៖ *ឱយូសុះ.. ចូរអ្នកគិតម្តងទៀតឲ្យច្បាស់លាស់ ហើយចងចាំនូវការផ្តាំផ្ញើរបស់ខ្ញុំប៉ុន្មានម៉ាត់ចុងក្រោយនេះ ស៊ូឡែខបានចំណាយទាំងកិត្តិយស នឹងកេរ៍ខ្មាស់របស់នាងដើម្បីអ្នកដើម្បីសម្រេចបំនងរបស់នាងតាមការចង់បាននឹងប៉ងប្រាថ្នាចំពោះអ្នក នាងត្រូវបានមហាជនជាច្រើនចំអកទឹកឡែយឲ្យនាងថាជាស្ត្រីក្បត់ប្តីនឹងបន្ទោកកិត្តិយសភាពជាស្ត្រីភេទ កេរ៍ឈ្មោះនាងដែលធ្លាប់តែល្អ ស្ងោចសសើពីមនុស្សម្នាគ្រប់គ្នា តែឥឡូវបែជារលុត ស្អុយឈ្មោះក៏ព្រោះតែអ្នក ដូច្នោះបើសិនជាអ្នកនៅតែបដិសេធមិនព្រមត្រូវការនាង មិនព្រមតាមអ្វីៗដែលនាងចង់បាន មិនសុខចិត្តធ្វើជាប្តីរបស់នាងនោះ គង់មានថ្ងៃ*

ណាមួយនាងនឹងចាប់អ្នកដាក់គុកជាពុំខាន ព្រោះអ្នកដឹងស្រាប់ហើយថា ប្តីរបស់នាងស្រលាញ្ជនាងណាស់ ហើយប្តីរបស់នាងអាចធ្វើអ្វីៗគ្រប់យ៉ាងដើម្បីនាង ប្រសិនបើនាងឲ្យប្តីនាងចាប់អ្នកឃុំឃាំងក្នុងគុក អ្នកប្រាកដជាមិនអាចរួចខ្លួនឡើយ។ ខ្ញុំពិតជាមានការសោកស្តាយចំពោះការសម្រេចរបស់អ្នកណាស់ សូមអ្នកអនុវត្តន៍ចុះតាមតំរូវការតណ្ហារបស់ស៊ូឡែខ និងតាមអ្វីដែលនាងចូលចិត្តនឹងចង់បាន ទាំងនោះក៏ព្រោះតែសេចក្តីសុខរបស់អ្នក នឹងសុវត្តភាពរបស់អ្នកផងដែ។ បន្ទាប់ពីស្តាប់ចប់ហើយ យូសុះធ្វើហាបីដូចមិនដឹងមិនលឺនូវរាល់ការនិយាយផ្តាំផ្ញើរបស់បណ្តាស្ត្រីទាំងអស់នោះ យូសុះនៅតែធ្វើប្រងើយកន្តើយ មិនអើពើរចំពោះរាល់ការអង្វរករបស់ស៊ូឡែខដដែល ពេលនោះយូសុះបានលើកដៃសុំទូអារ (បួងសួង) ចំពោះអល់ឡោះនៅចំពោះមុខក្រុមស្ត្រីទាំងអស់នឹងចំពោះមុខស៊ូឡែខថា៖ *ខឺអល់ឡោះជាម្ចាស់.. សូមទ្រង់ផ្តល់ភាពរឹងមាំដល់ចិត្តរបស់ខ្ញុំផងចុះ សូមទ្រង់បញ្ជៀសនូវប្រការដែលវង្វេង (ខុសឆ្គង) ទាំងឡាយដែលហ្សៃតនញ្ជាំញីមកលើរូបខ្ញុំ សូមទ្រង់ជួយការពារខ្លួនរបស់ខ្ញុំពីប្រការដែលនាំឲ្យរូបខ្ញុំធ្លាក់ក្នុងអំពើបាបកម្មផងចុះ។ ខឺអល់ឡោះជាម្ចាស់.. ខ្ញុំសុខចិត្តទទួលទោសនិងចូលឃុំឃាំងរបស់មនុស្សលោក ប្រសើជាងខ្ញុំប្រព្រឹត្តណ៍បទល្មើសនឹងទ្រង់ ខ្ញុំសុខចិត្តរស់នៅក្នុងគុកប្រសើជាងរស់នៅខាងក្រៅដែលត្រូវប្រឈមមុខនឹងតណ្ហាអស់ស្ត្រីទាំងនេះ។ សូមទ្រង់បញ្ជៀសខ្លួនប្រាណខ្ញុំ ចិត្តខ្ញុំពីប្រការដែលទ្រង់បានហាមប្រាមផងចុះ។*

បន្ទាប់ពីបណ្តាស្ត្រីទាំងអស់នោះលឺការបួងសួងទូអាររបស់យូសុះរួច ពួកគេក៏ចាប់ផ្តើមចាកចេញពីកម្មវិធីពិសារអាហារនោះរៀងៗខ្លួន ឯចំនែកនាងស៊ូឡែខវិញដោយទ្រាំនឹងភាពអាម៉ាស់មិនបានករត់ចូលក្នុងផ្ទះវិញ។ មិនយូប៉ុន្មានក្រោយមកស៊ូឡែខបានអង្វរដល់ប្តី (លោក ហ្វាត់ហីហ្វីរ) ឲ្យរកវិធីដោះស្រាយដើម្បីពន្លត់ភាពអាម៉ាស់ រឿងអាស្រូវដែលកើតមានឡើងហើយលឺសោះសាយនោះ ដើម្បីបញ្ជាក់ថាខ្លួនពិតជាមនុស្សស្អាតស្អំ មិនប្រព្រឹត្តិនូវទង្វើដ៏ថោកទាបដូចដែលគេឯងដឹងលឺតៗគ្នានោះទេ។ ដោយក្តីស្រ

លាញ អានិតអាស៊ូពីប្តីរបស់នាង ទុះជាលោកដឹងថាយូសុះមិនមានកំហុសអ្វីសោះ ឯស៊ូឡែខវិញជាអ្នកដែលខុសទាំងស្រុងកដោយ លោកនៅតែដួយនឹងយល់ព្រមធ្វើតាមការស្នើសុំរបស់ស៊ូឡែខ។

យូសុះជាប់ឆោស



ក្នុងយះពេលខ្លីក្រោយមក ប្តីរបស់ស៊ូឡែខបានចេញលិខិតបង្គាប់ឲ្យចាប់ខ្លួនយូសុះ គឺធ្វើទ្បើងនៅផ្ទះរបស់លោកផ្ទាល់តែម្តង។ នាថ្ងៃមួយពេលព្រឹកស្រាងៗ កូនទាហានរបស់ប្តីស៊ូឡែខបានចូលក្នុងផ្ទះរបស់នាង នឹងបានចាប់យូសុះតាមបង្គាប់បញ្ជារបស់លោក ហ្វាត់ហីហ្វើរ នឹងតាមការអង្វរករបស់ស៊ូឡែខផងដែ ឯយូសុះវិញ មិនបានរត់ហើយកមិនញញើតនឹងឲ្យក្រុមកូនទាហានទាំងអស់នោះចាប់ដែ យូសុះបានប្រគល់ខ្លួនជូនក្រុមទាហានទាំងអស់នោះដោយរីករាយនឹងដោយស្មគ្រចិត្តផងដែ ព្រោះវាគឺជាបំណងប្រាថ្នារបស់យូសុះស្រាប់ ដែលយូសុះបានបួងសួងសុំទាអារទៅចំពោះអល់ទ្បោះស៊ូរស់នៅក្នុងគុកប្រសើជាងរស់នៅខាងក្រៅពោពេញដោយប្រការបាបកម្ម។ ក្រុមទាហានទាំងនោះបានបណ្តើយូសុះចេញពីផ្ទះស៊ូឡែខ ឆ្ពស់ទៅកាន់តុលាការមួយកន្លែងដើម្បីប្រឈមមុខកាត់ទោសយូសុះ។ ពេលទៅដល់តុលាការយូសុះមិនបាននិយាយអ្វីច្រើនវែងឆ្ងាយនោះទេ យូសុះគ្រាន់តែបញ្ជាក់ថាខ្ញុំគ្មានទោសកំហុសនោះទេ ហើយខ្ញុំសុខចិត្តទទួលទោសរបស់មនុស្សលោកដែលដាក់លើរូបខ្ញុំ ប៉ុន្តែខ្ញុំមិនព្រមធ្វើនូវទង្វើដែលក្បត់នឹងអល់ទ្បោះទ្បើយ។ យូសុះនិយាយពាក្យ

នេះជាច្រើនដង ហើយដដែលៗ ជាចុងក្រោយតុលាការដែលលួចខុបខិតជាមួយប្តីស៊ូ
ឡែខនោះ បានសម្រេចចិត្តផ្តល់ទាទោសដល់យូសុះឲ្យជាប់គុកតាមចំនួនពេលវេលា
ដែលតុលាការបានកំនត់។ (22-35)

وَلَمَّا بَلَغَ أَشُدَّهُۥٓ ءَاتَيْنَٰهُ حُكْمًا وَعِلْمًا ۚ وَكَذَٰلِكَ نَجْزِى ٱلْمُحْسِنِينَ ﴿٢٢﴾ وَرَٰوَدَتْهُ ٱلَّتِى هُوَ فِى بَيْتِهَا عَن
نَّفْسِهِۦ وَغَلَّقَتِ ٱلْأَبْوَٰبَ وَقَالَتْ هَيْتَ لَكَ ۚ قَالَ مَعَاذَ ٱللَّهِ ۖ إِنَّهُۥ رَبِّىٓ أَحْسَنَ مَثْوَاىَ ۖ إِنَّهُۥ لَا
يُفْلِحُ ٱلظَّٰلِمُونَ ﴿٢٣﴾ وَلَقَدْ هَمَّتْ بِهِۦ ۖ وَهَمَّ بِهَا لَوْلَآ أَن رَّءَا بُرْهَٰنَ رَبِّهِۦ ۚ كَذَٰلِكَ
لِنَصْرِفَ عَنْهُ ٱلسُّوٓءَ وَٱلْفَحْشَآءَ ۚ إِنَّهُۥ مِنْ عِبَادِنَا ٱلْمُخْلَصِينَ ﴿٢٤﴾ وَٱسْتَبَقَا ٱلْبَابَ وَقَدَّتْ
قَمِيصَهُۥ مِن دُبُرٍ وَأَلْفَيَا سَيِّدَهَا لَدَا ٱلْبَابِ ۚ قَالَتْ مَا جَزَآءُ مَنْ أَرَادَ بِأَهْلِكَ سُوٓءًا إِلَّآ أَن يُسْجَنَ أَوْ
عَذَابٌ أَلِيمٌ ﴿٢٥﴾ قَالَ هِىَ رَٰوَدَتْنِى عَن نَّفْسِى ۚ وَشَهِدَ شَاهِدٌ مِّنْ أَهْلِهَآ إِن كَانَ قَمِيصُهُۥ قُدَّ
مِن قُبُلٍ فَصَدَقَتْ وَهُوَ مِنَ ٱلْكَٰذِبِينَ ﴿٢٦﴾ وَإِن كَانَ قَمِيصُهُۥ قُدَّ مِن دُبُرٍ فَكَذَبَتْ وَهُوَ مِنَ
ٱلصَّٰدِقِينَ ﴿٢٧﴾ فَلَمَّا رَءَا قَمِيصَهُۥ قُدَّ مِن دُبُرٍ قَالَ إِنَّهُۥ مِن كَيْدِكُنَّ ۖ إِنَّ كَيْدَكُنَّ عَظِيمٌ ﴿٢٨﴾
يُوسُفُ أَعْرِضْ عَنْ هَٰذَا ۚ وَٱسْتَغْفِرِى لِذَنۢبِكِ ۖ إِنَّكِ كُنتِ مِنَ ٱلْخَاطِـِٔينَ ﴿٢٩﴾ ۞ وَقَالَ
نِسْوَةٌ فِى ٱلْمَدِينَةِ ٱمْرَأَتُ ٱلْعَزِيزِ تُرَٰوِدُ فَتَىٰهَا عَن نَّفْسِهِۦ ۖ قَدْ شَغَفَهَا حُبًّا ۖ إِنَّا لَنَرَىٰهَا فِى ضَلَٰلٍ مُّبِينٍ
﴿٣٠﴾ فَلَمَّا سَمِعَتْ بِمَكْرِهِنَّ أَرْسَلَتْ إِلَيْهِنَّ وَأَعْتَدَتْ لَهُنَّ مُتَّكَـًٔا وَءَاتَتْ كُلَّ وَٰحِدَةٍ مِّنْهُنَّ سِكِّينًا وَقَالَتِ
ٱخْرُجْ عَلَيْهِنَّ ۖ فَلَمَّا رَأَيْنَهُۥٓ أَكْبَرْنَهُۥ وَقَطَّعْنَ أَيْدِيَهُنَّ وَقُلْنَ حَٰشَ لِلَّهِ مَا هَٰذَا بَشَرًا إِنْ هَٰذَآ إِلَّا مَلَكٌ كَرِيمٌ
﴿٣١﴾ قَالَتْ فَذَٰلِكُنَّ ٱلَّذِى لُمْتُنَّنِى فِيهِ ۖ وَلَقَدْ رَٰوَدتُّهُۥ عَن نَّفْسِهِۦ فَٱسْتَعْصَمَ ۖ وَلَئِن لَّمْ يَفْعَلْ مَآ ءَامُرُهُۥ
لَيُسْجَنَنَّ وَلَيَكُونًا مِّنَ ٱلصَّٰغِرِينَ ﴿٣٢﴾ قَالَ رَبِّ ٱلسِّجْنُ أَحَبُّ إِلَىَّ مِمَّا يَدْعُونَنِىٓ إِلَيْهِ ۖ وَإِلَّا تَصْرِفْ
عَنِّى كَيْدَهُنَّ أَصْبُ إِلَيْهِنَّ وَأَكُن مِّنَ ٱلْجَٰهِلِينَ ﴿٣٣﴾ فَٱسْتَجَابَ لَهُۥ رَبُّهُۥ فَصَرَفَ عَنْهُ كَيْدَهُنَّ ۚ إِنَّهُۥ هُوَ
ٱلسَّمِيعُ ٱلْعَلِيمُ ﴿٣٤﴾ ثُمَّ بَدَا لَهُم مِّنۢ بَعْدِ مَا رَأَوُا۟ ٱلْـَٔايَٰتِ لَيَسْجُنُنَّهُۥ حَتَّىٰ حِينٍ ﴿٣٥﴾

មាននយ័ថា៖ (22)- ហើយនៅពេលដែលយូសុះគ្រប់អាយុពេញវ័យ យើងបានផ្តល់ជូនទៅគេនូវ គតិបណ្ឌិតនិងចំនេះដឹង ប្រៀបដូច្នេះហើយយើងនឹងតបស្នងចំពោះពួកគេវិញដែលបានសាងអំពើ ល្អ។ (23)- បន្ទាប់មក នារីដែលយូសុះរស់នៅក្នុងផ្ទះជាមួយនាងនោះ បានលួងលោមយូសុះពីរូប យូសុហ្វផ្ទាល់ ហើយនាងបានបិទគ្រប់ទ្វារ រួចនាងថា៖ សូមអ្នកមកជិតនេះ! យូសុះឆ្លើយថា៖ សូមអល់ឡោះការពារខ្ញុំផង!! ការពិតលោក(ប៊ីស៊ូឡែខ) ជាចៅហ្វាយរបស់ខ្ញុំ គឺជាកន្លែងដែលខ្ញុំ រស់នៅដ៏ល្អជាងគេ។ ការពិតពួកប្រព្រឹត្តណ៍អំពើអយុត្តិធម៌នឹងមិនឈ្នះឡើយ។ (24)- ជាការពិត ណាស់ នាងមានចំណង់ (ស្រលាញ់) ចំពោះយូសុះ ហើយយូសុះក៏មានចំណង់លើនាងវិញដែរ បើសិនយូសុះមិនបានឃើញភ្រុកស្តុតាងរបស់ម្ចាស់គេទេ។ ហេតុដូច្នេះហើយ យើងនឹងបំបែកពីគេនូវ អំពើមិនគប្បី និងប្រការអាក្រក់ទាំងឡាយ។ ការពិតយូសុះក្នុងចំណោមពួកអ្នកដែលគៅរព ប្រណិបត្តិចំពោះយើងដ៏ស្មោះត្រង់បំផុត។ (25)- ហើយគេទាំងពីរនាក់ (យូសុះនឹងសូឡែខ) បានដណ្តើមគ្នារត់ទៅទ្វារ ហើយនាងបានហែកអាវរបស់យូសុះពីខាងក្រោយ ហើយពួកគេទាំង ពីរនាក់បានឃើញចៅហ្វាយប្រុសពួកគេនៅឯទ្វារ ។ រួចនាងនិយាយថា ចូរកយុត្តិធម៌សំរាប់អ្នក ដែលមានបំណងអាក្រក់ចំពោះគ្រួសាររបស់អ្នក គ្មានអ្វីក្រៅពីចាប់គេដាក់ចូលក្នុងឃុំឃាំង ឬក៏ធ្វើ ទណ្ឌកម្មណាមួយដ៏ឈឺចាប់បំផុត។ (26)- យូសុះនិយាយថា នាងបានធ្វើល្បិចលួងលោមលើរូប ខ្ញុំ ហើយអ្នកអាចធ្វើសាក្សីបាន ដោយសាក្សីម្នាក់នោះក្នុងចំណោមនៃគ្រួសាររបស់នាង សាក្សីបាន និយាយថា បើអាវរបស់យូសុះរហែកពីខាងមុខ ពិតណាស់នាងបាននិយាយជាការពិត ហើយ ចំពោះយូសុះក្នុងចំណោមពួកអ្នកដែលភូតកុហក។ (27)- ប៉ុន្តែបើអាវរបស់យូសុះរហែកពីខាង ក្រោយវិញ គឺនាងជាអ្នកភូតកុហក ហើយយូសុះក្នុងចំណោមពួកអ្នកដែលនិយាយទៀងត្រង់។ (28)- នៅពេលដែលចៅហ្វាយបានឃើញអាវរបស់យូសុះបនរហែកខាងក្រោយ គេនិយាយថា ការពិតវាគឺជាផ្នែកមួយនៃល្បិចកលរបស់ពួកនាង។ ល្បិចកលរបស់ពួកនាងពិតជាព្រៃផ្សៃណាស់។ (29)- ឱយូសុះ!! ចូរអ្នកបំភ្លេចរឿងរ៉ាវនេះចោលចុះ រីឯចំណែកនាងវិញចូរសុំអភ័យទោសចំពោះ បាបកម្មរបស់នាង ។ នាងគឺពិតជាអ្នកក្នុងចំណោមពួកដែលប្រព្រឹត្តិអំពើខុសឆ្គង។ (30)- រួចមក ពួកស្ត្រីនៅក្នុងទីក្រុងបាននិយាយថា៖ ភរិយារបស់លោកអាហ្សីស បានលួង លោមអ្នកបំរើខ្លួនឯង ពីរូបរបស់គេ ជាការពិតណាស់ មនោសញ្ចោតនារបស់នាង គឺ ស្រលាញ់ងប់។ ពួកយើងពិតជា ឃើញនាងស្ថិតក្នុងការភាន់ច្រលំមួយដ៏ច្បាស់បំផុត។ (31)- លុះនៅពេលដែលនាងបានឮនូវ

អន្ទងវញ្ចនា (ការចោទប្រកាន់) របស់ពួកនាង នាងក៏បានចាត់បញ្ជូនទៅពួក នាង ហើយនាង រៀបចំសំរាប់ពួកនាងនូវបន្ទប់ទទួលភ្ញៀវមួយ រួចមកនាងបានផ្តល់ទៅគ្រប់រូប ក្នុងចំណោម ពួក នាងនូវកាំបិតមួយម្នាក់ រួចមកនាងថា ចូរយូសុហ្វចេញទៅកាន់ពួកទាំងនោះទៅ។ លុះនៅពេល ដែល ពួកនាងបានឃើញយូសុហ្វ ពួកនាងស្រឡាំងកាំងចំពោះយូសុហ្វ ហើយពួកនាងក៏បានកាត់ ដៃពួកនាង ផ្ទាល់ រួចមកពួកនាងបានថា មហាបរិសុទ្ធអល់ឡោះ នេះគឺពុំមែនជាមនុស្សទេ។ នេះ គឺគ្មានអ្វីក្រៅពី ម៉ាឡាអ៊ីកាត់ម្នាក់ដ៏ល្អប្រណីតបំផុត។ (32)- នាងថា ទាំងនេះហើយដែលពួកអ្នក ធ្លាប់បានបន្ទោសយើងនោះ ជាការពិតណាស់យើងបានល្បួងប្រលោមគេពីរូបគេផ្ទាល់ រួចមកគេ រុញច្រាន ហើយការពារបានភាព បរិសុទ្ធរបស់គេ ជាការពិតណាស់ បើគេនៅតែមិនព្រមធ្វើនូវអ្វី ដែលយើងដាក់បញ្ជាទៅគេ គេប្រាកដជា នឹងត្រូវដាក់ពន្ធនាគារ ហើយគេនឹងមានក្នុងចំណោម ពួកថោកទាប។ (33)- យូសុហ្វថា ឱម្ចាស់របស់ខ្ញុំ ពន្ធនាគារនោះ ជាទីស្រលាញ់ចំពោះខ្ញុំជាងអ្វី ដែលពួកនាងបបួលខ្ញុំនោះទៅទៀត ហើយប្រសិនបើលោក មិនបំបែកចេញនូវល្បិចកលរបស់ពួក នាងពីខ្ញុំទេ ខ្ញុំប្រាកដជានឹងលំអៀងទៅកាន់ពួកនាង ពេលនោះខ្ញុំ ប្រាកដជានឹងមានក្នុងចំណោម ពួកឆោតល្ងង់។ (34)- រួចមក ម្ចាស់របស់គេក៏បានទទួលឆ្លើយតបទៅកាន់គេ វិញ រួចលោកបាន បំបែរចេញពីគេនូវល្បិចកលរបស់ពួកនាង។ ការពិត លោកគឺជាអ្នកដឹងបំផុត ឮបំផុត។ (35)- ក្រោយមក ក៏បានលេចឡើងចំពោះពួកគេនូវអ្វីដែលពួកគេបានមើលឃើញនូវភស្តុតាងៗពួកគេ និង ដាក់ពន្ធនាគារចំពោះយូសុហ្វរហូតដល់ពេលកំណត់មួយ។

ចាប់ពីថ្ងៃនោះមក យូសុះរស់នៅក្នុងគុកទាំងងងឹតនឹងចង្អៀត យូសុះមិនដែលត្អូញត្អែ បន្តិចឡើយ ផ្ទុយទៅវិញយូសុះរីករាយចំពោះការរស់នៅក្នុងគុកទាំងគ្មានកំហុស។ ក្នុង រយៈពេលយូសុះរស់នៅក្នុងគុក យូសុះមានពេលវេលាច្រើនដើម្បីប្រមូលផ្តុំអារម្មណ៍ សម្មាធិក្នុងចិត្តដើម្បីគោរពប្រណិបត្តិទៅចំពោះអល់ឡោះ ទាំងនោះធ្វើអោយយូសុះ មានការស្វែងនឹងចេះដឹងបានច្រើនដោយជំនួយពីអល់ឡោះ យូសុះបានចាប់ផ្តើមធ្វើ ការដាក់វ៉ែះ (ណែនាំ) ដល់អ្នកជាប់ទោសទាំងអស់ក្នុងគុកដូចយូសុះដែឲ្យដឹង យល់ អំពីសាសនារបស់អល់ឡោះ។ ពីមួយថ្ងៃទៅមួយថ្ងៃ យូសុះព្យាយាមធ្វើការពន្យល់ដល់

អ្នកទោសក្នុងគុក ឲ្យដើតាមផ្លូវដែលត្រឹមត្រូវ នឹងជៀសពីផ្លូវដែលអាក្រក់ខុសឆ្គង យូសុះបានបង្រៀនពួកគេឲ្យចេះធ្វើល្អ នឹងជៀសពីប្រការដែលបាបកម្មទាំងឡាយ។

មានថ្ងៃមួយ ក្រោយពីយូសុះបានក្រោកពីដំណេក មានបុរសជាប់ទោសពីរនាក់បានទៅជួបនឹងយូសុះ ដើម្បីឲ្យយូសុះជួយកាត់សុបិនរបស់ពួកគេទាំងពីរ។ ម្នាក់ក្នុងចំណោមពួកគេគឺជាអតីតមេផ្ទះការពារឃ្លាំងម្ហូបអាហារ នឹងរៀបចំចំណីអាហារជូនស្តេច ម្នាក់នេះជាប់គុកពីបទចោទប្រកាន់ថាបានលួចដាក់ថ្នាំពុលចូលក្នុងអាហាររបស់ស្តេច រីឯម្នាក់ទៀតមានតួនាទីជាអ្នករៀបចំអៅអ៊ីឲ្យស្តេចអង្គុយពេលពិសារអាហា នឹងដួសអាហារជូនស្តេច ជាប់ទោសពីបទលួចផ្សំគំនិតធ្វើគុតស្តេច។ ម្នាក់ដែលជាអ្នកការពារខ្លាំងម្ហូបអាហារ នឹងចំអិនអាហារជូនស្តេចបាននិយាយទៅកាន់យូសុះថា៖ *ឱយូសុះ.. ពេលយប់ក្នុងដំនេករបស់ខ្ញុំ ខ្ញុំបានយល់សុបិនឃើញខ្ញុំកំពុងកាន់ចានជាក់ផ្លែត្រពាំងបាយជូនៅក្នុងចំការត្រពាំងបាយជូមួយកន្លែង ដែលកែវនោះមានរូបរាងនឹងកិនភាគប្រហាក់ប្រហែលទៅនឹងកែវផឹកទឹកត្រពាំងបាយជូរជាប្រចាំរបស់ស្តេច។* និងម្នាក់ទៀតដែលជាអ្នករៀបអៅអ៊ី នឹងដួសអាហារជូនស្តេចវិញបានរៀបរាប់សុបិនរបស់គេប្រាប់យូសុះថា៖ *ក្នុងដំនេករបស់ខ្ញុំ ខ្ញុំបានយល់សុបិនឃើញរូបខ្ញុំកំពុងទូលកញ្ជែងមួយនៅលើក្បាល ហើយក្នុងកញ្ជែងនោះមាននំបុ័ង ស្រាប់តែមានសត្វចាបមួយក្បាលបានពាំនំបុ័ងនោះហើរទៅបាត់។* ពួកគេទាំងពីរនាក់សុំឲ្យយូសុះកាត់សុបិនរបស់ពួកគេ តើសុបិននោះនឹងមាននិយាយ៉ាងដូចម្តេច នឹងមានអ្វីកើតឡើងចំពោះពួកគេទាំងពីរទៅថ្ងៃខាងមុខ។ បន្ទាប់ពីយូសុះបានស្តាប់ការរៀបរាប់របស់អ្នកទាំងពីរយ៉ាងយកចិត្តទុកដាក់រួច យូសុះបានកាត់សុបិនជូនពួកគេថា៖ អ្នកទីមួយ (អ្នកយាមឃ្លាំងនឹងធ្វើម្ហូបអាហារជូនស្តេច) និងត្រូវកាត់ទោសប្រហារជីវិត្ត។ អ្នកទីពីរ (អ្នករៀបចំតុកៅអីនឹងដួសបាយឲ្យស្តេច) នឹងត្រូវរួមផុតពីទោស ហើយមានអនាគត់ជាអ្នករៀបចំតុកៅអី នឹងដួសបាយជូនស្តេចដដែល។ បន្ទាប់ពីស្តាប់ការបកស្រាយ កាត់សុបិនយូសុះចប់ អ្នកទាំងពីរបានចាកចេញ

ពីយូសុះ ម្នាក់ធ្វើមុខក្រៀមក្រំ ពិបាកចិត្ត ទុក្ខព្រួយគ្មានអ្វីថ្លែងពុំបាន រីឯម្នាក់ទៀត សប្បាយរីករាយ ដើបណ្តើញញឹមបណ្តើ សប្បាយចិត្តពន់ពេកក្រៃ។ មិនយូសប៉ុន្មាន អ្វីៗដូចការទុះទាយរបស់យូសុះមិនខុសឡើយ នាក់ទីមួយត្រូវតុលាការសម្រេចប្រហារជីវិត្ត រីឯម្នាក់ទៀតត្រូវបានតុលាការសម្រេចដោះលែងដោយគ្មានទោសកំហុស ហើយត្រូវបានស្តេចអនុញ្ញាតឲ្យចូលបំរើការងារជាអ្នករៀបចំតុកៅអី នឹងដួសបាយអាហារជូនស្តេចបរិភោគដូចដើមវិញ។ នៅថ្ងៃបុរសទីពីរត្រូវបានតុលាការដោះលែងឲ្យមានសិទ្ធិសេរីភាពឡើងវិញ មុននឹងចាកចេញពីគុក គេបានទៅជួបនឹងយូសុះម្តងទៀតដើម្បីថ្លែងអំណរអរគុណចំពោះការកាត់សុបិនរបស់គេដែលត្រឹមត្រូវ មិនខុសសូម្បីបន្តិចណាឡើយ ពេលនោះយូសុះបានផ្តាំផ្ញើជាមួយបុរស់ម្នាក់នោះថា៖ *ប្រសិនអ្នកបានចាកចេញពីគុកដោយមានសិទ្ធិសេរីភាព នឹងបានចូលបំរើការងារជាអ្នករៀបចំតុកៅអីនឹងដួចបាយជូនស្តេចដូចការការសុបិនរបស់ខ្ញុំពិតមែន សូមអ្នកកំភ្លេចប្រាប់ដល់ស្តេចអង្គនោះថា ខ្ញុំឈ្មោះយូសុះ ហើយខ្ញុំត្រូវបានតុលាការដាក់ទោសទាំងរូបខ្ញុំពុំមានកំហុសខុសឆ្គងណាមួយបន្តិចសោះឡើយ។* បន្ទាប់មកបុរសរូបនោះបានចាក់ចេញពីយូសុះ នឹងទទួលមុខងារជាអ្នករៀបចំតុកៅអីនឹងដួសបាយអាហារជូនស្តេចបរិភោគដូចដើមវិញ។ ជាយូក្រោយមក ការផ្តាំផ្ញើរបស់យូសុះជាមួយបុរសម្នាក់នោះក្លាយជាការផ្តាំផ្ញើឥតន័យដោយសារបុរសម្នាក់នោះបានភ្លេចបញ្ជាំរបស់យូសុះប្រាប់ដល់ស្តេច។

ណាពីយូសុះមានសិទ្ធិសេរីភាព

មិនយូប៉ុន្មានក្រោយមក នៅថ្ងៃមួយ ស្តេចអង្គនោះបានយល់សុបិន ឃើញថា មានសត្វគោមេចំនួន

ប្រាំពីរក្បាល ដោយមានមេគោធាត់ៗស៊ីមេគោដែលស្គមធ្វើជាចំណី នឹងឃើញដំណាំប្រាំពីរគួរទៀតក្រៀមស្វិត។ នាពេលព្រឹកព្រលឹងស្រាងៗ ស្តេចអង្គនោះបានចេញបង្គាប់បញ្ជាឲ្យអស់មន្ត្រីអ្នកមុខអ្នកការ ថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់ អ្នកទស្សទាយ អ្នកទស្សនៈ អ្នកវិភាគគ្រប់គ្នា មកពីគ្រប់តំបន់ ឲ្យចូលខ្លួនគាល់ដើម្បីវិភាគ និងធ្វើការទស្សទាយសុបិនរបស់ខ្លួន។ ប៉ុន្តែជាអកុសល្យ គ្មានមន្ត្រីអ្នកវិភាគ អ្នកទស្សទាយរូបណាម្នាក់អាចទស្សទាយដឹងអំពីសុបិនរបស់ស្តេចអង្គនោះទេ្បីយ មានទស្សនៈនឹងការបកស្រាយសុបិននោះផ្សេងៗគ្នា ដោយរកហេតុរកផល់មិនឃើញ ច្របូកច្របល់រកភាពត្រឹមត្រូវធ្វើជាការមិនបាន នៅពេលឃើញដូច្នោះ បុរសម្នាក់ដែលទើបតែរួចផុតពីទោសនឹងជាអ្នកដែលយូសុះផ្តាំផ្ញើឲ្យជួយទូលប្រាប់ស្តេចនោះ បាននឹកឃើញអំពីការផ្តាំផ្ញើរបស់យូសុះ។ បុរសម្នាក់នោះបានចូលជិតស្តេចហើយបានរៀបរាប់ប្រាប់ស្តេចអង្គនោះថា៖ បរពិត!! ខ្ញុំបានស្គាល់បុរសម្នាក់គ្រាដែលខ្ញុំនៅក្នុងគុក ហើយពេលនេះរូបគេកំពុងជាប់ទោសក្នុងគុកផងដែ បុរសម្នាក់នោះគឺជាមនុស្សម្នាក់ដែលពូកែទស្សទាយ ហើយមានទេពកុសល្យខ្ពស់ក្នុងការកាត់សុបិន។ គេបានទស្សទាយសុបិនរបស់ខ្ញុំ និងរឿងរ៉ាវសុបិនរបស់បុរសម្នាក់ទៀត ដែលត្រូវបានកាត់ទោសប្រហារជីវិត្ត។ នឹងបន្តប្រាប់ការទស្សទាយរបស់យូសុះប្រាប់ដល់ស្តេច។ នៅពេលស្តេចអង្គនោះលឺដូច្នោះ ស្តេចបានបញ្ជាឲ្យបុរសម្នាក់នោះទៅជួបនឹងយូសុះដើម្បីកាត់សុបិនរបស់លោក នៅពេលបុរសម្នាក់នោះទៅដល់គុកនឹងបានរៀបរាប់ប្រាប់រឿងរ៉ាវសុបិនរបស់ស្តេចដល់យូសុះ យូសុះបានធ្វើការកាត់សុបិននោះថា៖ *ជាការពិតណាស់ ប្រទេសជាតិនឹងជួបនឹងភាពសម្បូរបែប គ្រប់ដំណាំស្រូវ រុក្ខជាតិ បន្លែង នឹងការប្រកបមុខរបរបស់ប្រជារាស្ត្រនឹងទទួលបានភាពសុខសាន រីកចំរើនល្អឥតខ្ចុះនាពេលនេះ ប៉ុន្តែក្នុងឆ្នាំបន្ទាប់ ប្រទេសជាតិនឹងជួបនឹងវិបត្តិគ្រោះទុរភិក្សវឹងស្ងួតហួតហែង គ្មានទឹក គ្មានផល់ នឹងគ្រប់ដំណាំផ្លែឈើផ្សេងៗមិនអំណោយផល់ដល់ប្រជាគសិករទេ្បីយ ទន្លេនីលនឹងរីងគ្មានទឹកគ្រប់គ្រាន់សំរាប់*

អ្នកកសិករ គ្រប់ដំណាំបន្លែទាំងអស់នឹងត្រូវបំផ្លិចបំផ្លាញដោយសត្វល្អិត ហើយគ្រោះនេះមានរយៈពេលប្រាំពីរឆ្នាំជាបន្តន្ទាប់។ ដូច្នោះស្តាប់ការផ្តាំផ្ញើរបស់ខ្ញុំ និងសូមពាំនាំការកាត់សុបិនរបស់ខ្ញុំនេះទូលពិតដល់ស្តេច ឲ្យលោកត្រៀមស្បៀង នឹងរឹះរកវិធានការណ៍ផ្សេងៗដើម្បីទប់ទល់និងគ្រោះខាងលើ។ បន្ទាប់ពីរស្តាប់ការទស្សទាយរបស់យូសុះរួច បុរសម្នាក់នោះប្រញាប់វិលត្រលប់ទៅរាជវាំងនោះវិញ បន្ទាប់មកការកាត់សុបិនរបស់យូសុះបានដឹងដល់ស្តេចអង្គនោះ។ បន្ទាប់ពីស្តេចអង្គនោះបានស្តាប់ការរៀបរាប់ប្រាប់ពីបុរសម្នាក់នោះហើយ ស្តេចអង្គនោះមានអារម្មណ៍ថា ការទស្សទាយរបស់យូសុះហាបីដូចជារឿងពិត នឹងអាចទទួលយកបាន ស្តេចអង្គនោះបានចេញបង្គាប់បញ្ជាឲ្យមន្ត្រីរបស់ខ្លួនទៅជួបនិងយូសុះនៅក្នុងគុក នឹងបានបញ្ជាឲ្យមន្ត្រីឆ្មាំគុកដោះលែងយូសុះឲ្យមានសិទ្ធិសេរីភាពឡើងវិញ ប៉ុន្តែការដោះលែងនេះត្រូវបានយូសុះបដិសេធដោយយូសុះបាននិយាយថា៖ *ខ្ញុំពិតជាមិនអាចទទួលយកបានឡើយ បើសិនជាខ្ញុំមានសេរីភាពពីការឃុំឃាំងដោយសារត្រូវបានគេដោះលែងទាំងមិនរកខុសត្រូវនោះ រឺលើកលែងទោសទាំងឈ្មោះខ្ញុំនឹងខ្លួនខ្ញុំមានកំហុសបែបនេះ បើសិនជាខ្ញុំធ្វើដូច្នេះ ពិតណាស់មនុស្សគ្រប់រូបនឹងគិតថា ខ្ញុំគឺជាអ្នកខុសដូចការចោទប្រកាន់ ហើយខ្ញុំនៅតែជាអ្នកខុសអស់មួយជីវិត បើសិនជាខ្ញុំរួចផុតពីឃុំឃាំងនេះ ខ្ញុំត្រូវតែចេញដោយស្អាតស្អំ គ្មានកំហុសដូចដែលស៊ូឡែខនឹងប្តីរបស់នាងចោទប្រកាន់មកលើរូបខ្ញុំនោះទេ។* នៅពេលដែលគ្រប់មន្ត្រីតូចធំទាំងនោះបានលឺសំដីយូសុះដូច្នោះ កប្រញាប់ប្រញាលទៅទូលពិតដល់ស្តេចវិញ ហើយបានរៀបរាប់ប្រាប់ស្តេចអំពីគោលបំណងរបស់យូសុះដែលមិនព្រមចេញពីការឃុំឃាំង។ នៅពេលស្តេចអង្គនោះបានជ្រាប់ហើយ ស្តេចបានបញ្ជាឲ្យមន្ត្រីរបស់ខ្លួនអញ្ជើញស្រីៗដែលបានទៅចូលរួមកម្មវិធីដែលស៊ូឡែខរៀបចំនោះទៅចូលរួមក្នុងកម្មវិធីមួយដែលរៀបចំដោយស្តេចតែម្តង។ ពេលកម្មវិធីជួបជុំចាប់ផ្តើមធ្វើឡើងដោយស្តេចអង្គនោះខ្លួនឯងក៏ចូលរួមផងដែរ ពេលនោះស្តេចអង្គនោះបានបញ្ជាឲ្យស្រីៗទាំងនោះ

បញ្ចេញម្រៀមដៃរបស់ខ្លួនដើម្បីត្រួតពិនិត្យមើលស្លាកស្នាមមុតកាំបិតនាពេលដែលពួកនាងឃើញយូសុះ (ដូចបានរៀបរាប់ខាងលើ) ដើម្បីបង្ហាញនឹងបញ្ជាក់ថា បណ្តាស្ត្រីទាំងអស់នោះពិតជាបានចូលរួមក្នុងកម្មវិធីពិសារអាហារដែលស៊ូឡែខអញ្ជើញនោះមែននឹងដើម្បីធ្វើជាសាក្សីរាល់ការនិយាយស្តីរវាងពួកគេនឹងយូសុះ នឹងស៊ូឡែខផងដែរ។ នៅពេលនោះ បណ្តាស្ត្រីទាំងអស់នោះបាននិយាយថា ពួកខ្លួនពិតជាបានដឹងលឺយ៉ាងច្បាស់ថា យូសុះគ្មានកំហុសទោសពៃអ្វីទេ្បយ គឺជាបុរសដែលស្អាតស្អំ ឯចំនែកស៊ូឡែខវិញ នាងបានទទួលសារភាពថាទាំងអស់នោះ គឺជាគម្រោងការរបស់នាងនឹងស្វាមី (បន្ទាប់ពីយូសុះជាប់ឃុំឃាំងប្តីរបស់ស៊ូឡែខបានស្លាប់) ទំលាក់កំហុសលើយូសុះដើម្បីលាងកំហុសខ្លួនឯងនិងក្រុមគ្រួសារ ម្យ៉ាងវិញទៀតដើម្បីបំភ័ណ្ឌភ្នែកមនុស្សទាំងឡាយថា យូសុះគឺជាអ្នកចាប់រំលោភស៊ូឡែខ ដើម្បីការពារកេរ៍ឈ្មោះរបស់ខ្លួនឯង។ បន្ទាប់ពីស្តេចបានជ្រាបច្បាស់រួចរាល់ហើយ ស្តេចបានចេញសេចក្តីប្រកាស់ដល់បណ្តាមហាជន ប្រជារាស្ត្រ មន្ត្រីតូចធំគ្រប់លំដាប់ថ្នាក់ គ្រប់កន្លែងឲ្យដឹងជ្រាបជាពត៌មាន ក្រោយមកស្តេចអង្គនោះបានបញ្ជាឲ្យមន្ត្រីរបស់ខ្លួនប្រាប់ទៅយូសុះ នឹងបានអញ្ជើញយូសុះចេញពីឃុំឃាំងវិញនាពេលនោះ។

وَقَالَ ٱلْمَلِكُ إِنِّيٓ أَرَىٰ سَبْعَ بَقَرَٰتٍ سِمَانٍ يَأْكُلُهُنَّ سَبْعٌ عِجَافٌ وَسَبْعَ سُنۢبُلَٰتٍ خُضْرٍ وَأُخَرَ
يَابِسَٰتٍ ۖ يَٰٓأَيُّهَا ٱلْمَلَأُ أَفْتُونِى فِى رُءْيَىَ إِن كُنتُمْ لِلرُّءْيَا تَعْبُرُونَ ﴿٤٣﴾ قَالُوٓا۟ أَضْغَٰثُ أَحْلَٰمٍ ۖ وَمَا نَحْنُ بِتَأْوِيلِ
ٱلْأَحْلَٰمِ بِعَٰلِمِينَ ﴿٤٤﴾ وَقَالَ ٱلَّذِى نَجَا مِنْهُمَا وَٱدَّكَرَ بَعْدَ أُمَّةٍ أَنَا۠ أُنَبِّئُكُم بِتَأْوِيلِهِۦ فَأَرْسِلُونِ ﴿٤٥﴾ يُوسُفُ أَيُّهَا
ٱلصِّدِّيقُ أَفْتِنَا فِى سَبْعِ بَقَرَٰتٍ سِمَانٍ يَأْكُلُهُنَّ سَبْعٌ عِجَافٌ وَسَبْعِ سُنۢبُلَٰتٍ خُضْرٍ وَأُخَرَ يَابِسَٰتٍ لَّعَلِّىٓ
أَرْجِعُ إِلَى ٱلنَّاسِ لَعَلَّهُمْ يَعْلَمُونَ ﴿٤٦﴾ قَالَ تَزْرَعُونَ سَبْعَ سِنِينَ دَأَبًا فَمَا حَصَدتُّمْ فَذَرُوهُ فِى سُنۢبُلِهِۦٓ إِلَّا قَلِيلًا
مِّمَّا تَأْكُلُونَ ﴿٤٧﴾ ثُمَّ يَأْتِى مِنۢ بَعْدِ ذَٰلِكَ سَبْعٌ شِدَادٌ يَأْكُلْنَ مَا قَدَّمْتُمْ لَهُنَّ إِلَّا قَلِيلًا مِّمَّا تُحْصِنُونَ ﴿٤٨﴾ ثُمَّ يَأْتِى مِنۢ
بَعْدِ ذَٰلِكَ عَامٌ فِيهِ يُغَاثُ ٱلنَّاسُ وَفِيهِ يَعْصِرُونَ ﴿٤٩﴾ وَقَالَ ٱلْمَلِكُ ٱئْتُونِى بِهِۦ ۖ فَلَمَّا جَآءَهُ ٱلرَّسُولُ قَالَ ٱرْجِعْ إِلَىٰ
رَبِّكَ فَسْـَٔلْهُ مَا بَالُ ٱلنِّسْوَةِ ٱلَّٰتِى قَطَّعْنَ أَيْدِيَهُنَّ ۚ إِنَّ رَبِّى بِكَيْدِهِنَّ عَلِيمٌ ﴿٥٠﴾ قَالَ مَا خَطْبُكُنَّ إِذْ رَٰوَدتُّنَّ

يُوسُفَ عَن نَّفۡسِهِۦۚ قُلۡنَ حَٰشَ لِلَّهِ مَا عَلِمۡنَا عَلَيۡهِ مِن سُوٓءٖۚ قَالَتِ ٱمۡرَأَتُ ٱلۡعَزِيزِ ٱلۡـَٰٔنَ حَصۡحَصَ ٱلۡحَقُّ أَنَا۠
رَٰوَدتُّهُۥ عَن نَّفۡسِهِۦ وَإِنَّهُۥ لَمِنَ ٱلصَّٰدِقِينَ ٥١ ذَٰلِكَ لِيَعۡلَمَ أَنِّي لَمۡ أَخُنۡهُ بِٱلۡغَيۡبِ وَأَنَّ ٱللَّهَ لَا يَهۡدِي كَيۡدَ ٱلۡخَآئِنِينَ
٥٢ ۞ وَمَآ أُبَرِّئُ نَفۡسِيٓۚ إِنَّ ٱلنَّفۡسَ لَأَمَّارَةُۢ بِٱلسُّوٓءِ إِلَّا مَا رَحِمَ رَبِّيٓۚ إِنَّ رَبِّي غَفُورٞ رَّحِيمٞ ٥٣

មានន័យថា៖ (43)- រួចព្រះរាជាថា ការពិតយើងសុបិន ឃើញប្រាំពីរមេគោធាត់ៗកំពុងស៊ីពួកមេគោនោះ ដោយប្រាំពីរមេគោស្គមៗខ្លាំង ហើយប្រាំពីរកួរដែលខៀវ និងផ្សេងទៀតក្រៀមក្រោះ។ នែ៎! អ្នកមុខអ្នកការ ទាំងឡាយ ចូរពួកអ្នកឆ្លើយបញ្ជាក់មកយើង នៅក្នុងការសុបិននិមិត្តរបស់ យើងនេះ ប្រសិនបើពួកអ្នកទស្សន៍ទាយបានចំពោះឧគ្គហនិមិត្ត(សុបិន)នេះ។ (44)- ពួកគេថា នេះគឺជាសុបិនដ៏ច្របូកច្របល់គ្នា។ ហើយយើងពុំមែនជាពួកអ្នកដឹងនូវការកាត់ សុបិនទាំងឡាយទេ។ (45)- ហើយអ្នកដែលបានរួចផុតពីពន្ធនាគារក្នុងចំណោមគេទាំងពីរនាក់ ហើយទើបនឹងនឹកឃើញបន្ទាប់ពីមួយរយៈកាលបានថា ខ្ញុំនឹងជំរាបជូនពួកអ្នកនឹងការកាត់ សុបិននេះ ហេតុនេះ ចូរពួកអ្នកចាត់បញ្ជូនខ្ញុំទៅ។ (46)- ឱយូសុហ្វ! ឱអ្នកដែលនិយាយត្រង់ សូមអ្នកឆ្លើយមកយើងផង ក្នុងរឿងប្រាំពីរមេគោធាត់ៗ ដែលកំពុងស៊ីពួកវាដោយប្រាំពីរ មេគោស្គមៗខ្លាំង ហើយប្រាំពីរកួរដែលខៀវ ហើយផ្សេងទៀតក្រៀមក្រោះ សង្ឃឹមថា យើង នឹងត្រលប់ទៅកាន់មនុស្សទាំងឡាយវិញ សង្ឃឹមថាពួកគេនឹងបានដឹង។ (47)- យូសុហ្វថា ពួកអ្នកត្រូវដាំស្រូវប្រាំពីរឆ្នាំតាមធម្មតា រួចមក អ្វីដែលពួកអ្នកត្រូវបានច្រូតកាត់ ចូរពួកអ្នក ទុកវានៅក្នុងកួរវាបស់វា លើកលែងតែចំនួនបន្តិចបន្តួច នៃអ្វីដែលពួកអ្នកត្រូវបរិភោគ។ (48)- ក្រោយមក ប្រាំពីរឆ្នាំរាំងស្ងួតខ្លាំងនឹងមកដល់បន្ទាប់ពីរយៈពេលនោះ ដែលនឹងបរិភោគ នូវអ្វីដែលពួកអ្នកបានត្រៀមជាមុនសំរាប់រយៈពេលទាំងនោះ លើកលែងតែបន្តិចបន្តួចនៃ អ្វីដែលពួកអ្នកត្រៀមទុក។ (49)- ក្រោយមក នឹងមកដល់ទៀតបន្ទាប់ពីរយៈពេលនោះ នូវ ឆ្នាំមួយ ដែលពួកមនុស្សនឹងមានភ្លៀងបរិបូរ ហើយនៅឆ្នាំនោះ ពួកគេនឹងគាបទំពាំង បាយជូរ។ (50)- ព្រះរាជាថា ចូរពួកអ្នកនាំជននោះមក។ នៅពេលដែលនារសាព្រះរាជាបាន ទៅដល់យូសុហ្វ យូសុហ្វថា សូមអ្នកវិលទៅចៅហ្វាយអ្នកវិញ ចូរអ្នកសួរគាត់ថា សភាព យ៉ាងមេចទៅហើយ ពួកនារីដែលបានកាត់ដៃខ្លួនឯងនោះ? ការពិតម្ចាស់របស់យើង គឺជា អ្នកដឹងបំផុតនូវល្បិចកលរបស់ពួកនាង។ (51)- ព្រះរាជាថា រឿងរ៉ាវរបស់ពួកនាងយ៉ាងដូចម្តេច ដែរ នៅពេលដែលពួកនាងបានលួងលោមយូសុហ្វចង់បានខ្លួនរបស់គេនោះ?។ ពួកនារីទាំង នោះថា មហាបរិសុទ្ធចំពោះអល់ឡោះ

យើងឥតមានដឹងនៅលើរឿងនោះនៃអកុសលណា មួយទេ។ ភរិយារបស់អាហ្សីសបាននិយាយថា បច្ចុប្បន្នរឿងពិតបានលេចតាំងឡើងហើយ យើងបានល្បងប្រលោមគេពីខ្លួនគេផ្ទាល់ ហើយគេពិតជាក្នុងចំណោមពួកអ្នកនិយាយ ត្រង់មែន។ (52)- ទាំងនោះ ដើម្បីគេនឹងដឹងថា យើងពិតជាមិនក្បត់គេដោយកំបាំងមុខនោះ ទេ ។ ហើយអល់ឡោះ ពិតជានឹងមិនចង្អុលបង្ហាញឡើយចំពោះល្បិចកលពួកក្បត់។ (53)- ខ្ញុំនឹងមិនថាខ្លួនខ្ញុំស្អាតស្អំនោះទេ។ ជាការពិតណាស់ កិលេសតណ្ហា ប្រាកដជាត្រួតត្រាយ៉ាងខ្លាំងដោយ អកុសល លើកលែងតែអ្វីដែលម្ចាស់របស់ខ្ញុំបានអាណិតអាសូរ ។ ការពិតម្ចាស់របស់ខ្ញុំជាអ្នកអភ័យទោស ឱ្យ ជាអ្នកអាណិតអាសូរបំផុត។

ចាប់ពីថ្ងៃដែលយូសុះបានធ្វើការកាត់សុបិនជូនស្តេចរួចមក ស្តេចអង្គនោះហបីដូច ពេញចិត្តពេញថ្លើម ស្រលាញ់ចូលចិត្តយូសុះ ហើយស្តេចអង្គនោះតែងតែគិតថា បុរសម្នាក់ដែលទើបតែចេញពីការឃុំឃាំងទាំងគ្មានកំហុសនោះ អាចមានសមត្ថភាពខ្ពស់ស្របពេលដែលស្តេចអង្គនោះកំពុងត្រូវការនឹងស្វែងរកអ្នកដែលសាកសមដើម្បីបំរើការងារក៏ដូចជាជួយការងារផ្សេងៗរបស់ខ្លួន ស្តេចអង្គនោះក៏បានលើកយូសុះឲ្យធ្វើជាមន្ត្រីម្នាក់ក្នុងចំណោមមន្ត្រីដ៏ទៃផ្សេងទៀត ហើយយូសុះមានតួនាទីសំខាន់ជាងគេ គឺយូសុះធ្វើជាអ្នកប្រឹកសារយោបល់ដល់ស្តេចផ្ទាល់ ដោះស្រាយរាល់បញ្ហាដែលពិបាក ធ្វើការសន្និដ្ឋាន ទស្សទាយផ្សេងៗក្នុងប្រទេសអេហ្ស៊ីប ជាពិសេសរាល់ករណីណាមួយសែលស្តេចត្រូវការជំនួយពីមន្ត្រីរបស់ខ្លួន។ ដោយភាពឆ្លាតវ័យរបស់យូសុះ នឹងការចង្អុលបង្ហាញពីអល់ឡោះ យូសុះបានបំពេញតួនាទីរបស់ខ្លួនមិនដែលខុសឆ្គងម្តងណាឡើយ គួបផ្សំនឹងសិលធម៌ អកប្បកិរិយាដ៏ប្រពៃ នឹងអង់អាចក្លាហានរបស់យូសុះថែមទៀតនោះ ពីមួយថ្ងៃទៅមួយថ្ងៃ ដោយភាពបិនប្រសប់ ភាពឆ្លាតវ័យ នឹងតៀងត្រង់របស់យូសុះផងដែនោះ បានធ្វើឲ្យស្តេចអង្គនោះគោរពស្រលាញ ពេញចិត្តយូសុះកាន់តែខ្លាំងឡើងៗ។ ជាច្រើនឆ្នាំក្រោយមកដោយភាពចាស់ជរា នឹងទ្រុឌទ្រោមរបស់ស្តេច ជាពិសេសដោយសារស្តេចអង្គនោះមើលឃើញថាការដឹកនាំរបស់ខ្លួនមិនអាចទៅមុខរួចតទៅទៀត ដោយសារបញ្ហាសុខភាពផង នឹងចាស់ជរាផងនោះ ស្តេចអង្គនោះបាន

សម្រេចចិត្តប្រគល់បាលាំង អំណាចជាស្តេចរបស់ខ្លួន ឲ្យទៅយូសុះដើម្បីគ្រងរាជធ្វើជាស្តេចជំនួសខ្លួន ដឹកនាំប្រជារាស្ត្របន្ត។ ដោយយូសុះមិនអាចប្រកែកនឹងរាជបញ្ជារបស់ស្តេចបាន យូសុះបានព្រមទទួលយករាជប្រទានរបស់ស្តេចអង្គនោះដើម្បីបន្តដឹកនាំគ្រប់គ្រងប្រទេសជាតិជំនួសតាំងពីថ្ងៃនោះមក។

យូសុះទទួលមុខជារជាស្តេចអេហ្ស៊ីប



នៅថ្ងៃមួយស្តេចអង្គនោះបានសម្រេចចិត្តហៅអស់មន្ត្រីទាំងឡាយរបស់ខ្លួន អ្នកមានមុខមាត់ក្នុងសង្គម អ្នកចេះដឹងខ្ពង់ខ្ពស់ ជាពិសេសសាច់សាលោហិតរាជវង្សរបស់ស្តេចអង្គនោះ ឲ្យមកជួបជុំគ្នានៅក្នុងរាជវាំងរបស់ខ្លួន ដើម្បីពិភាគសារអំពីការប្រគល់តួនាទីជាស្តេចអំណាច នឹងបាលាំងរបស់ខ្លួនឲ្យទៅយូសុះ នៅក្នុងកម្មវិធីនោះ គ្មានមន្ត្រីណាមួយដែលបដិសេធចំពោះការសម្រេចចិត្តរបស់ស្តេចនឹងប្រគល់អំណាចឲ្យទៅយូសុះធ្វើជាស្តេចនោះទេ ពួកគេម្នាក់ៗលើកដៃគាំទ្រទាំងពេញចិត្តនឹងបន្តជួយជ្រុំជ្រែងយូសុះក្នុងការងារជាស្តេចថែមទៀតផង។ នៅថ្ងៃនោះផងដែ បន្ទាប់ពីបានពិភាគសារចប់សប់គ្រប់រួច ស្តេចអង្គនោះបានប្រកាស់ជាសធារណៈថា នឹងប្រគល់បាលាំងរបស់ខ្លួនជាស្តេច សិទ្ធិនឹងអំណាច ទ្រពសម្បត្តិផ្សេងៗដែលជាធនធានរបស់រាជាឲ្យទៅយូសុះ ហើយលើកយូសុះធ្វើជាស្តេចតែម្តង។ ស្តេចអង្គនោះបានចុះពីលើបាលាំងនឹងបានប្រគល់ចិញ្ចៀនមួយវង់ដែលជាចិញ្ចៀនដំណាងជាស្តេចឲ្យទៅយូសុះដើម្បីបញ្ជាក់ថា ចាប់ពីពេលនោះតទៅយូ

សុះគឺជាស្តេចគ្រប់គ្រងអស់មន្ត្រីតូចធំ ប្រជារាស្ត្រ ទឹកដី នឹងគ្រប់ហេត្ថារច្ចនាសម្ព័នផ្សេងៗដែលមានក្នុងប្រទេសអេហ្ស៊ីបទាំងមូល។

បន្ទាប់ពីកម្មវិធីប្រគល់អំណាចជាស្តេចរួចរាល់ហើយ ស្តេចអង្គនោះបានរៀបចំអាពាហ៍ពិពាហ៍មួយជូនយូសុះជាមួយនាងស៊ូឡែខផងដែរ ដោយអាពាហ៍ពិពាហ៍នោះរៀបចំដោយស្តេចផ្ទាល់ នឹងអញ្ជើញអស់មន្ត្រីដែលចូលរួមក្នុងកម្មវិធីប្រគល់បាលាំងជាស្តេចរបស់យូសុះនោះចូលរួមតែម្តង។ នៅក្នុងកម្មវិធីរៀបអាពាហ៍ពិអាហ៍យូសុះបាននិយាយទៅកាន់ភរិយារបស់ខ្លួន នាងស៊ូឡែខថា៖ *ឱស៊ូឡែខ.. តើអ្នកនឹងគិតទេថា នេះគឺជាអ្វីដែឡល្អសម្រាប់ខ្ញុំនឹងអ្នកជាជាងអ្វីដែលអ្នកបានធ្វើដូចកាលមុន? ស៊ូឡែខឆ្លើយតបថា៖ ឱប្តីរបស់ខ្ញុំដែលល្អ សូមកុំជៀលរំលឹកនូវអ្វីដែលកើតឡើងអតីតៈកាល ព្រោះវាគឺជាភាពវង្វេងរបស់ខ្ញុំចំពោះ ដោយសារខ្ញុំមិនអាចគ្រប់គ្រងនឹងតណ្ហារបស់ខ្លួនមិនថាពេលដែលខ្ញុំឃើញអ្នកម្តងៗ។ អ្នកនឹងយល់ ខ្ញុំគឺជាស្ត្រីម្នាក់ដែលស្អាតលើសស្ត្រីទាំងឡាយ ហើយក្មេង ឯប្តីរបស់ខ្ញុំ (ប្តីមុន) គឺជាបុរសម្នាក់ដែលចាស់ទុកខ្សោយ គេអាចផ្តល់តម្រូវការគ្រប់គ្រាន់ក្នុងពេលរួមដំនេកសម្រាប់ខ្ញុំឡើយ។*

ចាប់តាំងពីពេលនោះមក យូសុះនឹងនាងស៊ូឡែខបានរួមរស់ជាមួយគ្នាជាប្តីប្រពន្ធក្នុងវាំង និងបានរួមគ្នាដឹកនាំប្រទេសជាតិ ប្រជារាស្ត្រ ផ្តល់សេចក្តីសុខស្លាម៉ាត់ សុខក្សេមក្សាន្តជូនប្រទេសជាតិទាំងមូល។ យូសុះនឹងស៊ូឡែខបានដឹកនាំមន្ត្រីរបស់ខ្លួនចុះត្រួតពិនិត្យ សួរសុខទុក្ខ ដោះស្រាយរាល់បញ្ហារបស់ប្រជារាស្ត្រពីតំបន់មួយទៅកាន់តំបន់មួយផ្សេងទៀតជារៀងរាល់ថ្ងៃមិនដែលខានឡើយ។ យូសុះបានជម្រុញឲ្យប្រជារាស្ត្ររបស់ខ្លួនបង្កបង្កើនផល់ដំណាំកសិកម្ម មុខជំនួញផ្សេងៗក្នុងរដូវដែលមានទឹកនឹងធមជាតិគ្រប់គ្រាន់មុនពេលរដូវប្រាំង (រដូវរាំងស្ងួតហួតហែងដូចដែលស្តេចសុបិនឃើញហើយយូសុះកាត់សុបិនឃើញនោះ) ចូលមកដល់ ពោល គឺត្រូវត្រៀម

ស្បៀងក្នុងរយៈពេលប្រាំពីរឆ្នាំនាពេលរដូវប្រាំងនោះចូលមកដល់។ ប៉ុន្មានឆ្នាំក្រោយមក រដូចបាំងប្រាំងនោះកចូលមកដល់ដូចការសុបិនរបស់ស្តេច នឹងបានទស្សទាយដោយយូសុះ ប៉ុន្តែដោយសារបានដឹងមុន និងបានត្រៀមអ្វីៗគ្រប់យ៉ាងជាស្បៀងសម្រាប់ទប់ទល់ក្នុងរយៈពេលប្រាំពីរឆ្នាំរដូចនោះ គ្មានប្រជារាស្ត្រណាមួយដែលពិបាកខ្វះខាតស្បៀងនោះទេ ពួកគេមានអាហារស្បៀងគ្រប់គ្រាន់សម្រាប់ដោះស្រាយជីវៈភាពរបស់ពួកគេក្នុងរយៈពេលប្រាំពីរឆ្នាំនោះ។ ជាបន្តបន្ទាប់ យូសុះនឹងស៊ូឡៃខទទួលបានបុត្រាពីរនាក់ គឺ៖ អ៊ីហ្វ្រាស្សីម និង ម៉ីហ្សា។ ដូចអល់ឡោះបានពោលនៅក្នុងគម្ពីរអាល់កូរអានក្នុងស៊ូរ៉ោះយូសុះ អាយ៉ាត់ 54-57 ថា៖

وَقَالَ ٱلْمَلِكُ ٱئْتُونِى بِهِۦٓ أَسْتَخْلِصْهُ لِنَفْسِى ۖ فَلَمَّا كَلَّمَهُۥ قَالَ إِنَّكَ ٱلْيَوْمَ لَدَيْنَا مَكِينٌ أَمِينٌ ﴿٥٤﴾ قَالَ ٱجْعَلْنِى عَلَىٰ خَزَآئِنِ ٱلْأَرْضِ ۖ إِنِّى حَفِيظٌ عَلِيمٌ ﴿٥٥﴾ وَكَذَٰلِكَ مَكَّنَّا لِيُوسُفَ فِى ٱلْأَرْضِ يَتَبَوَّأُ مِنْهَا حَيْثُ يَشَآءُ ۚ نُصِيبُ بِرَحْمَتِنَا مَن نَّشَآءُ ۖ وَلَا نُضِيعُ أَجْرَ ٱلْمُحْسِنِينَ ﴿٥٦﴾ وَلَأَجْرُ ٱلْءَاخِرَةِ خَيْرٌ لِّلَّذِينَ ءَامَنُوا۟ وَكَانُوا۟ يَتَّقُونَ ﴿٥٧﴾

មាននំយថា៖ (54)- ព្រះរាជាបានថា ចូរពួកអ្នកនាំយូសុហ្វមកកាន់យើង យើងប្រាកដជា នឹងទុកគេដោយខ្លែកសម្រាប់ខ្លួនយើងផ្ទាល់។ លុះនៅពេលដែលព្រះរាជា បាននិយាយទៅកាន់គាត់ ព្រះរាជាថា ការពិតអ្នកនៅថ្ងៃនេះនៅជិតយើង ជាអ្នកដែលមានអំណាចពេញជាទីទុកចិត្តបំផុត។ (55)- យូសុហ្វថា សូមលោកចាត់តាំងខ្ញុំឱ្យទទួលខុសត្រូវគន:សម្បត្តិនៃផែនដី។ ការពិត ខ្ញុំជាអ្នកដែលថែ ការពារ ហើយក៏ជាអ្នកដឹងដែរ។ (56)- ប្រៀបបីដូចទាំងនេះហើយ ដែលយើងបានទុកជាក់ឱ្យយូសុហ្វនៅឯ ផែនដី គេនឹងតាំងលំនៅភាគខ្លះនៃផែនដីតាមតែគេប្រាថ្នា ។ យើងនឹងនាំក្តីអាណិតអាសូរបស់យើងទៅ ប៉ះត្រូវអ្នកដែលយើងប្រាថ្នា។ ហើយយើងក៏មិនធ្វេសប្រហែសដែរ នូវរង្វាន់របស់ពួកអ្នកសាងកុសល។ (57)- រង្វាន់នៃអវសានលោក ប្រាកដជាការប្រសើរមួយសំរាប់ពួកដែលមានជំនឿ ហើយពួកគេកោតខ្លាច។

ណាពីយូសុះជួបជុំក្រុមគ្រួសារ

បន្ទាប់ពីយូសុះបានឡើងធ្វើជាស្តេចគ្រប់គ្រងលើប្រទេសអេហ្ស៊ីបទាំងមូល នឹងបានអំពាវនាវឲ្យប្រជារាស្ត្ររបស់ខ្លួនបង្កបង្កើនផល់ ដាំដំណាំកសិកម្ម គ្រប់មុខជំនួញ រកស៊ីអាជីវកម្មផ្សេងៗក្នុងរដូវវស្សា ដើម្បីជាស្បៀងត្រៀមប្រឈមនឹងគ្រោះទុរភិក្ខនារដូវប្រាំងដែលនឹងមកដល់នាពេលខាងមុខរយៈពេលប្រាំពីរឆ្នាំ ដូចដែលយូសុះបានទស្សទាយសុបិនរបស់ស្តេចមុន។ មិនយូប៉ុន្មានរដូវប្រាំង អាកាស់ធាតុក្តៅហួតហែងគ្មានទឹក គ្រប់រុក្ខជាតិក្រៀមស្វិត គ្រប់ដំណាំកសិកម្មផ្សេងៗដែលធ្លាប់តែរីកស្រស់ខៀវស្រងាត់ប្រែជាក្រៀមស្វិត បានចូលមកដល់។ ប្រជារាស្ត្ររបស់យូសុះបានត្រៀមជាស្រេចទាំងអស់គ្មានភាពកង្វះខាតណាមួយកើតមានចំពោះពួកគេឡើយ លើសពីនេះយូសុះបានត្រៀមទុកក្នុងឃ្លាំងរាជការរបស់ខ្លួនសម្រាប់អ្នកដែលខ្វះខាត ដើម្បីទប់ទល់នឹងគ្រោះទុរភិក្ខពេញប្រាំពីរឆ្នាំផងដែ។ មិនយូប៉ុន្មានក្រោយមក ដោយមានប្រជារាស្ត្រយូសុះមួយចំនួនមានភាពកង្វះខាត យូសុះបានបើកប្រកាស់លក់ស្បៀងក្នុងឃ្លាំងរបស់ខ្លួនលក់ក្នុងតំលៃហោកថូថ្លៃសំរាប់អ្នកត្រូវការស្បៀងជាចាំបាច់ក្នុង មិនថាប្រជារាស្ត្ររស់នៅក្នុងប្រទេសអេហ្ស៊ីប រឺប្រជារាស្ត្រក្នុងបណ្តាប្រទេសផ្សេងដែលមានព្រំប្រទល់ជាប់នឹងប្រទេសដែលគ្រប់គ្រងដោយយូសុះនោះទេ ក្នុងនោះជារួមមានទាំងប្រជាជនមកពីប៉ាឡេស្ទីន ដែលជាប្រទេសយ៉ាកូបនិងបងប្អូនរបស់យូសុះរស់នៅផងដែ។ នៅពេលដែលក្រុមគ្រួសារយូសុះទទួលបានដំណឹងថា ស្តេចប្រទេសអេហ្ស៊ីបបានបើកឃ្លាំងរបស់ខ្លួនដើម្បីលក់ស្បៀងជូនប្រជារាស្ត្រក្រីក្រ ដោយមិនរើសអើងជនជាតិ ពូជសាស្ត្រ ប្រទេសពោល សំរាប់អ្នកដែលត្រូវការ ភាពចាំបាច់ កង្វះខាត់នោះ នឹងដោយពេលនោះក្រុមគ្រួសាររបស់យូសុះកំពុងជួបនឹងកង្វះខាតស្បៀងផងនោះ បងប្អូនយូសុះទាំង១០នាក់បានចាកចេញពីក្រុមគ្រួសារនៅប៉ាឡេស្ទីន ដោយធ្វើដំណើរឆ្ពស់ទៅកាន់ប្រទេសអាហ្ស៊ីប ដើម្បីទិញស្បៀងពីស្តេចយូសុះ។ ពេលទៅដល់អេហ្ស៊ីប នឹងដោយយូសុះខ្លួនឯងជា

អ្នកចាត់ចែងលក់ស្បៀងទាំងនោះដោយខ្លួនឯងផងដែរនោះ បងប្អូនយូសុះទាំង១០នាក់បានជួបនឹងយូសុះ ប៉ុន្តែពួកគេមិនបានដឹងថាស្តេចអង្គនោះគឺជាយូសុះប្អូនរបស់ពួកខ្លួន ដែលពួកគេធ្លាប់ចាប់ទំលាក់ក្នុងអណ្តូងនោះទេ ចំណែកយូសុះវិញដឹងយ៉ាងច្បាស់ថា ពួកគេគឺជាបងៗរបស់ខ្លួន។ នៅចំពោះមុខយូសុះ ម្នាក់ក្នុងចំណោមពួកគេបាននិយាយទៅកាន់យូសុះថា៖

បងប្អូនយូសុះ: *ឪចៅហ្វាយជាទីគោរព.. យើងខ្ញុំទាំងអស់គ្នាគឺជាកូនៗរបស់ណាពីយ៉ាកូប មកពីប្រទេសប៉ាឡេស្ទីន ដែលមានបងប្អូនចំនួន12នាក់។*

យូសុះ : *អ្វីដែលយើងឃើញមាននៅទីនេះ គឺមានចំនួនតែ១០នាក់ប៉ុណ្ណោះ ឯណាទៅពីរនាក់ទៀត រីមួយពួកអ្នកទាំងអស់គ្នាគឺជាពួកនិយាយកហុក?*

បងប្អូនយូសុះ: *ជាការពិតណាស់ ម្នាក់ក្នុងចំណោមពួកយើងខ្ញុំទាំងគ្នា១២នាក់ ឈ្មោះយូសុះ និងម្នាក់ទៀតជាប្អូនប្រុសពៅ គឺពុនយ៉ាមុនបាននៅផ្ទះដើម្បីមើលថែរក្សាឪពុករបស់យើងខ្ញុំយ៉ាកូបដែលចាស់ជរា ម្យ៉ាងវិញទៀតលោកមិនអនុញ្ញាតឲ្យប្អូនប្រុសពៅរបស់យើងខ្ញុំចេញដំណើជាមួយពួកយើងទេ ដោយសារប្អូនពៅរបស់យើងខ្ញុំគឺជាកូនដែលលោកស្រលាញ់ នឹងយកចិត្តទុកដាក់បំផុត បន្ទាប់ពីម្នាក់ក្នុងចំណោមបងប្អូនរបស់យើងខ្ញុំ១២នាក់ឈ្មោះយូសុះ បានបាត់ខ្លួនអស់រយៈកាលជាច្រើនឆ្នាំមកហើយ ឯឪពុករបស់យើងខ្ញុំវិញ ដោយសារបាត់បង់កូនជាទីស្រលាញ់របស់លោក (យូសុះ) ចាប់ពីថ្ងៃនោះមក ធ្វើឲ្យលោកធ្លាក់ខ្លួនឈឺ សម្រក់ទឹកភ្នែកជារៀងរាល់ថ្ងៃរហូតបណ្តាលឲ្យភ្នែករបស់លោកពិការមើលអ្វីមិនឃើញ ហើយបច្ចុប្បន្នដោយហេតុនៅឯស្រុករបស់យើងខ្ញុំកំពុងជួបបញ្ហាស្បៀង យើងខ្ញុំបានសំការអនុញ្ញាតពីលោកឪពុករបស់*

យើងខ្ញុំឲ្យមកកាន់ទីនេះ ដើម្បីសំដែងនឹងទិញស្បៀងពីចៅហ្វាយ ដើម្បីផ្តត់ផ្តង់ក្រុមគ្រួសារ។

យ៉ូសុះ *៖ ជាការពិតណាស់ តាមការវិភាគនឹងប៉ាន់ស្មានរបស់យើង ពួកអ្នកទាំងអស់គ្នាគឺជាពួកដែលនិយាយមិនពិត យើងមិនជឿនូវអ្វីដែលពួកអ្នករៀបរាប់ប្រាប់យើងនោះទេ ប្រសិនបើពួកអ្នកមានភស្តុតាងណាមួយបញ្ជាក់ថា អ្វីដែលពួកនិយាយនោះគឺជាការពិត ទើបយើងលក់ស្បៀងរបស់យើងជូនពួកអ្នក ចូរពួកអ្នករកសាក្សី រឺអ្នកធានាអះអាងថាពួកអ្នកគឺជាបុត្រារបស់ណាពីយ៉ាកូនទើបយើងជឿជាក់។*

ចចប្អូនយ៉ូសុះ៖ *ជីស្តេចជាទីគោរព.. ពួកយើងទាំងអស់គ្នាជាអ្នកធ្វើដំណើរពីប្រទេសប៉ាឡេស្ទីន ពួកយើងមិនបានស្គាល់នរណាម្នាក់នៅទីនេះក្រៅពីបងប្អូនរបស់យើងខ្ញុំទាំង១០នាក់នេះទេ សូមចៅហ្វាយមេត្តាលក់ស្បៀងរបស់ចៅហ្វាយដល់ពួកយើងខ្ញុំផង ដើម្បីយើងខ្ញុំបានពាំនាំផ្តត់ផ្តង់ក្រុមគ្រួសារដែលកំពុងជួបកង្វះខាតស្បៀង។*

យ៉ូសុះ *៖ បើសិនជាពួកអ្នកពុំមានអ្នកធានា រឺភស្តុតាងត្រឹមត្រូវដែលយើងអាចទទួលយកបាន ទើបយើងព្រមលក់ស្បៀងទាំងនេះជូនពួកអ្នក បើពុំដូច្នោះទេ យើងនៅតែគិតថាពួកអ្នកគឺជាជនបង្កប់ ជាសត្រូវ ដែលគេចាត់តាំងឲ្យមកសើបការណ៍ដើម្បីផ្តល់ពត៌មានទៅកាន់ពួកសត្រូវរបស់យើងជាក់ជាពុំខាន។*

ចចប្អូនយ៉ូសុះ៖ *ចៅហ្វាយជាទីគោរព.. សូមទ្រង់មេត្តាផ្តល់ជាគំនិតយោបល់ នឹងចង្អុលបង្ហាញ តើពួកយើងគួរធ្វើយ៉ាងណាដើម្បីឲ្យទ្រង់ព្រមជឿជាក់ជាភស្តុតាង ហើយព្រមលក់ស្បៀងដល់ពួកយើង ?។*

យ៉ូស្វ ៖ ពួកអ្នកទាំងអស់គ្នាបាននិយាយថា ពួកអ្នកនៅមានប្អូនប្រុសពៅម្នាក់ទៀត ឈ្មោះពុនយ៉ាមុីននៅឯផ្ទះ ដើម្បីមើលការខុសត្រូវនឹងថែរក្សាលោកឪពុកដែលចាស់ជរា នឹងខ្វាក់ភ្នែក ដូច្នោះយើងព្រមលក់ស្បៀងបន្ទិចបន្ទួចគ្រប់សម្រាប់ប្រើប្រាស់ក្នុងរយៈពេលដែលពួកអ្នកត្រលប់ទៅផ្ទះវិញ ហើយពួកអ្នកប្រញ៉ាប់មកជួបនឹងយើងវិញដោយនាំមកជាមួយប្អូនពៅរបស់ពួកអ្នក រួចយើងនឹងលក់ស្បៀងរបស់យើងបន្ថែមឲ្យពួកអ្នកតាមចំនួនដែលពួកអ្នកត្រូវការ។

បងប្អូនយ៉ូស្វ៖ បរពិតចៅហ្វាយ... ពួកយើងមានការព្រួយបារម្ភណ៍ចំពោះការស្នើសុំរបស់ពួកយើងពីលោកឪពុក ដើម្បីនាំពុនយ៉ាមុីនមកជួបនឹងចៅហ្វាយតាមការសន្យាពីព្រោះខ្លាចក្រែងឪពុករបស់យើងខ្ញុំមិនអនុញ្ញាត ដោយមូលហេតុ បន្ទាប់ពីយ៉ូសុះបងបន្ទាប់របស់ពុនយ៉ាមុីនបានបាត់ខ្លួនពីផ្ទះរួចមក លោកឪពុករបស់ពួកយើងហាបីដូចព្រួយបារម្ភណ៍ចំពោះសុវត្ថភាពពុនយ៉ាមុីន ដោយលោកខ្លាចបាត់បង់ពុនយ៉ាមុីនម្នាក់ទៀត ប៉ុន្តែទុះជាយ៉ាងណា ប្រសិនបើទ្រង់ដាក់លក្ខ័ណបែបនោះទៅហើយ ពួកយើងទាំងអស់គ្នានឹងព្យាយាម សុំការអនុញ្ញាតពីលោកឪពុករបស់ពួកយើង ដើម្បីនាំពុនយ៉ាមុីនមកកាន់ទីនេះជួបជាមួយទ្រង់ដើម្បីធ្វើជាភស្តុតាង។

បន្ទាប់ពីយ៉ូសុះនឹងបងប្អូនរបស់គេទាំង១០នាក់ ដែលមិនស្គាល់ថាជាយ៉ូសុះប្អូនប្រុសរបស់ពួកខ្លួននោះ បានចចារនិយាយគ្នាទៅវិញទៅមកហើយ យ៉ូសុះបានបញ្ជាឲ្យក្រុមការងាររបស់ខ្លួនវាល់ស្បៀងលក់ជូនពួកគេទាំង១០នាក់ និងបានលួចបង្កប់ប្រាក់ដែលជាថ្លៃទិញស្បៀងនោះចូលទៅក្នុងស្បៀងនោះវិញ ហើយពួកគេទាំង១០នាក់កចាកចេញពីយ៉ូសុះដោយមិនដឹងថាយ៉ូសុះលួចបង្កប់ប្រាក់ដែលជាថ្លៃដែលពួកគេទិញស្បៀងនោះវិញទេ ហើយនឹកគិតសង្ឃឹមថាពេលដល់ផ្ទះពួកគេនឹងរីករាយជាមួយក្រុមគ្រួសារ

ដោយបានទិញស្បៀងក្នុងតំលៃថោក និងអាចសំពីឪពុករបស់ខ្លួនដើម្បីនាំពុនយ៉ាមុនទៅជួបយូសុះតាមការសន្យា។

ជាការពិតណាស់ ក្នុងចិត្តរបស់យូសុះនិងទង្វើរបស់គេចំពោះពួកគេទាំង១០នាក់នោះមិនមែនដើម្បីសងសឹកចំពោះពួកគេវិញនោះទេ ដែលពួកគេធ្លាប់ធ្វើបាប ប៉ុនប៉ងសម្លាប់រហូតបណ្តាលឲ្យយូសុះធ្លាក់ខ្លួនក្លាយជាក្មេងអនាថា គ្មានផ្ទះសំបែងរស់នៅ ខ្វះភាពកក់ក្តៅ នឹងត្រូវគេលក់ដូចសត្វធាតុ លំបាក ព្រាត់ប្រាស់ពីឪពុកជាទីស្រលាញ្ជាកាលពីមុនមក ផ្ទុយទៅវិញទាំងអស់ខាងលើដែលយូសុះដាក់លក្ខ័ណចំពោះពួកគេទាំង១០នាក់នោះ ពោល គឺដើម្បីឲ្យពួកគេនាំពុនយ៉ាមុន និងយ៉ាកូបមកជួបខ្លួន នឹងដឹងពីសុខទុក្ខរបស់ពួកគេទាំងពីរនៅឯផ្ទះប៉ុណ្ណោះ។

ពេលពួកគេទាំង១០នាក់បានពាំនាំស្បៀងទៅដល់ផ្ទះ ពួកគេបានរៀបរាប់គ្រប់ដំណើរឿងរ៉ាវពួកគេនិងយូសុះប្រាប់ទៅឪពុករបស់ខ្លួន។ ម្នាក់ក្នុងចំណោមបងប្អូនទាំង១០នាក់បាននិយាយថា៖ *ឪលោកឪពុកជាទីស្រលាញ្ជ.. ជាការពិតណាស់ ស្តេចរបស់ប្រទេសអេហ្ស៊ីបដែលព្រមលក់ស្បៀងអោយយើងនេះ គឺជាស្តេចដែលមានចិត្តល្អ មេត្តាករុណា នឹងជាទីគោរពណាស់ លោកបានលក់ស្បៀងឲ្យពួកយើងក្នុងតំលៃថោកបំផុត ប៉ុន្តែដោយសារពួកយើងគឺជាជនខាងក្រៅ (មិនមែនប្រជារាស្ត្រអេហ្ស៊ីប) លោកមិនបានអនុញ្ញាតលក់ឲ្យពួកយើងតាមចំនួនដែលយើងចង់បាននោះទេ គឺលោកបានលក់ជូនបន្តិចបន្តួចជាស្បៀងបណ្តុះអាសន្ន ហើយបើសិនជាពួកយើងអាចនាំពុនយ៉ាមុនទៅជួបនឹងស្តេចអង្គនោះជាទ្រពធានានឹងជាកស្តុតាង ស្តេចនោះបានសន្យាថា និងលក់ស្បៀងឲ្យពួកយើងតាមចំនួនដែលយើងចង់បាន ហើយក្នុងតំលៃថោកបំផុត។*

បន្ទាប់ពីពួកគេបានទៅដល់ផ្ទះ បានសម្រាកនឹងបានរៀបរាប់ប្រាប់លោកឪពុករបស់ខ្លួនអំពីគ្រប់រឿងរ៉ាវដែលកើតមានក្នុងអំឡុងពេលពួកគេជួបយូសុះ ពួកគេបានរើសស្បៀង

ដែលយូសុះលក់ឲ្យនោះ ស្រាប់តែពួកគេបានឃើញប្រាក់ដែលពួកគេយកពីផ្ទះនឹងបានប្រគល់ជូនយូសុះជាថ្លៃស្បៀងនោះ ធ្វើឲ្យពួកគេទាំង១០នាក់ និងយ៉ាកូបឆ្ងល់រួមទាំងសប្បាយចិត្តផង ហើយម្នាក់ក្នុងចំណោមពួកគេបាននិយាយថា៖ *លោកឪពុកមើលចុះ នេះគឺជាប្រាក់ដែលពួកយើងយកពីផ្ទះដើម្បីទិញស្បៀងពីស្តេចអេហ្ស៊ីប ប៉ុន្តែបែជាស្បៀងទាំងនេះស្តេចយូសុះបានប្រគល់ជូនពួកយើងវិញដោយមិនដឹងខ្លួន។* ជាការពិណាស់ អ្វីដែលយូសុះលួចបង្កប់ប្រាក់នោះចូលក្នុងស្បៀងរបស់ពួកគេវិញ គឺដើម្បីឲ្យប្រាកដថា នៅពេលដែលយ៉ាកូបបានឃើញប្រាក់នោះវិញ យ៉ាកូបប្រាកដជារួមដំណើរជាមួយពួកកូនៗដើម្បីទៅជួបខ្លួននៅប្រទេសអេហ្ស៊ីប ព្រោះយ៉ាកូបគឺជាមនុស្សម្នាក់ដែលមានចិត្តទៀងត្រង់ យុត្តិធម៌ មិនដែលចង់បានរបស់នរណាម្នាក់ឡើយ ហើយយូសុះនឹកគិតថា ពេលដែលយ៉ាកូបឃើញហើយ យ៉ាកូបប្រាកដជាមិនទុកចិត្តពួកគេទាំង១០នាក់នោះឡើយ ពួកគេហ៊ានធ្វើបាបយូសុះ ដូច្នោះដៃពួកគេកហ៊ានបោកប្រាស់គេឯងដែ។

ទុះជាយ៉ាកូបបានលឺការរៀបរាប់របស់ពួកកូនទាំង១០នាក់យ៉ាងដូច្នោះក៏ដោយ យ៉ាកូបនៅតែប្រកែកមិនព្រមអនុញ្ញាតឲ្យពុនយ៉ាមីនរួមដំណើជាមួយពួកគេទៅកាន់ប្រទេសអេហ្ស៊ីបតាមការសន្យារបស់ពួកគេជាមួយនឹងយូសុះនោះទេ ព្រោះយ៉ាកូបភ័យក្លាចអ្វីៗនឹងអាចកើតមានឡើងដូចយូសុះម្នាក់ទៀត ការបាត់បង់យូសុះគឺជាការបាត់បង់កូនម្នាក់ដ៏ស្រលាញ់មួយ បើសិនជាយ៉ាកូបបាត់បង់ពុនយ៉ាមីនម្នាក់ទៀត យ៉ាកូបពិតជាបាត់បង់អ្វីៗគ្រប់យ៉ាងដែលខ្លួនមាន។ ពីមួយថ្ងៃទៅមួយថ្ងៃ ដោយហេតុស្បៀងដែលស្តេចយូសុះលក់ឲ្យបន្តិចបន្តួចនោះកាន់ខ្ចីចទៅៗ យ៉ាកូបបានពិចារណាឡើងវិញម្តងទៀត នឹងដោយមានការព្រួយបារម្ភណ៍ចំពោះភាពកង្វះខាតស្បៀងទៅថ្ងៃខាងមុខ និងដោយសារឆ្ងល់និងប្រាក់ដែលមានក្នុងស្បៀងនោះ យ៉ាកូបបានសម្រេចចិត្តអនុញ្ញាតឲ្យពុនយ៉ាមីនរួមដំណើជាមួយក្រុមបងៗ រួមទាំងយ៉ាកូបផងធ្វើដំណើរួមគ្នាឆ្ពស់ទៅកាន់

ប្រទេសអេហ្សិបដើម្បីជួបជាស្តេចយូសុះ នឹងសំទិញស្បៀងបន្ថែមតាមចំនួនដែលពួកគេត្រូវការ។ មិនយូប៉ុន្មានក្រោយមក ស្បៀងជិតអស់ពីផ្ទះ យ៉ាកូបបានដឹកនាំពួកកូនៗប្រជុំនឹងសម្រេចជ្រើសរើសយកថ្ងៃដែលត្រូវធ្វើដំណើរទៅកាន់ប្រទេសអាហ្សិន។ នាពេលពួកគេបានទៅដល់ប្រទេសអេហ្សិប នឹងបានជួបជាមួយយូសុះជាលើកទីពីតាមសន្យារបស់ពួកគេទាំង១០នាក់កាលមុន ប៉ុន្តែគ្រានេះយ៉ាកូបក៏រួមដំណើជាមួយពួកគេផងដែរ។

នៅពេលដែលពួកគេទៅដល់ប្រទេសអេហ្សិប យូសុះបានទទួលយ៉ាងរាក់ទាក់បំផុត យូសុះបានរៀបំអាហារសម្រាប់ពួកគេ ផ្តល់កន្លែងស្នាក់នៅដ៏ល្អ នឹងមានការទំនាក់បំរុងគ្រប់បែបយ៉ាងក្នុងនាមជាភ្ញៀវដែលគោរពពាក្យសន្យា នឹងជាភ្ញៀវដែលមានមកពីពូជពង្សកេរ៍ឈ្មោះខ្ពង់ខ្ពស់ ពោលជាខ្សែណាពីៗពីមុនមក។ យូសុះបានឲ្យពួកគេទាំង១០នាក់ដេកសម្រាក់នៅក្នុងអាគារ៍មួយក្នុងវាំងដោយបន្ទាប់មួយមានគ្នាពីរនាក់ រីឯពុនយ៉ាមុនវិញត្រូវបានយូសុះនាំទៅដេកជាមួយក្នុងអាគាររបស់ខ្លួន។ យូសុះបានសួរនាំច្រើនអំពីរឿងរ៉ាវទាក់ទងទៅនឹងក្រុមគ្រួសារ ជីវភាពគ្រួសារ និងការរស់នៅ ប៉ុន្តែពុនយ៉ាមុនមិនបានដឹងថាយូសុះគឺជាបងប្រុសរបស់ខ្លួននោះទេ។ យូសុះបានសួរថា៖ ឯណាទៅបងប្រុសបន្ទាប់អ្នកដែលឈ្មោះយូសុះនោះ? ពុកយ៉ាមុន បានរៀបរាប់ប្រាប់រឿងរ៉ាវយូសុះដល់ស្តេច ប៉ុន្តែពុនយ៉ាមុនមិនបានដឹងថា ស្តេចដែលពុលយ៉ាមុនកំពុងនិយាយរឿងប្រាប់នៅចំពោះមុខនោះគឺជាយូសុះដែលជាបងប្រុសបង្កើតរបស់ខ្លួននោះទេ ពុនយ៉ាមុនសម្រុកទឹកភ្នែកនឹងបានបន្តថា៖ បើសិនជាយូសុះបងប្រុសរបស់ខ្ញុំនៅជាមួយរហូតមកដល់ពេលនេះ យូសុះនឹងបានជួបសំណេះសំណាលជាអ្នកដូចដែលពួកយើងទាំងអស់គ្នាបានជួបអ្នកនៅទីនេះផងដែរ។ យូសុះបានឆ្លើយវិញថា៖ ឪពុនយ៉ាមុន ចូរប្អូនសប្បាយចិត្តចុះ ខ្ញុំអាចជំនួសបងប្រុសរបស់អ្នក និងធ្វើជាបងប្រុសរបស់អ្នក ដូចដែលបងប្រុសរបស់អ្នកដូច្នោះដែរ។ ពុនយ៉ាមុនបានតបថា៖ ស្តេចជាទីគោរព.. វាពិតជាមិនអាច

កើតមានឡើយ ស្តេចគឺជាអ្នកមានកិត្តិយសខ្ពង់ខ្ពស់ គ្រប់គ្រងលើប្រជារាស្ត្រទាំងប្រទេស ឯចំនែកយូសុះបងប្រុសរបស់ខ្ញុំវិញគ្រាន់តែជាមនុស្សម្នាក់ដែលបង្កើតឡើងដោយឪពុករបស់ខ្ញុំយ៉ាកូប និងម្តាយរបស់ខ្ញុំរ៉ាហែល នៅក្នុងក្រុមគ្រួសារក្រីក្រមួយ។ ពេលយូសុះលឺដូច្នោះ យូសុះស្ទើទប់នឹងទឹកភ្នែករបស់ខ្លួនពុំបាន យូសុះបានសម្រុកទឹកភ្នែកនៅចំពោះមុខពុនយ៉ាមីន ហើយអបពុនយ៉ាមីនពេញនិងទ្រូងរបស់ខ្លួនរួចបាននិយាយថា៖ ឪពុនយ៉ាមីន ខ្ញុំនេះហើយគឺជាយូសុះបងប្រុសរបស់អ្នក ខ្ញុំបានបាត់ខ្លួនពីអ្នកនឹងពុកជាទៅស្រលាញ់ រួចយូសុះបានរៀបរាប់រឿងរ៉ាវដែលកើតឡើងទាំងអស់ប្រាប់ទៅពុនយ៉ាមីន ដែលបងប្អូនរបស់គេទាំង១០នាក់បានធ្វើចំពោះយូសុះ និងក្នុងការរស់នៅរបស់យូសុះចាប់ពីថ្ងៃនោះមក រហូតបានក្លាយជាស្តេចមួយអង្គនាពេលនោះ។ ពេលលឺនឹងដឹងរឿងរ៉ាវដែលកើតឡើតចំពោះយូសុះរួចហើយ ពុនយ៉ាមីនសប្បាយរីករាយលែង ពុនយ៉ាមីនបានអបយូសុះមិនលែងដៃឡើយ ដោយក្តីនឹករលឹក នឹកនាអស់ជាច្រើនឆ្នាំមកហើយនោះ ពួកគេទាំងពីរនាក់បងប្អូនបង្កើតដែលបែកគ្នា បានបន្តនិយាយគ្នាពេញមួយយប់។ ពុនយ៉ាមីនបាននិយាយថា៖ បើសិនជាដំណឹងដ៏ល្អនេះបានលឺដល់លោកឪពុកនោះ លោកប្រាកដជាសប្បាយចិត្តរីករាយរកអ្វីមកផ្ទឹមពុំបាន បើសិនជាលោកដឹងថា បងនៅរស់រានមានជីវិត្ត និងបានក្លាយជាស្តេចមួយអង្គដែលមានអំណាចមានកិត្តិយស គ្រប់គ្រងលើមនុស្សរាប់មិនអស់ កាន់កាប់ទឹកដីមួយដ៏ធំល្វឹងល្វើយ រស់នៅក្នុងរាជវាំងដ៏ល្អប្រណិត ជាពិសេសជាមនុស្សម្នាក់ដែលល្អក្នុងកែវភ្នែកមនុស្សទាំងអស់បែបនេះ បន្ទាប់ពីលោកឪពុកទទួលដំណឹងពីបង។ទាំង១០នាក់ថា បងត្រូវបានឆ្កែចចកស៊ីជាអាហាររួចមក បានធ្វើអោយលោកឈឺចាប់រឹងរៃ សម្រុកទឹកភ្នែកជារៀងរាល់ថ្ងៃរហូតបណ្តាលឲ្យភ្នែករបស់លោកងងិតមើលអ្វីមិនឃើញ។ បន្ទាប់ពីយូសុះបានដឹងរឿងរ៉ាវក្នុងករុមគ្រួសារ ជាពិសេសបានដឹងពីសុខទុខរបស់យ៉ាកូបហើយ យូសុះបានអង្វរសំឲ្យពុនយ៉ាមីនរក្សាអ្វីដែលយូសុះរៀបរាប់ប្រាប់ ជាពិសេសរឿងស្តេចអង្គនោះគឺជា

យូសុះ មិនឲ្យបងប្អូនទាំង១០នាក់ផ្សេងទៀតដឹងឡើយ ហើយរក្សាជាអាថកំបាំងបំផុត។ រឿងរ៉ាវយូសុះនិងពុនយ៉ាមីនក្នុងវគ្គនេះ ដូចអល់ឡោះមានបន្ទូលក្នុងគម្ពីរអាល់កូរអានថា៖

وَلَمَّا جَهَّزَهُم بِجَهَازِهِمْ قَالَ ٱئْتُونِى بِأَخٍ لَّكُم مِّنْ أَبِيكُمْ ۚ أَلَا تَرَوْنَ أَنِّىٓ أُوفِى ٱلْكَيْلَ وَأَنَا۠ خَيْرُ ٱلْمُنزِلِينَ ﴿٥٩﴾
فَإِن لَّمْ تَأْتُونِى بِهِۦ فَلَا كَيْلَ لَكُمْ عِندِى وَلَا تَقْرَبُونِ ﴿٦٠﴾ قَالُوا۟ سَنُرَٰوِدُ عَنْهُ أَبَاهُ وَإِنَّا لَفَٰعِلُونَ ﴿٦١﴾
وَقَالَ لِفِتْيَٰنِهِ ٱجْعَلُوا۟ بِضَٰعَتَهُمْ فِى رِحَالِهِمْ لَعَلَّهُمْ يَعْرِفُونَهَآ إِذَا ٱنقَلَبُوٓا۟ إِلَىٰٓ أَهْلِهِمْ لَعَلَّهُمْ يَرْجِعُونَ
﴿٦٢﴾ فَلَمَّا رَجَعُوٓا۟ إِلَىٰٓ أَبِيهِمْ قَالُوا۟ يَٰٓأَبَانَا مُنِعَ مِنَّا ٱلْكَيْلُ فَأَرْسِلْ مَعَنَآ أَخَانَا نَكْتَلْ وَإِنَّا لَهُۥ
لَحَٰفِظُونَ ﴿٦٣﴾ قَالَ هَلْ ءَامَنُكُمْ عَلَيْهِ إِلَّا كَمَآ أَمِنتُكُمْ عَلَىٰٓ أَخِيهِ مِن قَبْلُ ۖ فَٱللَّهُ خَيْرٌ حَٰفِظًا ۖ وَهُوَ
أَرْحَمُ ٱلرَّٰحِمِينَ ﴿٦٤﴾ وَلَمَّا فَتَحُوا۟ مَتَٰعَهُمْ وَجَدُوا۟ بِضَٰعَتَهُمْ رُدَّتْ إِلَيْهِمْ ۖ قَالُوا۟ يَٰٓأَبَانَا مَا نَبْغِى ۖ
هَٰذِهِۦ بِضَٰعَتُنَا رُدَّتْ إِلَيْنَا ۖ وَنَمِيرُ أَهْلَنَا وَنَحْفَظُ أَخَانَا وَنَزْدَادُ كَيْلَ بَعِيرٍ ۖ ذَٰلِكَ كَيْلٌ يَسِيرٌ ﴿٦٥﴾
قَالَ لَنْ أُرْسِلَهُۥ مَعَكُمْ حَتَّىٰ تُؤْتُونِ مَوْثِقًا مِّنَ ٱللَّهِ لَتَأْتُنَّنِى بِهِۦٓ إِلَّآ أَن يُحَاطَ بِكُمْ ۖ فَلَمَّآ ءَاتَوْهُ مَوْثِقَهُمْ
قَالَ ٱللَّهُ عَلَىٰ مَا نَقُولُ وَكِيلٌ ﴿٦٦﴾ وَقَالَ يَٰبَنِىَّ لَا تَدْخُلُوا۟ مِنۢ بَابٍ وَٰحِدٍ وَٱدْخُلُوا۟ مِنْ أَبْوَٰبٍ مُّتَفَرِّقَةٍ ۖ وَمَآ أُغْنِى
عَنكُم مِّنَ ٱللَّهِ مِن شَىْءٍ ۖ إِنِ ٱلْحُكْمُ إِلَّا لِلَّهِ ۖ عَلَيْهِ تَوَكَّلْتُ ۖ وَعَلَيْهِ فَلْيَتَوَكَّلِ ٱلْمُتَوَكِّلُونَ ﴿٦٧﴾ وَلَمَّا
دَخَلُوا۟ مِنْ حَيْثُ أَمَرَهُمْ أَبُوهُم مَّا كَانَ يُغْنِى عَنْهُم مِّنَ ٱللَّهِ مِن شَىْءٍ إِلَّا حَاجَةً فِى نَفْسِ يَعْقُوبَ
قَضَىٰهَا ۚ وَإِنَّهُۥ لَذُو عِلْمٍ لِّمَا عَلَّمْنَٰهُ وَلَٰكِنَّ أَكْثَرَ ٱلنَّاسِ لَا يَعْلَمُونَ ﴿٦٨﴾ وَلَمَّا دَخَلُوا۟ عَلَىٰ
يُوسُفَ ءَاوَىٰٓ إِلَيْهِ أَخَاهُ ۖ قَالَ إِنِّىٓ أَنَا۠ أَخُوكَ فَلَا تَبْتَئِسْ بِمَا كَانُوا۟ يَعْمَلُونَ ﴿٦٩﴾

មាននัយថា៖ ហើយនៅពេលដែលយូសុហ្វបានចាត់ចែងជូន ពួកគេ នូវសំភារៈវត្ត(ស្បៀង)របស់ពួកគេ ហើយគាត់បានថា ចូរពួកអ្នកនាំមកកាន់យើងនូវប្អូនប្រុស របស់ពួកអ្នកពីបិតារបស់ពួកអ្នក។ តើពួកអ្នកមិនឃើញទេឬ ការពិតយើងបំពេញវង្គាល់ ហើយយើង ពិតជាអ្នកទទួលភ្ញៀវដ៏ប្រសើរជាងគេ (59). បើពួកអ្នកមិនព្រមនាំវាមកកាន់យើងទេ គឺគ្មានទៀតទេ វង្គាល់ លើសសំរាប់ពួកអ្នកអំពីយើង ហើយពួកអ្នកនឹងមិនបាននៅជិតយើងឡើយ (60). ពួកគេថាយើង យើងនឹងលួងលោមចំពោះបិតារបស់ពួកគេ ស្តីពីគេនេះហើយ យើងពិតជាអ្នកដែលធ្វើយ៉ាងប្រាកដ (61). រួចយូសុហ្វបាននិយាយទៅកាន់អ្នកបំរើរបស់គាត់ថា ចូរពួកអ្នកដាក់ទំនិញរបស់ពួកគេទៅក្នុង

ភារៈ វត្ថុរបស់ពួកគេវិញទៅ សង្ឃឹមថា ពួកគេនឹងស្គាល់ទំនិញនោះ កាលណាពួកគេបានវិលត្រលប់ទៅកាន់គ្រួសាររបស់ពួកគេវិញ សង្ឃឹមថា ពួកគេនឹងវិលមកវិញ (62). លុះនៅពេលដែលពួកគេបានវិលត្រលប់ ទៅកាន់បិតារបស់ពួកគេវិញ ពួកគេថា ឱបិតារបស់ពួកយើង! រង្វាល់ត្រូវបានគេហាមឃាត់ពីពួកយើង ដូច្នេះ សូមបិតាមេត្តាបញ្ជូនឱ្យទៅរួមជាមួយពួកយើងនូវប្អូនប្រុសរបស់ពួកយើង ពួកយើងប្រាកដជា នឹងទទួលបានការវាល់ ហើយពួកយើងពិតណាស់ ជាពួកអ្នកថែការពារចំពោះប្អូនប្រុសយ៉ាងប្រាកដ (63). បិតាបានថា តើយើងនឹងទុកចិត្តពួកអ្នកទៅលើរឿងប្អូនប្រុសនេះ ក្រៅពីដូចដែលយើងបានទុកចិត្ត ពួកអ្នកទៅលើរឿងយូសុហ្វកាលពីមុននោះឬ? តែអល់ឡោះទេដែលប្រសើរបំផុតខាងអ្នកថែ ការពារ ហើយលោកជាអ្នកអាណិតអាសូរជាងគេបង្អស់ (64). ហើយនៅពេលដែលពួកគេបាន បើកប្រដាប់ប្រដាពួកគេ ពួកគេបានប្រទះនូវទំនិញរបស់ពួកគេ ដែលត្រូវបានគេបង្វិលជូនទៅ ពួកគេវិញ។ ពួកគេថា ឱបិតារបស់យើង! តើយើងស្វែងរកអ្វីទៀត នេះនែ៎! គឺជាទំនិញរបស់ពួកយើង ដែលត្រូវបានគេបង្វិលជូនមកពួកយើងវិញ។ ហើយយើងនឹងបាននាំសំរិទ្ធានវត្ថុ (ស្បៀង)នេះមកកាន់គ្រួសារយើងទៀត ហើយយើងនឹងថែការពារប្អូនប្រុសរបស់ពួកយើង ហើយយើងនឹងទទួលបានកើននូវបន្ទុករបស់សត្វអូដ្ឋមួយទៀត។ ទាំងនេះ គឺជាបន្ទុកមួយដែល ងាយស្រួលបំផុត (65). បិតាថា យើងនឹងមិនបញ្ជូនវាឱ្យទៅរួមជាមួយពួកអ្នកទេ ទាល់តែពួកអ្នក នឹងផ្តល់ជូនមកយើង នូវចំណងកិច្ចសន្យាមួយពីអល់ឡោះ ពួកអ្នកប្រាកដជានឹងនាំវាមក ដល់យើងវិញ លើកលែងតែពួកអ្នកនឹងត្រូវគេឡោមព័ទ្ធ។ លុះនៅពេលដែលពួកគេបានផ្តល់នូវចំណងកិច្ចសន្យារបស់ពួកគេ គាត់ថា អល់ឡោះជាអ្នកសាក្សីនៅលើអ្វីដែលពួកយើងទាំងអស់ គ្មានិយាយ (66). រួចមកបិតាថា នែ៎!បុត្រាទាំងឡាយរបស់យើង ចូរពួកអ្នកកុំទៅតាមទ្វារតែមួយ ហើយចូរពួកអ្នកចូលទៅតាមទ្វារទាំងឡាយដែលផ្សេងៗពីគ្នា ហើយយើងមិនអាចការពារពួកអ្នក ពីអល់ឡោះនូវវត្ថុណាមួយឡើយ ការវិនិច្ឆ័យ គឺគ្មានអ្វីក្រៅពីជាកម្មសិទ្ធិរបស់អល់ឡោះឡើយ ។ នៅលើលោក យើងបានប្រគល់ទំនុកចិត្ត។ ហើយនៅលើលោក ចូរបណ្តាអ្នកដែលប្រគល់ ក្តីស្មោះធ្វើការប្រគល់ (67). ហើយនៅពេលដែលពួកគេបានចូលទៅតាមករណីដែលបិតារបស់ ពួកគេបានបញ្ជាទៅពួកគេ ដែលគាត់មិនបានការពារពួកគេពីអល់ឡោះនូវវត្ថុណាមួយឡើយ លើកលែងតែសេចក្តីត្រូវការមួយនៅក្នុងខ្លួនរបស់យ៉ាក់កូប ដែលគេបានសម្រេចតម្រូវការ នោះហើយ ការពិតគេប្រាកដជាអ្នកមានវិជ្ជាមួយ ដោយសារតែយើងបានបង្រៀនគេ ក៏ប៉ុន្តែ ភាគច្រើននៃមនុស្សនៅតែមិនទាន់ដឹងទៀត (68). ហើយនៅពេលដែលពួកគេបានចូលទៅ កាន់យូសុហ្វ យូសុហ្វក៏បានអោបប្អូនប្រុសរបស់គេ។ គេថា ពិតប្រាកដណាស់យើងជាបង ប្រុសរបស់អ្នក ហេតុដូចនេះ ចូរអ្នកកុំទាន់អស់សង្ឃឹមនូវអ្វីដែលពួកគេធ្លាប់បានប្រព្រឹត្ត (69).

ក្នុងរយៈពេលពួកគេទាំង១១នាក់បានរស់នៅជាមួយយូសុះ ដោយយូសុះទទួលយ៉ាងរាក់ទាក់ និងបានរៀបចំទំនុកបម្រុងដល់ពួកគេយ៉ាងល្អរួចហើយ ៣ថ្ងៃក្រោយមកពួកគេ

កបានរៀបចំសំភារៈដើម្បីធ្វើដំណើរចាកចេញពីវាំងរបស់យូសុះវិញ ដោយមានសត្វអូដ្ឋ ជាមធ្យោបាយធ្វើដំណើរម្នាក់មួយកបាល និងយូសុះបានអនុញ្ញាតឲ្យពួកគេទាំង១១ នាក់ទទួលបានស្បៀងជាទីគាប់ចិត្តដោយមិនបានលក់ឡើយ។ បន្ទាប់ពីពួកគេរៀបចំរួចរាលហើយ នាព្រឹកព្រលឹមឡើងពួកគេបានចូលខ្លួនដើម្បីសុំលាយូសុះ ហើយកចាក់ចេញពីវាំងយូសុះទាំងសប្បាយចិត្ត និងអបអរសាទរចំពោះស្បៀងផ្សេងៗគ្រប់មុខ គ្រប់ប្រភេទដែលយូសុះឲ្យដោយមិនគិតថ្លៃ។ នៅពេលពួកគេទាំង១១នាក់ចេញបានបន្តិចពោល នៅឃ្លោងទ្វាមួយដែលរៀបនិងចេញផុតពីទីប្រជុំជន មានក្រុមទាហានរបស់យូសុះជាច្រើននាក់បានទៅដល់ផងដែរ ពួកគេបានស្រែកប្រកាស់ថាៈ តាមបង្គាប់បញ្ជារបស់ស្តេចយូសុះ នៅក្នុងរាជវាំងបានបាត់កែវទឹកធ្វើអំពីមាស ដែលជាកែវទឹករបស់ស្តេចយូសុះផឹកទឹកជារៀងរាល់ថ្ងៃ ដូច្នោះយើងទាំងអស់គ្នាជាសេនារបស់ស្តេចយូសុះសំធ្វើការឆែកឆេរគ្រប់របស់របបទាំងអស់នៅទីនេះ ហើយបើសិនជាពួកយើងដឹងថា នរណាម្នាក់ជាអ្នកលួច នោះយើងនិងចាប់អ្នកនោះនៅទីនេះ នឹងដាក់ទោសពីបទលួច។ ម្នាក់ក្នុងចំណោមបងប្អូនពុនយ៉ាមីនបាននិយាយថាៈ *ពួកយើងខ្ញុំទាំងអស់គ្នាដែលជាកូនរបស់ណាពីយ៉ាកូប ពួកយើងបានមកដល់ទីនេះតាមបង្គាប់របស់ឪពុករបស់យើង ដើម្បីសុំការអនុញ្ញាតពីស្តេចយូសុះ ដើម្បីទិញស្បៀងសម្រាប់ផ្គត់ផ្គង់ក្នុងគ្រួសាររបស់យើងដែលកំពុងជួបកង្វះខាត ផ្សេងពីនេះ ស្តេចយូសុះបានមានគុណមកលើពួកយើងខ្ញុំដោយប្រគល់ស្បៀងជូនដោយឥតគិតថ្លៃ និងបានរៀបចំទំនុកបម្រុងម្ហូបអាហារ កន្លែងស្នាក់នៅ ផ្សេងៗជាទីគាប់ចិត្តដល់ពួកយើង នេះគឺជាគុណបំណាច់មួយដ៏ធំធេងរបស់ស្តេចយូសុះ ដូច្នោះគ្មានហេតុផល់ណាមួយដែលម្នាក់រឺច្រើននាក់នៃបងប្អូនយើងទាំង១១នាក់លួចទ្រពសម្បត្តិដែលជារបស់អ្នកមានគុណរបស់យើងនោះទេ។ តែបើសិនជាពួកអ្នកបានឆែកឆេរយើញ និងបញ្ជាក់យ៉ាងច្បាស់ថាកែវទឹកនោះត្រូវបានរកយើញក្នុង*

របស់របរ តវ៉ាន់របស់ពួកយើង នោះពួកយើងសុខចិត្តប្រគល់ខ្លួនជូនពួកអ្នក និងអនុញ្ញាតឲ្យស្តេចយូសុះកាត់ទោសតាមច្បាប់។

បន្ទាប់ក្រុមសេនាស្តេចយូសុះទាំងអស់នោះបានឆែកឆេរគ្រប់ក្រុម គ្រប់តវ៉ាន់ របស់របស់ផ្សេងមិនឃើញ ជាចុងក្រោយពួកគេបានឆែកតវ៉ាន់ដែលជារបស់ពុលយ៉ាមុីននៅលើខ្នងសត្វអូដ្ឋដែលពុនយ៉ាមុីនជិះ កស្រាប់តែប្រទះឃើញកែវទឹករបស់ស្តេចយូសុះនៅក្នុងនោះ នៅពេលនោះបងប្អូនទាំង១១នាក់បានបើកភ្នែកធំៗហើយឆ្ងល់ថា ហេតុអ្វីបានជាកែវទឹករបស់ស្តេចមាននៅក្នុងតវ៉ាន់របស់ពុនយ៉ាមុីនទៅវិញ? ហើយពួកគេដឹងច្បាស់ថា ពុនយ៉ាមុីននិងបងប្អូនរបស់ពួកគេទាំង១០នាក់ផ្សេងទៀត ពិតជាមិនអាចធ្វើនូវទង្វើលួចបែបនោះបានទេ ពួកចម្លែកក្នុងចិត្ត។ ប៉ុន្តែដោយហេតុគ្មានភស្តុតាង និងមិនអាចប្រកែកបាន ដោយសារពួកគេឃើញផ្ទាល់ភ្នែកថា កែវទឹកនោះដកចេញពីក្នុងតវ៉ាន់របស់ពុនយ៉ាមុីនពិតប្រាកដមែន។ សេនាយូសុះម្នាក់ក្នុងចំណោមពួកគេបានសួរថា ៖

សេនា៖ *នរណាជាម្ចាស់កម្មសិទ្ធិសត្វអូដ្ឋ និងជាម្ចាស់តវ៉ាន់នេះ?*

បងប្អូនយូសុះ៖ *វាគឺជាកម្មសិទ្ធិក្រោមមើលការខុសត្រូវ និងជាសត្វអូដ្ឋរបស់ប្អូនប្រុសពៅរបស់ខ្ញុំឈ្មោះពុនយ៉ាមុីន។*

សេនា៖ *យើងត្រូវចាប់ពុនយ៉ាមុីនដើម្បីផ្តល់ទាទោសចោទប្រកាន់ពីបទលួចកែវទឹករបស់ស្តេចយូសុះដោយមិនអាចប្រកែកបាន។*

បងប្អូនយូសុះ៖ *(យ៉ាហុហ្សា ដែលជាបងច្បងក្នុងចំណោមពួកគេទាំង១០នាក់បាននិយាយថា)៖ អស់លោកមន្ត្រីទាំងអស់គ្នា.. ខ្ញុំជាបងគេបង្អស់ក្នុងចំណោមបងប្អូន*

យើងខ្ញុំទាំង១១នាក់ ហើយខ្ញុំគឺជាអ្នកមើលការខុសត្រូវចំពោះប្អូនៗទាំងអស់គ្នា ដូច្នោះ ដោយសារមានករណីនេះ ខ្ញុំសុំចូលខ្លួនជំនួសប្អូនពៅរបស់ខ្ញុំនៅទីនេះ ហើយទទួលកំហុសជំនួស មូលហេតុ ពួកយើងខ្ញុំទាំងអស់គ្នាត្រូវប្រឈមមុខលោកឪពុករបស់យើងដែលកំពុងដេកឈឺនៅឯផ្ទះ និងពិការភ្នែកមើលមិនឃើញ មុនពេកពួកយើងបានសំលោកដើម្បីនាំពុនយ៉ាមីនមកកាន់ទីនេះ លោកមិនអនុញ្ញាតនោះទេ ប៉ុន្តែដោយសារភាពចាំបាច់ក្នុងគ្រួសារ ដោយកង្វះខាតស្បៀងទើបលោកបានអនុញ្ញាតឲ្យពុនយ៉ាមីនរួចំណីជាមួយយើងខ្ញុំទាំងអស់គ្នាមកកាន់ទីនេះ ហើយពួកយើងបានសន្យាជាមួយលោកថា និងការពារពុនយ៉ាមីនក្នុងរយៈពេលធ្វើដំណើរហូតត្រលប់ដល់ផ្ទះសម្បែងវិញដោយសុវត្ថិភាពល្អបំផុត។

សេនាះ *យើងខ្ញុំទាំងអស់គ្នាសូមមធ្យាស្រយ នេះគឺជាបញ្ជារបស់ស្តេចនៃពួកយើងទាំងអស់គ្នា ពួកយើងត្រូវតែអនុវត្តន៍តាមបង្គាប់បញ្ជាស្តេចរបស់ពួកយើង បើពុំដូច្នោះទេពួកយើងនិងមានទោសពីបទមិនគោរពតាមបង្គាប់បញ្ជារបស់ស្តេច។*

បន្ទាប់ពីចរចារណ៍រួច បងប្អូនយូសុះបានស្នើសុំដល់សេនាយូសុះទាំងអស់នោះដើម្បីបានជួបនឹងស្តេចយូសុះដោយផ្ទាល់ បន្ទាប់មកពួកគេកបាននិយាយទៅកាន់យូសុះថា៖ *ឪវាជាជាទីគោរព.. ពិតប្រាកដណាស់យើងខ្ញុំទាំងអស់គ្នាបានទទួលស្គាល់ថា កែវទឹកមាស់នោះពិតជាបានរកឃើញក្នុងឥវ៉ាន់របស់ប្អូនពៅរបស់យើងខ្ញុំពិតប្រាកដមែន ប៉ុន្តែដោយសារពុនយ៉ាមីននៅតូច ខ្វះការពិចារណា យើងខ្ញុំសំអនុញ្ញាតពីទ្រង់ដើម្បីជ្រើសរើសម្នាក់ក្នុងចំណោមពួកយើងខ្ញុំដើម្បីជំនួសយូសុះឲ្យនៅទីនេះ រហូតទ្រង់បានរកឃើញថា តើនរណាជាអ្នកល្អចហើយទម្លាក់កំហុសមកលើបងប្អូនយើងខ្ញុំពុនយ៉ាមីនយ៉ាងដូច្នោះ សូមទ្រង់ពិចារណានិងលើកលែងតាមការស្នើសុំផងចុះ។* ទុះជាមានការអង្វរពីបងប្អូនពុនយ៉ាមីនយ៉ាងណាកដោយ យូសុះនិងអស់មន្ត្រីទាំងអស់នៅតែ

បដិសេធ និងត្រូវតែអនុវត្តន៍តាមច្បាប់របស់ខ្លួន ជនណាដែលល្មើចត្រូវផ្តល់ទាទោសធ្វើជាអ្នកបំរើរយៈពេល១ឆ្នាំ ហើយយូសុះកមិនអនុញ្ញាតឲ្យមានការដោះដូរនាក់ផ្សេងជំនួសឡយ។

ដោយហេតុប្រកែកមិនបាន ការអង្វរគ្មានប្រសិទ្ធិភាព គ្រប់យ៉ាងត្រូវយូសុះបដិសេធ ហើយត្រូវអនុវត្តន៍តាមច្បាប់ដែលបានចែង យ៉ាហុទហ្សា បាននិយាយទៅកាន់បងប្អូនគេទាំងអស់ថា៖ ចូរពួកអ្នកទាំងអស់គ្នានាំគ្នាត្រលប់ទៅកាន់ផ្ទះវិញ ហើយខ្ញុំរួចជាមួយយូសុះនឹងបន្តនៅទីនេះរហូតដល់ពេលដែលស្តេចយូសុះរកឃើញថា ពុនយ៉ាមុនគ្មានទោសកំហុស រួចយើងទាំងពីរនាក់នឹងត្រលប់ទៅជួបលោកពុកវិញ ខ្ញុំគ្មានមុខមាត់អ្វីដើម្បីប្រឈមនិងសំនួរដែលត្រូវលោកឪពុកសួរនោះទេ យើងបានបំពាននិងការសន្យាជាមួយលោកពុកដែលត្រូវមើលការខុសត្រូវចំពោះពុលយ៉ាមុន ឲ្យស្លាម៉ាត់រួចផុតពីគ្រោះទាំងឡាយរហូតបានត្រលប់ទៅដល់ផ្ទះវិញ ដូច្នោះចូរពួកអ្នកត្រលប់ទៅវិញចុះ ហើយប្រាប់លោកឪពុកថា ខ្ញុំនៅជាមួយពុនយ៉ាមុន ហើយកុំឲ្យលោកមានការព្រួយបារម្ភណ៍ចំពោះសុខទុខពុនយ៉ាមុនឲ្យសោះ។ ពេលនិយាយផ្តាំផ្ញើរួច បងប្អូនទាំង៩នាក់បានចាកចេញពីពុនយ៉ាមុន និងយ៉ាហុទហ្សា ត្រលប់ទៅផ្ទះវិញ ឯចំនែកពុកយ៉ាមុននិងយ៉ាហុទហ្សាត្រូវកេ្សាទុកនៅក្នុងវាំងជាបណ្តុះអាសន្ន។

ជាការពិតណាស់ ទង្វើទាំងអស់ខាងលើគឺជាគម្រោងដែលយូសុះរៀបចំទុកជាមុនដើម្បីឲ្យពុនយ៉ាមុនបានរស់នៅក្បែខ្លួនក្នុងវាំងមួយរយៈពេល ក្តីនឹករលឹកយូសុះចំពោះពុនយ៉ាមុនពិតជាធំធេងណាស់។ នៅពេលដែលបងប្អូនទាំង៩នាក់បានទៅដល់ផ្ទះ ករៀបរាប់ប្រាប់យ៉ាកូបអំពីរឿងរ៉ាវដែលកើតមានឡើងចំពោះពុនយ៉ាមុន នឹងសុំក្តីសណ្តោះប្រណីពីលោកឪពុក (អភ័យទោស) ចំពោះរឿងរ៉ាវហេតុការណ៍ទាំងអស់ខាងលើដែលកើតមានឡើង ជាពិសេសដែលមិនអាចការពារពុនយ៉ាមុនដូចដែលពួកខ្លួន

ផ្លាប់សន្យា។ យ៉ាកូបបែបមុខចេញ ស្រក់ទឹកភ្នែករួចនិយាយថា៖ *ជាការពិតណាស់ យើងពិតជាពិបាក់ចិត្តណាស់ យូសុះបានបាត់ខ្លួនទៅហើយរហូតមកទល់ពេលនេះ យើងនៅមិនទាន់ទទួលបានដំណឹងពីយូសុះ ក្តីនឹករលឹកយើងចំពោះយូសុះនៅតែមានក្នុងចិត្តរបស់យើង ហើយនឹកឃើញមុខយូសុះគ្រប់ពេលមិនទាន់នឹងបាត់ផង លើសនេះពួកអ្នកបានបន្ថែមក្តីកង្វល់ ទុកព្រួយមកលើរូបយើងបន្ថែមទៀត ហេតុអ្វីពាល់ប្រការដែលយើងព្រួយបារម្ភណ៍នោះតែងតែកើតមានឡើងដោយចេញពីពួកអ្នកទៅវិញ? ពេលនេះពុនយ៉ាមុីនត្រូវបានគេចោទពីបទលួច និងឃាត់ទុកដើម្បីផ្តល់ទារទោសនៅឯប្រទេសគេ ហេតុអ្វីបានជាពួកអ្នកតែងតែក្បត់និងការសន្យារបស់ពួកអ្នកចំពោះការសន្យាដែលពួកអ្នកសន្យាជាមួយយើងទាំងពីរលើកយ៉ាងដូច្នេះ? សង្ឃឹមថា អល់ឡោះនិងប្រទានសេចក្តីអត់ធ្មត់មកលើយើង ហើយផ្តល់ក្តីជួបជុំដល់យើងជាមួយកូនៗជាទីស្រលាញ់របស់យើងវិញ។* ពេលលឺប្រសាសន៍របស់ឪពុកដូច្នោះ ម្នាក់ក្នុងចំណោមបងប្អូនទាំង៩នាក់ដែលត្រលប់ពីប្រទេសអេហ្ស៊ីបវិញបាននិយាយទៅកាន់យ៉ាកូបវិញថា៖ *លោកឪពុកជាទីគោរព.. ជាការពិតណាស់ លោកឪពុកកំពុងប្រឈមនិងជំងឺប្រចាំកាយយ៉ាងធ្ងន់ធ្ងរ ដូច្នោះសូមលោកពុករក្សាសុខភាព និងកាត់ក្តីកង្វល់របស់លោកពុកផង បើពុំដូច្នោះទេ លោកពុកនិងត្រូវប្រឈមមុខនិងជំងឺកាន់តែធ្ងន់ធ្ងរ អាចបណ្តាលឲ្យលោកពុកបាត់បង់រាងការឲយ ក្តីចងចាំ និងជីវិតបាន។* ក្នុងរឿងរ៉ាវនេះដូចអល់ឡោះបានមានបន្ទូលក្នុងគម្ពីរអាល់កូរអាន ក្នុងស៊ូរ៉ោះយូសុះ អាយ៉ាត់ទី 70 – 86 ថា៖

فَلَمَّا جَهَّزَهُم بِجَهَازِهِمْ جَعَلَ ٱلسِّقَايَةَ فِى رَحْلِ أَخِيهِ ثُمَّ أَذَّنَ مُؤَذِّنٌ أَيَّتُهَا ٱلْعِيرُ إِنَّكُمْ لَسَـٰرِقُونَ
﴿٧٠﴾ قَالُوا۟ وَأَقْبَلُوا۟ عَلَيْهِم مَّاذَا تَفْقِدُونَ ﴿٧١﴾ قَالُوا۟ نَفْقِدُ صُوَاعَ ٱلْمَلِكِ وَلِمَن جَآءَ بِهِۦ حِمْلُ
بَعِيرٍ وَأَنَا۠ بِهِۦ زَعِيمٌ ﴿٧٢﴾ قَالُوا۟ تَٱللَّهِ لَقَدْ عَلِمْتُم مَّا جِئْنَا لِنُفْسِدَ فِى ٱلْأَرْضِ وَمَا كُنَّا سَـٰرِقِينَ
﴿٧٣﴾ قَالُوا۟ فَمَا جَزَٰٓؤُهُۥٓ إِن كُنتُمْ كَـٰذِبِينَ ﴿٧٤﴾ قَالُوا۟ جَزَٰٓؤُهُۥ مَن وُجِدَ فِى رَحْلِهِۦ فَهُوَ جَزَٰٓؤُهُۥ كَذَٰلِكَ

نَجۡزِي ٱلظَّٰلِمِينَ ٧٥ فَبَدَأَ بِأَوۡعِيَتِهِمۡ قَبۡلَ وِعَآءِ أَخِيهِ ثُمَّ ٱسۡتَخۡرَجَهَا مِن وِعَآءِ أَخِيهِۚ
كَذَٰلِكَ كِدۡنَا لِيُوسُفَۖ مَا كَانَ لِيَأۡخُذَ أَخَاهُ فِي دِينِ ٱلۡمَلِكِ إِلَّآ أَن يَشَآءَ ٱللَّهُۚ نَرۡفَعُ دَرَجَٰتٖ مَّن
نَّشَآءُۗ وَفَوۡقَ كُلِّ ذِي عِلۡمٍ عَلِيمٞ ٧٦ ۞ قَالُوٓاْ إِن يَسۡرِقۡ فَقَدۡ سَرَقَ أَخٞ لَّهُۥ مِن قَبۡلُۚ
فَأَسَرَّهَا يُوسُفُ فِي نَفۡسِهِۦ وَلَمۡ يُبۡدِهَا لَهُمۡۚ قَالَ أَنتُمۡ شَرّٞ مَّكَانٗاۖ وَٱللَّهُ أَعۡلَمُ بِمَا تَصِفُونَ
٧٧ قَالُواْ يَٰٓأَيُّهَا ٱلۡعَزِيزُ إِنَّ لَهُۥٓ أَبٗا شَيۡخٗا كَبِيرٗا فَخُذۡ أَحَدَنَا مَكَانَهُۥٓۖ إِنَّا نَرَىٰكَ مِنَ
ٱلۡمُحۡسِنِينَ ٧٨ قَالَ مَعَاذَ ٱللَّهِ أَن نَّأۡخُذَ إِلَّا مَن وَجَدۡنَا مَتَٰعَنَا عِندَهُۥٓ إِنَّآ إِذٗا لَّظَٰلِمُونَ ٧٩
فَلَمَّا ٱسۡتَيۡـَٔسُواْ مِنۡهُ خَلَصُواْ نَجِيّٗاۖ قَالَ كَبِيرُهُمۡ أَلَمۡ تَعۡلَمُوٓاْ أَنَّ أَبَاكُمۡ قَدۡ أَخَذَ عَلَيۡكُم مَّوۡثِقٗا
مِّنَ ٱللَّهِ وَمِن قَبۡلُ مَا فَرَّطتُمۡ فِي يُوسُفَۖ فَلَنۡ أَبۡرَحَ ٱلۡأَرۡضَ حَتَّىٰ يَأۡذَنَ لِيٓ أَبِيٓ أَوۡ يَحۡكُمَ ٱللَّهُ لِيۖ وَهُوَ خَيۡرُ
ٱلۡحَٰكِمِينَ ٨٠ ٱرۡجِعُوٓاْ إِلَىٰٓ أَبِيكُمۡ فَقُولُواْ يَٰٓأَبَانَآ إِنَّ ٱبۡنَكَ سَرَقَ وَمَا شَهِدۡنَآ إِلَّا بِمَا عَلِمۡنَا وَمَا
كُنَّا لِلۡغَيۡبِ حَٰفِظِينَ ٨١ وَسۡـَٔلِ ٱلۡقَرۡيَةَ ٱلَّتِي كُنَّا فِيهَا وَٱلۡعِيرَ ٱلَّتِيٓ أَقۡبَلۡنَا فِيهَاۖ وَإِنَّا
لَصَٰدِقُونَ ٨٢ قَالَ بَلۡ سَوَّلَتۡ لَكُمۡ أَنفُسُكُمۡ أَمۡرٗاۖ فَصَبۡرٞ جَمِيلٌۖ عَسَى ٱللَّهُ أَن يَأۡتِيَنِي بِهِمۡ
جَمِيعًاۚ إِنَّهُۥ هُوَ ٱلۡعَلِيمُ ٱلۡحَكِيمُ ٨٣ وَتَوَلَّىٰ عَنۡهُمۡ وَقَالَ يَٰٓأَسَفَىٰ عَلَىٰ يُوسُفَ وَٱبۡيَضَّتۡ عَيۡنَاهُ
مِنَ ٱلۡحُزۡنِ فَهُوَ كَظِيمٞ ٨٤ قَالُواْ تَٱللَّهِ تَفۡتَؤُاْ تَذۡكُرُ يُوسُفَ حَتَّىٰ تَكُونَ حَرَضًا أَوۡ تَكُونَ
مِنَ ٱلۡهَٰلِكِينَ ٨٥ قَالَ إِنَّمَآ أَشۡكُواْ بَثِّي وَحُزۡنِيٓ إِلَى ٱللَّهِ وَأَعۡلَمُ مِنَ ٱللَّهِ مَا لَا تَعۡلَمُونَ
٨٦

មានន័យថា៖ លុះនៅពេលដែលគាត់បានចាត់ចែងជូនពួកគេនូវសំភារៈវត្ថុរបស់ពួកគេ ហើយគេក៏បាន ដាក់ពែង(មាស)ទៅក្នុងភារៈវត្ថុរបស់ប្អូនប្រុសរបស់គេ ក្រោយមក អ្នកដែលប្រកាសបានស្រែកប្រកាសថា ឱបណ្តាអ្នកបរសេវអូដ្ឋទាំងឡាយ! ការពិតពួកអ្នក គឺពិតជាពួកចោរយ៉ាង ប្រាកដ (70). ពួកគេបានដើរតំរង់ទៅលើពួកទាំងនេះដោយថា តើពួកអ្នកបាត់អ្វីដែរ? (71). ពួកគេថា ពួកយើងបាត់ពែងរបស់ព្រះរាជា ហើយសំរាប់អ្នកដែលបាននាំពែងនេះមកវិញ ដោយបន្ទុករបស់អូដ្ឋមួយ ហើយយើងជាអ្នកដែលធានាផ្តល់រង្វាន់ជូនក្នុងរឿងនេះ (72). ពួក គេនិយាយថា សច្ចាអល់ឡោះ! ពួកអ្នកប្រាកដជាបានដឹងហើយ មិនមែនយើងបានមកនេះ ដើម្បីយើងនឹងសាងចលាចលនៅលើទឹកដីទេ ហើយយើងក៏ពុំមែនជាពួកចោរដែរ (73). ពួក គេបាននិយាយថា តើអ្វីទៅជាការ

ទូទាត់របស់វា ប្រសិនបើអ្នកទាំងឡាយជាពួកដែលភូត កុហក? (74). ពួកគេថា ការទូទាត់របស់វា គឺជនណាហើយដែលត្រូវបានគេប្រទះឃើញ ពែងនៅក្នុងភារៈវត្ថុរបស់គេ ជននោះផ្ទាល់ត្រូវទូទាត់។ ឱ្យ ប្រៀបដូចទាំងនេះដែរ ដែលយើង នឹងទូទាត់ចំពោះពួកដែលបំពារបំពាន (75). រួចមក យូសុហ្វ បានចាប់ផ្តើម(ឆែក)បន្ទុករបស់ ពួកគេមុនបន្ទុករបស់ប្អូនប្រុសគេ។ ក្រោយមក គេក៏បានយកពែងនោះចេញពីបន្ទុករបស់ ប្អូនប្រុសរបស់គេ។ ប្រៀបដូចទាំងនេះហើយ ដែលយើងបានផ្តល់ល្បិចកលសំរាប់យូសុហ្វ។ គេនឹងមិនអាចយកប្អូនប្រុសបង្កើតរបស់គេ តាមរាជាបញ្ញតិបានឡើយ លើកលែងតែ អល់ឡោះប្រាថ្នា។ យើងនឹងលើកកំពស់នូវឋានៈទាំងឡាយចំពោះអ្នកដែលយើងមានបំណងប្រាថ្នា។ ហើយនៅពីលើរាល់អ្នកដែលមានវិជ្ជា លោកជាអ្នកដែលដឹងបំផុត (76). ពួកគេថា ប្រសិនបើគេលួច គឺបងប្រុសរបស់គេក៏បានលួចយ៉ាងប្រាកដជាកាលពីពេលមុននោះដែរ រួច មកយូសុហ្វក៏បានលាក់រឿងនេះនៅក្នុងខ្លួនរបស់គេ ហើយគេមិនទាន់បង្ហាញរឿងនេះទៅ ពួកគេនោះទេ។ យូសុហ្វនិយាយថា ពួកទាំងឡាយទេដែលអាក្រក់ខាងស្ថានភាព។ ហើយ អល់ឡោះដឹងបំផុតនូវអ្វីដែលពួកអ្នកពិពណ៌នា (77). ពួកគេនិយាយថា ឱលោកម្ចាស់អើយ! ការពិតជនម្នាក់នេះ មានបិតាម្នាក់ចាស់ជរាខ្លាំងណាស់ ហេតុនេះ សូមលោកចាប់យកម្នាក់ នៃពួកយើងជំនួសគេទៅ។ ការពិតយើងយើញអ្នកក្នុងចំណោមពួកដែលសាងកុសល (78). យូសុហ្វបានថា សូមជ្រកកោននឹងអល់ឡោះ! ដែលយើងនឹងចាប់យកក្រៅពីអ្នកដែល យើងបានជួបប្រទះនូវប្រជាប់ប្រជារបស់យើងនៅជាមួយគេ ពុំនោះទេ យើងពិតជាពពួក អយុត្តិធម៌យ៉ាងប្រាកដ (79). នៅពេលដែលពួកគេបានអស់សង្ឃឹមពីរឿងនេះមក ពួក គេបានដកខ្លួនចេញ ដើម្បីពិភាក្សាសង្គ្រោះ។ ម្នាក់បងគេនៃពួកគេនោះថា តើពួកអ្នក មិនទាន់ដឹងទេឬថា បិតារបស់ពួកអ្នក ពិតជាបានយកលើពួកអ្នកនូវចំណងកិច្ចសន្យា មួយអំពីអល់ឡោះហើយកាលពីមុន ដែលពួកអ្នកបានធ្វេសប្រហែសក្នុងរឿងយូសុហ្វ? ដូច្នេះ យើងមិនអាចចាកចេញពីទឹកដីនេះបានទេ លុះត្រាតែបិតាយើងអនុញ្ញាតឱ្យយើង ឬទាល់តែអល់ឡោះវិនិច្ឆ័យឱ្យយើង លោកជាអ្នកដែលវិនិច្ឆ័យដ៏ប្រសើរជាងគេបង្អស់ (80). ចូរពួកអ្នកវិលត្រលប់ទៅកាន់បិតារបស់ពួកអ្នក រួចមក ចូរពួកអ្នកថា ឱបិតារបស់ ពួកយើង! ជាការពិតណាស់បុត្រារបស់បិតាបានលួច ហើយពួកយើងមិនបានធ្វើជា សាក្សីទេ ក្រៅពីអ្វីដែលពួកយើងបានដឹង ហើយសំរាប់អាថ៌កំបាំង ពួកយើងក៏មិនអាច ការពារបានទេ (81). សូមបិតាសួរទៅភូមិការ ដែលពួកយើងបានស្នាក់នៅនោះទៅ ព្រម ទាំងអ្នកបរសត្វអូដ្ឋក្នុងពេលដែលពួកយើងត្រលប់មកវិញ។

ហើយពួកយើង គឺពិតជា ពួកដែលនិយាយត្រង់ពិតមែន (82). បិតាថា ជាការពិតណាស់ ខ្លួនរបស់ពួកអ្នកផ្ទាល់ ដែលបានតាក់តែងឱ្យពួកអ្នកនូវកិច្ចការមួយ។ ណ្តើយ! ត្រូវទ្រាំអត់ធ្មត់យ៉ាងល្អទៅចុះ សង្ឃឹមថា អល់ឡោះនឹងនាំពួកគេមកកាន់យើងទាំងអស់គ្នា។ ការពិតលោក គឺពិតជា អ្នកដែលដឹងបំផុត មហាគតិបណ្ឌិត (83). គាត់បានដើរងាកចេញពីពួកគេ ព្រមទាំងស្រដី ថា ឱអនិច្ចាយូសុហ្វ! នេត្រាទាំងពីររបស់គាត់បានឡើងសំបុរស ដោយសារការកើតទុក្ខ ពីព្រោះគាត់ជាអ្នកទប់កំហឹង (84). ពួកគេបានថា សច្ចានឹងអល់ឡោះ បិតាមិនទាន់ អស់ទេ ដែលបិតានឹកទៅយូសុហ្វ រហូតដល់បិតាធ្លាក់ខ្លួនឈឺខ្សោយ ឬរហូតបិតាមាន ក្នុងចំណោមពួកអ្នកវិនាសខ្លួន (85). គាត់និយាយថា ការពិតឆ្ពោះទៅអល់ឡោះតែ ប៉ុណ្ណោះ ដែលយើងតួញ្ជែរនូវការឈឺចាប់របស់យើង ព្រមទាំងទុក្ខព្រួយរបស់យើង។ ហើយយើងដឹងណាស់អំពីរឿងអល់ឡោះ នូវអ្វីដែលពួកអ្នកមិនទាន់បានដឹងនោះ (86).

យូសុះជួបជុំក្រុមគ្រួសារ

បន្ទាប់ពីពួកគេទាំង៩នាក់បានត្រលប់ពីប្រទេសអសហ្សីប ដោយគ្មានពុនយ៉ាមុន និងយាហុទហ្សា ធ្វើឲ្យយ៉ាកូបកាន់តែមានទុកព្រួយក្នុងចិត្ត និងរងការឈឺចាប់កាន់តែខ្លាំងព្រួយបារម្ភណ៍ចំពោះសុវត្ថភាពនឹងបារម្ភណ៍ចំពោះដំណឹងពួកកូនៗទាំ៣នាក់ដែលបាត់ឆ្ងាយពីក្រុមគ្រួសារ យ៉ាកូបមានក្តីកង្វល់ធំធេង អាហារកមិនញ៉ាំ ទឹកកមិនផឹកតហូតធ្វើឲ្យខ្លួនរបស់លោកស្គមតឹងរៃ និងលែងមើលអ្វីមិនឃើញ។ ដោយឃើញដូច្នោះកូនៗបានព្យាយាមលួងលោមយ៉ាកូប ដើម្បីទប់អារម្មណ៍ រំលែកទុកព្រួយកាត់ចិត្តដោយគេបាននិយាយថា៖ *ឱលោកពុកជាទីគោរព.. លោកគឺជាណាពី និងជាតំណាងរបស់អល់ឡោះដើម្បីដឹកនាំមនុស្សលោកឲ្យគោរពប្រណិបត្តិចំពោះទ្រង់ ដូច្នោះអ្វីៗគ្រប់យ៉ាងគឺទ្រង់ជាអ្នកកំណត់ យើងត្រូវប្រគល់ជូនលោកចុះរាងផល់ល្អនឹងអាក្រក់ ហេតុដូច្នោះលោកពុកគួរតែរក្សាសុខភាពឲ្យបានល្អ ដើម្បីបន្តការដឹកនាំរបស់លោកពុកជាណាពីម្នាក់ ដែលអល់ឡោះបានដាក់បង្គាប់បញ្ជា និងជាតួនាទីរបស់លោកពុក ប្រសិនបើ*

លោកពុកនៅតែមិនព្រមហូបបុក និងមិនមើលថែពីសុខភាពខ្លួនឯងបែបនេះ ពួកយើងខ្លាចក្រែងមានថ្ងៃណាមួយលោកពុកនឹងធ្លាក់ខ្លួនឈឺកាន់តែខ្លាំង រង្វែងស្មារតី រហូតបណ្តាលឲ្យលោកពុកលាចាកពីពួកយើងនឹងបាត់បង់ភាពជាណាពីរបស់លោក។ យ៉ាកូប បានឆ្លើយវិញថា៖ *តើមានអ្វីខ្លះដែលយើងអាចកាត់ចិត្តទប់អារម្មណ៍បាន បើមនុស្សដែលយើងស្រលាញ់ពេញចិត្ត និងតែងតែបារម្ភណ៍ចំពោះពួកគេនោះ បានឃ្លាត់ឆ្ងាយពីកែវភ្នែករបស់យើងដូច្នោះ កាលមុនយើងធ្លាប់ឃើញពួកអ្នកទាំងអស់គ្នានៅចំពោះមុខយើងជារៀងរាល់ថ្ងៃ ប៉ុនតែឥឡូវ យើងបានបាត់បង់មួយផ្នែកនៃក្រុមគ្រួសារមួយនេះ។ យើងជឿជាក់នឹងដឹងយ៉ាងច្បាស់ថា យូសុះពិតជានៅរស់រានមានជីវិត ហើយកំពុងរស់នៅលើភពផែនដីរបស់អល់ឡោះនេះ ប៉ុន្តែកន្លែងណាដែលយូសុះគំពុងនៅបច្ចុប្បន្ន ហើយដូចម្តេចដែសុខទុក្ខរបស់យូសុះ? មានតែអល់ឡោះទេដែលដឹងអំពីរឿងរ៉ាវរបស់យូសុះ។ ប្រសិនបើពួកអ្នកទាំង៩នាក់ព្រួយបារម្ភណ៍ចំពោះយើង ខ្វល់ខ្វាយចំពោះសុខភាពរបស់យើងពិត ចូរពួកអ្នកទាំងអស់គ្នាប្រញ៉ាប់ចេញដំណើរទៅរកយូសុះគ្រប់កន្លែងគ្រប់ច្រកល្ហក់ណាដែលមានមនុស្ស និងជាភពផែនដីរបស់អល់ឡោះរហូតបានជួបនឹងយូសុះ និងបានដឹងពីសុខទុក្ខរបស់គេ ហើយចូរកុំបដិសេធចំពោះការធ្វើដំណើរុករកយូសុះ ព្រោះអ្នកដែលបដិសេធនោះគឺមានតែពួកក្បត់ទេដែលពួកគេតែងតែបដិសេធចំពោះរ៉ោះម៉ាត់ (ក្តីមេត្តាករុណា) របស់អល់ឡោះ។*

បន្ទាប់ពីបានលឺប្រសាសន៍របស់យ៉ាកូបដូច្នោះ និងដោយពួកគេទាំង៩នាក់ព្រួយបារម្ភណ៍ចំពោះសុខភាពយ៉ាកូបផង និងដើម្បីធ្វើឲ្យយ៉ាកូបសប្បាយចិត្តផងដែនោះ ពួកគេបានឯកភាពទទួលយកនឹងអនុវត្តន៍ធ្វើតាមប្រសាសន៍របស់យ៉ាកូបដោយមិនរុញរឡើយ ទុះជាពួកគេមិនបានដឹងថា យូសុះរស់នៅទីណា ស្លាប់រឺរស់ក៏ដោយ លើសពីនេះពួកគេមិនដែលរំពឹងទុកថានឹងបានជួបយូសុះដែ ដោយក្នុងចិត្តរបស់ពួកគេដឹងជាស្រេចថា យូសុះស្លាប់បាត់បង់ជីវិតបាត់ទៅហើយ។ ជាចំណុចចាប់ផ្តើមក្នុងការដោះ

ស្រាយធ្វើយ៉ាងណាឲ្យយ៉ាកូបបានសប្បាយចិត្តវិញខ្លះនោះ ពួកគេបានសម្រេចចិត្តទៅជួយដោះស្រាយពុនយ៉ាមុីន និងយ៉ាហុទហ្សា ចេញពីការចោទប្រកាន់របស់ស្តេចយូសុះជាមុនសិន រួចបន្តដំណើរដើម្បីរុករកយូសុះជាក្រោយ។ បន្ទាប់ពីសម្រេចិត្តរួច ពួកគេបងប្អូនទាំង៩នាក់ បានគោរពសំលាយ៉ាកូបដើម្បីឆ្ពស់ទៅកាន់ប្រទេសអេហ្ស៊ីបដើម្បីដោះស្រាយរឿងពុនយ៉ាមុីនផង និងសាកសួរអំពីដំណឹងរបស់យូសុះផង។ ក្នុងការធ្វើដំណើរតាមផ្លូវ ពួកគេបានព្យាយាមសាក់សួរគ្រប់តំបន់ ភូមិ មនុស្សដែលពួកគេជួប ប្រាប់អំពីកិនភាគយូសុះដើម្បីទទួលបានដំណឹង ប៉ុន្តែអ្វីហបីដូចស្ងាត់សូន្យឈឹង ពុំទទួលបានដាផ្លែផ្កាអ្វីបន្តិចអំពីយូសុះទ្បីយ។

មិនយូប៉ុន្មានក្រោយមក ពួកគេបងប្អូនទាំង៩នាក់បានទៅដល់ប្រទេសអេហ្ស៊ីប ដើម្បីដោះស្រាយជូនពុនយ៉ាមុីនផង នឹងដើម្បីទិញស្បៀងដែលស្តេចយូសុះដាក់លក់នោះផង។ នៅពេលពួកគេបានទៅដល់ ពួកគេកបានជួបនិងយូសុះនិងបាននិយាយទៅកាន់យូសុះថា៖ *ឪស្តេចជាទីគោរព.. នេះគឺជាលើកទីពរហីយដែលបងប្អូនរបស់យើងខ្ញុំបានមកដល់ទីនេះ កាលពីលើមុនៗពួកយើងទាំងអស់គ្នាមកកាន់ទីនេះដើម្បីសុំការអនុញ្ញាតពីលោកដើម្បីលក់ស្បៀងដែលលោកមានមកពួកយើង ដើម្បីបំពេញកង្វះខាតដែលជាតម្រូវការប្រើប្រាស់ជាប្រចាំថ្ងៃគ្រួសាររបស់ពួកយើង ដូច្នោះដែលើកនេះ គោលបំណងរបស់យើងខ្ញុំទាំងអស់គ្នាមកដើម្បីទិញស្បៀងផង និងសុំការអនុញ្ញាតពីលោកដើម្បីដោះលែងបងប្អូនប្រុសពៅរបស់យើងខ្ញុំនិង និងដើម្បីស្វែងរកដំណឹងរបស់យូសុះបងប្រុសពុនយ៉ាមុីនផងដែ។ ពីព្រោះលើកនេះជាកតព្វកិច្ចដ៏ចាំបាច់នឹងធ្ងន់ធ្ងៃដែលឪពុកយើងខ្ញុំទាំងអស់គ្នាបានដាក់ជូន ដោយហេតុលោកព្រួយបារម្ភណ៍ចំពោះសុខទុកពុនយ៉ាមុីន និងកំពុងជួបនឹងជំងឺស្តមរីងរៃដោយសារលោកមិនពិសារអាហារ និងភ្នែករបស់លោកកាន់តែលែងមើលអ្វីមិនឃើញ តាំងពីបាត់យូសុះពីលោកមក។ ហេតុដូច្នោះ*

យើងខ្ញុំសូមអង្វរដល់លោកដើម្បីដោះលែងពុនយ៉ាមុីន ឲ្យគេមានសិទ្ធិសេរីភាពនឹងបានជួបនឹងឪពុករបស់យើងខ្ញុំ ដើម្បីឲ្យលោកបានធូស្បាយពីជំងឺ និងការព្រួយបារម្ភណ៍។

នៅពេលយូសុះលឺដូច្នោះ ធ្វើឲ្យយូសុះមានការព្រួយបារម្ភណ៍ចំពោះសុខទុករបស់ឪពុករបស់ខ្លួន យូសុះបានសម្រេចចិត្តប្រាំដល់បងប្អូនផ្សេងៗទៀតថា៖ តើពួកអ្នកទាំងអស់គ្នាមានចាំទេ កាល់មុនពួកអ្នកធ្លាប់ពង្រាត់យូសុះឲ្យឃ្លាត់ឆ្ងាយពីឪពុកជាទីស្រលាញ់របស់គេ រួចធ្វើបាបគេគ្រប់បែបយ៉ាង? តើពួកអ្នកមាននីចាំទេ ក្នុងគ្រាដែលពួកអ្នកបានបបួលយូសុះទៅលេងឯព្រៃឆ្ងាយពីផ្ទះ រួចពួកអ្នកចាប់សម្រាតខោអាវយូសុះរួចទំលាក់ក្នុងអណ្តូងដ៏ងងឹតជ្រៅមួយក្បែផ្លូវសធារណៈ? តើពួកអ្នកមានដឹងទេថា នោះគឺជាកំហុសមួយដោយអ្នកបានក្បត់នឹងឪពុកជាទីលាញ្ជរបស់អ្នក រហូតបណ្តាលឲ្យលោកដេកឈឺយ៉ាងធ្ងន់ធ្ងៅបែបនេះ?ហើយអ្នកដឹងទេថា នោះគឺជាបាបកម្មមួយដែលអល់ឡោះហាមជំពោះពួកអ្នក?។ លឺប្រសាសន៍របស់យូសុះយ៉ាងដូច្នោះ ធ្វើឲ្យបងប្អូនពួកគេទាំង៩នាក់មានការងើយឆ្ងល់ ហើយមើលមុខគ្នារួចខ្សឹបសួរគ្នាថា៖ រឿងរ៉ាវទាំងអស់នោះគ្មាននរណាម្នាក់ដឹងនោះទេ ហើយពួកគេម្នាក់ៗកមិនដែលនិយាយប្រាប់នរណាម្នាក់នោះដែ តើហេតុអ្វីបានជាយូសុះដឹងរឿងរ៉ាវទាំងអស់នោះច្បាស់ម្លេះ?។

យូសុះបានបន្តថា៖ *មែនហើយ ខ្ញុំគឺជាយូសុះប្អូនរបស់ពួកអ្នក ហើយពុនយ៉ាមុីនគឺជាប្អូនប្រុសបង្កើតរបស់យើង អល់ឡោះបានផ្តល់សេចក្តីអាណិតស្រលាញ់មកលើរូបយើងបន្ទាប់ពីលោកបានសាកល្បងគ្រប់សប់បែបយ៉ាងចំពោះយើង ហើយលោកបានប្រទាននូវកិត្តិយស កេរ៍ឈ្មោះ ល្បែងល្បីមកលើយើងជាសម្ងដែលពួកអ្នកបានធ្វើមកលើយើង។*

បន្ទាប់ពីពួកគេទាំងអស់គ្នាដឹងថា ស្តេចគ្រប់គ្រងប្រទេសអាហ្សិបទាំងមូលគឺជាយូសុះដែលជាប្អូនរបស់របស់ពួកគេ ដែលពួកគេធ្លាប់ធ្វើបាបនោះ ទឹកមុខរបស់ពួកគេម្នាក់ៗ

ធ្លាក់ចុះយ៉ាងក្រៀមក្រំ ពោពេញទៅដោយអាម៉ាស់បំផុត រួចម្នាក់ក្នុងចំណោមពួកគេបាននិយាយទៅកាន់យូសុះថា៖ *យូសុះជាទីគោរព.. យើងខ្ញុំទាំងអស់គ្នាបានដឹងកំហុសនឹងព្រមទទួលទោសចំពោះគ្រប់ទង្វើរបស់ពួកយើងចំពោះអ្នក ចូរអ្នកដាក់ទោសមកពួកយើងចុះ ឲ្យសមនឹងអ្វីយើងពួកយើងទាំងអស់គ្នាបានធ្វើលើអ្នក ពួកយើងគ្មានមុខមាត់ដើម្បីបន្តនិយាយជាមួយអ្នកនោះទេ កំហុសរបស់ពួកយើងពិតជាធ្ងន់ធ្ងោណាស់ ដូច្នោះចូរអ្នកអនុវត្តន៍នឹងសម្រេចចុះនូវអ្វីដែលអ្នកគិតថាត្រឹមត្រូវជាការតបស្នងវិញ។* លីដូច្នោះយូសុះបានឆ្លើយវិញថា៖ *ជាការពិតណាស់កំហុសរបស់ពួកអ្នកធ្ងន់ធ្ងោណាស់ ពួកអ្នកត្រូវតែត្រូវទទួលទោសកំហុសសមនឹងទង្វើដែលពួកអ្នកបានធ្វើមកលើយើង ក៏ប៉ុន្តែវាគ្មានផលប្រយោជន៍អ្វីចំពោះយើងនោះទេ ផ្ទុយទៅវិញវាកាន់ធ្វើឲ្យយើងមានបាបកម្មនឹងអល់ឡោះ និងមានវិប្បដិសារីលើខ្លួនឯងវិញទេ ម៉្យាងវិញទៀតវាកាន់តែធ្វើឲ្យឪពុកជាទីស្រលាញ់របស់យើងដែលកំពុងដេកឈឺនៅឯផ្ទះ ពិបាកចិត្តកាន់តែខ្លាំងទៅវិញទេ ដូច្នោះយើងនិងលើកលែងទោសទាំងអស់ (អភ័យទោស) ចំពោះរាល់ទង្វើដែលពួកអ្នកបានធ្វើមកលើយើង សូមពួកអ្នកប្រញាប់រៀបចំតវ៉ាន់ចេញដំណើរត្រលប់ទៅផ្ទះវិញ និងនាំលោកឪពុកមកកាន់ទីនេះវិញក្នុងរយៈពេលដ៏ខ្លីបំផុត..។* យូសុះបានប្រគល់អាវមួយដល់បងប្អូនទាំង៩នាក់ រួចបាននិយាយផ្តាំផ្ញើថា៖ នេះគឺជាអាវរបស់យើង ពួកអ្នកត្រូវរក្សាសុវត្ថភាពអាវនេះឲ្យបានល្អនឹងគង់វង់ នៅពេលទៅដល់ ចូរពួកអ្នកយកអាវនេះដួតលើមុខរបស់លោកឪពុក នោះភ្នែករបស់លោកនឹងមើលឃើញវិញភ្លឺដូចធម្មតា។ ពួកគេទាំង១០នាក់បានរៀបចំតវ៉ែតវ៉ាន់ និងបានធ្វើដំណើរចាកចេញពីយូសុះឆ្ពស់ទៅជួបនឹងលោកពុករបស់ពួកគេវិញដែលកំពុងរង់ចាំផ្លូវ ពត៌មានអំពីយូសុះ និងពុនយ៉ាមីនពីពួកគេ ទាំងត្រេកអរ សប្បាយរីករាយក្រៃលែង។

មិនយូប៉ុន្មានពួកគេបងប្អូនទាំង១០នាក់បានធ្វើដំណើរដល់ផ្ទះដោយសុខស្លាម៉ាត់ និងបានរៀបរាប់ប្រាប់យ៉ាកូបដែលកំពុងដេកឈឺនៅក្នុងផ្ទះ ទាំងភ្នែកងងឹតនោះអំពីយូសុះ

និងពុកយ៉ាម៉ីន ពួកគេបានយកអាវយូសុះនោះជូតលើមុខរបស់យ៉ាកូប ធ្វើឲ្យភ្នែកយ៉ាកូបមើលឃើញវិញធម្មតា ពេលនោះយ៉ាកូបសប្បាយរីករាយគ្មានអ្វីមកប្រៀបផ្ទឹមពុំបានយ៉ាកូននិងកូនៗ មួយក្រុមគ្រួសារបានប្រញាប់ប្រញាលរៀបចំឥវ៉ាន់ រួចចាកចេញពីផ្ទះឆ្ពស់ទៅកាន់ប្រទេសអាហ្សិបវិញតាមផ្តាំផ្ញើរបស់យូសុះ។

នៅពេលក្រុមគ្រួសារយ៉ាកូន ទាំងប្រពន្ធ (យ៉ាទ្បា) និងពួកកូនៗទាំងអស់បានទៅដល់បរទេសអេហ្សិប យូសុះបានចាត់តាំងមន្ត្រីក្រោមការគ្រប់គ្រងរបស់ខ្លួនឲ្យនៅចាំទទួលនៅឯជាយក្រុង រួមពួកគេបាននាំក្រុមគ្រួសារយ៉ាកូបចូលក្នុងវាំងដើម្បីជួបនិងយូសុះ។ ពួកគេសប្បាយរីករាយណាស់ យ៉ាកូបបានបន្តស្រក់ទឹកភ្នែក ប៉ុន្តែទឹកភ្នែកលើកនេះមិនមែនស្រក់ដោយសារបែកបាក់នោះទេ ពោល ស្រក់ដោយសារយ៉ាក់កូបសប្បាយរីករាយហួស ដោយមិននឹកស្មានថាបានជួបនឹងយូសុះដែលជាកូនជាទីស្រលាញ់របស់ខ្លួនវិញទេ ម៉្យាងវិញទៀតដោយបានជួបជុំក្រុមគ្រួសារដូចដើមវិញ ជាពិសេសបានឃើញយូសុះក្លាយជាមនុស្សម្នាក់ដែលយ៉ាកូបធ្លាប់កាត់សុបិនឲ្យយូសុះពីមុន យូសុះបានយកដៃជូតទឹកភ្នែករបស់យ៉ាកូបដែលកំពុងហូរលើថ្ពាល់នោះ និងបានលើកឪពុករបស់ខ្លួន នឹងប្រពន្ធដាក់លើបាទ្បាំង (កន្លែងស្តេចអង្គុយ) រួចនិយាយថា៖ *ជាការពិតណាស់.. អ្វីដែលកូនធ្លាប់សុបិនឃើញនោះ វាបានក្លាយជាការពិតដូចលោកពុកធ្លាប់បានកាត់សុបិនរបស់កូន អល់ឡោះបានគោរពតាមសន្យាដែលទ្រង់ធ្លាប់ពន្យល់សុបិនដល់កូន ទ្រង់បានសាកល្បងលើកូនគ្រប់សប់បែបយ៉ាង ទ្រង់បានពង្រាត់កូនពីលោកពុក ហើយទ្រង់បានជួយកូនឲ្យផុតពីក្នុងអណ្តូងដ៏ជ្រៅនឹងងងឹត ទ្រង់បានផ្តល់សេចក្តីសុខដល់កូនក្នុងគ្រាកូនធ្វើជាខ្ញុំបំរើរបស់គេ ទ្រង់បានផ្តល់សិទ្ធិសេរីភាពចំពោះកូនវិញនៅពេលដែលកូនត្រូវបានចោទប្រកាន់ និងជាប់គុក ទ្រង់បានផ្តល់កេរ៍ឈ្មោះ កិត្តិយស នឹងអណាចដ៏មហាសាលចំពោះកូន ទាំងនោះគឺជាប្រទានដ៏ថ្លៃថ្លារបស់ទ្រង់ រហូតបានធ្វើឲ្យក្រុមគ្រួសាររបស់យើងបានជួបគ្នាសារជាថ្មីម្តងទៀតនៅថ្ងៃនេះផងដែ។* រួចយូសុះបានលើក

ដៃសុំទូអារ (បួងសួង) ដូចអល់ឡោះបានមានបន្ទូលក្នុងគម្ពីអាល់កូរអាន ស៊ូរ៉ោះយូសុះ អាយ៉ាត់ទី ១០១ ថា៖

۞ رَبِّ قَدْ ءَاتَيْتَنِي مِنَ ٱلْمُلْكِ وَعَلَّمْتَنِي مِن تَأْوِيلِ ٱلْأَحَادِيثِ ۚ فَاطِرَ ٱلسَّمَٰوَٰتِ وَٱلْأَرْضِ أَنتَ وَلِيِّۦ فِى ٱلدُّنْيَا وَٱلْءَاخِرَةِ ۖ تَوَفَّنِى مُسْلِمًا وَأَلْحِقْنِى بِٱلصَّٰلِحِينَ ﴿١٠١﴾

មានន័យថា៖ ឱម្ចាស់របស់ខ្ញុំ!! លោកបានផ្តល់ឱ្យខ្ញុំយ៉ាងពិតប្រាកដនូវមួយផ្នែកនៃអំណាច ហើយទ្រង់បានបង្រៀនដល់ខ្ញុំមួយផ្នែកនៃការកាត់សុបិនទាំងអស់ ។ ឱអល់ឡោះដែលជាអ្នកបង្កើតមេឃ និងភពផែនដី លោកជាអ្នកដែលថែរក្សាខ្ញុំក្នុងលោកីយ៍នេះ និងលោកខាងមុខ សូមទ្រង់បញ្ចប់ជីវិតរបស់ខ្ញុំដោយមានជំនឿចំពោះទ្រង់ផងចុះ ហើយសូមទ្រង់ដាក់រូបខ្ញុំជាមួយនឹងអ្នកដែលធ្វើអំពើល្អផងចុះ។

ចាប់ពីថ្ងៃនោះមក ក្រុមគ្រួសារយូសុះបានជួបជុំគ្នាវិញ ហើយពួកគេបានបន្តការរស់នៅជុំគ្នាក្នុងវាំងយ៉ាងមានសុភមង្គល់ និងសេចក្តីសុខ បន្តដឹកនាំប្រទេសជាតិ ដឹកនាំមនុស្សលោកនឹងដាក់វ៉ៃមនុស្សលោកក្នុងខ្លួនជាណាពី ដើម្បីដើរលើគន្លងផ្លូវដ៏ត្រឹមត្រូវនៃសាសនារបស់អល់ឡោះ គោរពនឹងប្រណិបត្តិទៅចំពោះទ្រង់រាល់បង្គាប់បញ្ជាទាំងឡាយរបស់ទ្រង់ រហូតពួកគេម្នាក់ៗបានស្លាប់រៀងៗខ្លួន។

****

وبالله التوفيق والهداية والسلام عليكم ورحمة الله وبركاته

សូមរក្សាសិទ្ធិក្នុងការកែប្រែ

បើមានការខុសឆ្គង សូមផាក់ទងមកកាន់យើងខ្ញុំតាមរយៈហ្វេសប៊ុកផេក

ដើម្បីកែសម្រួលឡើងវិញ

1438 - 2016